ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
...០០.១៤២៧
វិទ្យាស្ថាន ភាសាជាតិ

## មាតិកា

### ១-ផ្នែកគ្រប់គ្រង

១.១- សមាសភាពនៃគណៈគ្រប់គ្រង :............................................................ទំព័រ i
១.២- អារម្ភកថា :....................................................................................................ទំព័រ iii

### ២-ផ្នែកអត្ថបទ

២.១- អំពីសញ្ញាប្រយោគចម្រូងចម្រាសមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន
ដោយបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ :.........................................................ទំព័រ ១
២.២- អំពីគុណនាមក្នុងភាសាខ្មែរបច្ចុប្បន្ន ដោយបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់
និង លោក ប៊ី សុខគង់ :.................................................................ទំព័រ ១៣
២.៣- ការប្រើប្រាស់និងការវិវត្តនៃកម្មវាចកៈសម័យមុនអង្គរ និង សម័យអង្គរ
ដោយលោក មាឃ បូរ៉ា :..............................................................ទំព័រ ២៤
២.៤- មូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង៥ខាងដើម
ក្នុងអក្ខរក្រមខ្មែរចូលផ្សំក្នុងទីតាំងរង ដោយលោក វ៉ាន់ ម៉ូន :..................ទំព័រ ៤១
២.៥- ស្ថានភាពនៃការប្រើប្រាស់ភាសាក្រោលនៅឃុំស្រែជិះ
ដោយវិទ្យាស្ថានភាសាជាតិ និង អង្គការ ICC:........................................ទំព័រ ៥១
២.៦- វចនសព្ទរទេះ ដោយក្រុមស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិ :...................ទំព័រ ៥៩
២.៧- វចនសព្ទតម្បាញ ដោយក្រុមស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិ :...............ទំព័រ ៦២
២.៨- អក្សរសិល្ប៍ប្រជាប្រិយជនជាតិជង ដោយក្រុមស្រាវជ្រាវ
នៃវិទ្យាស្ថានភាសាជាតិ :...................................................................ទំព័រ ៦៥
២.៩- ឯកតារង្វាស់ប្រវែង និង ឯកតារង្វាស់ទម្ងន់ដែលមាននៅក្នុង
បទានុក្រមបាឡី ម៉ឺង សែស និង មាននៅក្នុងវចនានុក្រមខ្មែរ
ដោយលោក ជួរ គារី :...................................................................ទំព័រ ៧០

RECEIVED
19 MAR 20..

## គណៈគ្រប់គ្រង

| | | |
|---|---|---|
| - ប្រធានកិត្តិយស | : | បណ្ឌិតសភាចារ្យ ខ្លួត ធីតា |
| - ចាងហ្វាងការផ្សាយ | : | បណ្ឌិតសភាចារ្យ អ៊ីវ ច័ន |
| - ចាងហ្វាងការផ្សាយរង | : | បណ្ឌិត សន ពៅ |
| | | លោក ជួរ គារី |

## គណៈកម្មការត្រួតពិនិត្យ

| | | |
|---|---|---|
| - ប្រធាន | : | បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ |
| - អនុប្រធាន | : | បណ្ឌិត ច័ន្ទ សំណព្វ |

## គណៈកម្មការអំណាន

| | | |
|---|---|---|
| - ប្រធាន | : | បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន |
| - អនុប្រធាន | : | បណ្ឌិតសភាចារ្យ សោម សុមុនី |
| - សមាជិក | : | បណ្ឌិត ម៉ៅ សុក្កន |
| | : | បណ្ឌិត នៅ ស៊ុន |
| | : | ឯកឧត្តម អ៊ុំ ប៉ុម |
| | : | ឯកឧត្តម លី សុធីរ័ត្ន |
| - សមាជិករបាយការណ៍ | : | លោក លាង សុភាព |

## ទំនាក់ទំនងទូទៅ

| | | |
|---|---|---|
| លោក ផង់ ភិរុណ | លោក ប៊ី សុខគង់ | លោក មាឃ បូរ៉ា |
| លោក ណុន សុខា | លោក ជួន សោរិទ្ធី | លោក វង្ស មេង |

## ក្រុមការងារ

| | | | |
|---|---|---|---|
| អ្នកកុំព្យូទ័រ ៖ | លោកស្រី តិប ស៊ីណា | កញ្ញា សុង ឧស្សាហ៍ | លោកស្រី គឹម កែវកល្យាណ |
| | លោកស្រី ភាជ ណាង | លោកស្រី ហង់ ថាវី | លោកស្រី អ៊ឹង ម៉ាល័យ |
| ជំនួយការកុំព្យូទ័រ៖ | លោក សេ អឿន | លោក វ៉ាត សូផាន | លោក កែវ លីណែត |
| | លោក ឃឹម វិច្ឆិកា | លោក ប៉ាង ចាន់ថា | លោក វ៉ាន់ ម៉ូន |
| | លោក គុយ រិន | កញ្ញា ព្រំ ចន្ថា | លោក យ៉ាត វ៉ាន់ថា |

## Comité de Direction

| | | |
|---|---|---|
| - Président d'honneur | : | Dr. Khlot Thyda |
| - Directeur de publication | : | Dr. IV Chan |
| - Directeur Adjoint | : | Dr. San Peou |
| | | M. Chour Keary |

## Comité de Correction-révision

| | | |
|---|---|---|
| - Président | : | Dr. Prum Moal |
| - Vice Président | : | Dr. Chan Somnoble |

## Comité de Lecture

| | | |
|---|---|---|
| - Président | : | Dr. Sum Chhumbun |
| - Vice Président | : | Dr. Som Somuny |
| - Membres | : | Dr. Mao Sokan |
| | : | Dr. Neou Sun |
| | : | M. Oum Pom |
| | : | M. Ly Sothyrath |
| -Membre rapporteur | : | M. Leang Sopheap |

## Relations publiques

M. Phang Phirun　M. By Sokkong　M. Meakh Bora
M. Non Sokha　M. Chuon Sorithy　M.Vong Meng

## Groupe de Travail

Mm. Tip Sina　Ms. Song Usa　Mm. Hang Thavy　M.Vann Maun
Mm. Pheach Nang　Mm. Kem Keokalyan　Mm. Ung Malay
M. Se Oeun　Mr. Vath Sophan　M. Keo Linet　M. Khim Vicheka
M. Pang Chantha　M. Kuy Rin　Ms. Prom Chantha　M. Yat Vantha

| | |
|---|---|
| ចេញផ្សាយដោយ | វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា |
| អាសយដ្ឋាន | ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល ២ |
| | ផ្លូវសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| Publié par | Institut de la Langue Nationale de l'A.R.C. |
| Adresse | Université Royale de Phnom Penh, Campus II |
| | Boulevard de la Fédération de Russie Phnom Penh Cambodge |
| E-mail | inlrac.languages@gmail.com |
| Téléphone | 012 836 476, 092 892 343, 012 906 585, 012 252 473 |

# អារម្ភកថា

ក្នុងក្របខណ្ឌវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ទស្សនាវដ្ដីលេខ៧នេះ មានចុះអត្ថបទរបស់ផ្នែកទាំងបួននៃវិទ្យាស្ថាន ដែលអ្នកស្រាវជ្រាវយើងបានចុះទៅប្រមូលទិន្នន័យបឋមរបស់ខ្លួនដល់មូលដ្ឋាន។ ទន្ទឹមនឹងនេះ ទស្សនាវដ្ដីយើង ក៏មានចុះផ្សាយនូវគោលវេយ្យាករណ៍នៃសញ្ញាប្រយោគចម្រូងចម្រាសមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន ដែលជាវិភាគទានសម្រាប់ការពិចារណាក្នុងការសរសេរអក្សរខ្មែរឱ្យបានឯកភាពគ្នា និង អត្ថបទរបស់អ្នកស្រាវជ្រាវខាងភាសាអម្បូរមន-ខ្មែរ នៃបងប្អូនជនជាតិដើមខ្មែរយើងផងដែរ។

ក្នុងនាម មិត្តភក្ដិ ថ្នាក់ដឹកនាំ និង មន្ត្រីវិទ្យាស្ថានភាសាជាតិទាំងអស់ សូមឧទ្ទិសទស្សនាវដ្ដីលេខនេះ ជូនចំពោះវិញ្ញាណក្ខន្ធឯកឧត្តមបណ្ឌិតសភាចារ្យ ឡុង សៀម ក្នុងឱកាសខួបទី៤នៃថ្ងៃមរណភាពរបស់ឯកឧត្តម (១៥ កក្កដា ២០០៧ - ១៥ កក្កដា ២០១១) ដើម្បីជាការរំឭកដល់គុណបំណាច់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ដែលជាស្ថាបនិកដ៏សំខាន់ក្នុងការបង្កើតវិទ្យាស្ថានភាសាជាតិ និង ចូលរួមបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បានខិតខំពុះពារត្រួសត្រាយផ្លូវ ដើម្បីស្វែងរកការឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ។

**ប្រធានវិទ្យាស្ថានភាសាជាតិ**

**បណ្ឌិតសភាចារ្យ អ៊ីច ច័ន**

# អំពីសញ្ញាប្រយោគ[១] ចម្រូងចម្រាសមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន

បទអន្តរាគមន៍របស់បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** សាស្ត្រាចារ្យភាសាវិទ្យា
ថ្លែងក្នុងសន្និសីទជាតិ រៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
លើកទី២ ថ្ងៃព្រហស្បតិ៍ ទី២២ ខែកញ្ញា ឆ្នាំ២០០៥

(អត្ថបទកែសម្រួល និង បំព្រួញ ទុកតែគោលធំៗ ដើម្បីឱ្យប្រាជ្ញាអ្នកអានចាប់បានដោយងាយ)

## I- សេចក្តីផ្តើម

ភាសាខ្មែរបច្ចុប្បន្នកំពុងលូតលាស់យ៉ាងខ្លាំង ទាំងផ្នែកវាក្យសព្ទ (ពាក្យនិងវាចាវិលាស) ទាំងផ្នែកសម្ព័ន្ធ ប៉ុន្តែ ការលូតលាស់ខ្លាំងនិងឆាប់រហ័សនេះបាននាំមកជាមួយនូវចំណុចអវិជ្ជមានមួយចំនួន រួមមាន ការបង្កើតពាក្យក្នុងភាពចម្រូងចម្រាស, ការប្រើល្បះកម្មវាចកៈដែលអ្នកប្រើប្រាស់ភាសាមិនទាន់មូលមតិគ្នា, ការប្រើដំណកឃ្លាប្លែកៗ គ្នា។ ល។

យើងមិនអាចមិនទទួលស្គាល់ថា ការលូតលាស់នេះបាននាំមកជាមួយនូវចំណុចវិជ្ជមានជាច្រើននោះទេ ប៉ុន្តែក្នុងអត្ថបទនេះ ខ្ញុំមានបំណងនិយាយតែពីចំណុចអវិជ្ជមានមួយចំនួន ដើម្បីស្វែងរកលក្ខណៈសមស្របផ្អែកលើវត្ថុវិស័យភាព (objectivité) តាមដែលអាចធ្វើទៅបាន ចៀសអត្តវិស័យភាព/អញ្ញថាភាព (subjectivité) របស់យើងម្នាក់ៗ ហើយ ខ្ញុំសុំ[២] លើកមកពិនិត្យតែបញ្ហាទាក់ទងនឹងការប្រើសញ្ញាក្នុងប្រយោគ[៣] (ឬហៅដោយខ្លីថា : "សញ្ញាប្រយោគ")។ ក្នុងចំណោមសញ្ញាប្រយោគទាំងប៉ុន្មាន ខ្ញុំនឹងសិក្សាតែអំពីដំណកឃ្លាដែលគេប្រើផ្សេងៗគ្នា :

- ដំណកឃ្លាជាមួយឈ្នាប់ចង : *និង*, *ហើយ*, *ឬ*, *ប៉ុន្តែ* ....

---

[១] - សូមកុំច្រឡំសញ្ញាប្រយោគដែលត្រូវនឹងពាក្យបារាំងថា signes de ponctuation និង វណ្ណយុត្តិដែលត្រូវនឹងពាក្យបារាំងថា signes diacritiques :
  - សញ្ញាប្រយោគ ជាសញ្ញាសម្រាប់សម្គាល់ចំណប់ល្បះ គម្លាតពាក្យ/កន្សោមពាក្យ ឱ្យដាច់ពីគ្នា , ...
  - វណ្ណយុត្តិ គេបង្កើតវាឡើងដើម្បីបង្រួបសេចក្តីត្រូវការក្នុងការកត់សូរ ដូច មូសិកទន្ត, ត្រីសព្ទ ជាដើម។

[២] - សម្តេចព្រះសង្ឃរាជ ជួន ណាត បានប្រើ "សុំ" ផង "សូម" ផង ក្នុងន័យដូចគ្នា ប៉ុន្តែ លោកបានប្រើ "សុំ" ច្រើនជាង "សូម" , ក្នុង *និទាន* និង *និវេទនកថា* របស់លោក សម្រាប់បោះពុម្ពវចនានុក្រមខ្មែរ គ្រាទី៥ ដូចមានជាឧទាហរណ៍ខ្លះៗខាងក្រោម :
  - "លោក លាង ហ៍បអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ បានមកសូមឱ្យខ្ញុំជួយឧបត្ថម្ភក្នុងការបោះពុម្ពគ្រាទី ៥ នេះ". (និទានសម្រាប់បោះពុម្ពវចនានុក្រមខ្មែរ គ្រាទី ៥, ឆ្នាំ១៩៦៧, ១៩៦៨, ទំព័រ ង)។
  - "ដល់មកកាលជាខាងចុង គ. ស. ១៩៦៧ លោកនាយកនៃពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ បានចាត់ការបោះពុម្ពវចនានុក្រមនេះជាគ្រាទី ៥ (...), សុំឱ្យគណៈកម្មការទាំង ៤ រូបនេះឆ្លៀតពេលធ្វើការឱ្យបានសម្រេចឆាប់បន្តិច (...)" , (និទាន ដដែល, ទំព័រ ឃ & ង)។
  - "លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី កិម-តូរ (ចន្ទមង្គលោ) សមាជិកក្រុមជំនុំព្រះត្រៃបិដក និងលោក ញូង-សឿង (...) ឱ្យទទួលបំពេញមុខងារនេះ" , (និវេទនកថា , ទំព័រ ជ)។

[៣] - ប្រយោគគឺ "ដំណើរពាក្យដែលមានសេចក្តីគ្រប់គ្រាន់មួយសង្កាត់ៗ : សេចក្តី១ប្រយោគ". វចនានុក្រមខ្មែរដោយសម្តេច ជួន ណាត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យគ្រាទី៥, ១៩៦៧។

- ដំណាក់ឃ្លាជាមួយកម្ម[៤] ទេសកាលដើមល្បះ,
- សញ្ញាប្រយោគណាខ្លះដែលកំពុងចោទជាបញ្ហារវាងអ្នកប្រើប្រាស់អក្សរខ្មែរ ។

ខ្ញុំចាត់ទុកគម្លាតរវាងពាក្យពីរម៉ាត់ឬកន្សោមពាក្យពីរកន្សោម (ដំណាក់ឃ្លា) ថា ជាសញ្ញាដូចសញ្ញាឯទៀតដែរ ពីព្រោះគម្លាតដែលទុកលំហាពណ៌សលើក្រដាសពណ៌ស/ផ្ទៃរាបពណ៌ស ឬ លំហាពណ៌ផ្សេងៗលើក្រដាសពណ៌ផ្សេងៗ/ផ្ទៃរាបពណ៌ផ្សេងៗនោះ ក៏ជាសញ្ញាដែលភ្នែកយើងមើលឃើញដូចសញ្ញាឯទៀតដែរ ។

## II. <u>អត្ថាធិប្បាយ</u>

### ១-<u>ធិន្នន័យធាក់ធងនឹងការប្រើដំណាក់ឃ្លាជាមួយ **ឈ្នាប់ចង**</u>

<u>រំលឹក</u> : ឈ្នាប់ចងមាន : *និង, ឬ, ហើយ, ប៉ុន្តែ, ...*

### ១.១- ការប្រើ<u>ឈ្នាប់ចង ដោយឥតដកឃ្លា</u>

ការប្រើឈ្នាប់ចងដោយឥតដកឃ្លា មានជាឧទាហរណ៍ដូចខាងក្រោម :

(១) - "(...) សំខ្យាដែលរាប់នាមនាមបង្គ្រប់ជាជាន់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា (...) គំរប់ប្រាំជាដើម<u>**និង**</u>ពាក្យថា : (...). (ពូរ អ៊ុម . វេយ្យាករណ៍ខ្មែរ . បណ្ណាគារ **គីម សេង** លេខ ២១២ វុក្ខវិថីខេមរភូមិន្ទ ឆ្នាំ១៩៥៨ . ទំព័រ ៥២ & ៥៣) ។

(២) - "សាលាក្រុងភ្នំពេញបានសម្រេចធ្វើការងារ (...) មិនអាចអត់ឱន<u>**ឬ**</u>លើកលែងទោសឱ្យក្រុមបើកឡានបំផ្លាញសួនច្បារ (...)". ("រស្មីកម្ពុជា" ថ្ងៃអង្គារ ២៣-០៨-០៥ . ទំព័រ ក៦ < ស្គាល់មុខរថយន្ត២គ្រឿងដែលបើកឡើងបំផ្លាញសួនច្បារសម្តេច ហ៊ុន សែន ដោយ **វ៉ាម៉ែន**) ។

### ១.២- ដំណាក់ឃ្លាខាងឆ្វេងនៃឈ្នាប់ចង

ថ្ងៃមួយ ក្នុងសម័យប្រជុំគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ (គ.ប.ស.) ឯ.ឧ.សាស្ត្រាចារ្យបណ្ឌិត ស៊ន សំណាង បានសុំឱ្យគេកែដំណាក់ឃ្លាខាងឆ្វេងផងនិងខាងស្តាំផងនៃឈ្នាប់ចងមកត្រឹមដំណាក់ឃ្លាខាងឆ្វេងនៃឈ្នាប់វិញ ។ នៅពេលនោះ ឯ.ឧ.សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានការពារការប្រើដំណាក់ឃ្លាខាងឆ្វេងផងនិងខាងស្តាំផងនៃឈ្នាប់ ប៉ុន្តែ ឥឡូវនេះ គាត់បានប្រែចិត្ត ហើយ ថែមទាំងបានបង្ខំសហការីខ្ញុំ (ដែលដកឃ្លាខាងឆ្វេងផងនិងខាងស្តាំផងនៃឈ្នាប់) ឱ្យដកឃ្លាតែខាងឆ្វេងនៃឈ្នាប់វិញ ដោយសំអាងថា ការដកឃ្លាបែបនេះមានគេនិយមប្រើច្រើន[៥] ។

---

[៤] - ចំពោះបញ្ញត្តិនេះ (ដែលត្រូវនឹងពាក្យបារាំង complément) អ្នកវេយ្យាករណ៍ខ្មែរបានប្រើពាក្យផ្សេងៗគ្នា មាន : *កម្មរង, កម្មបទ, បទកម្ម* និង *កម្ម* ។ ដោយពាក្យ *កម្ម* ត្រូវបានអនុម័តយកជាផ្លូវការដោយគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) កាលពីប៉ុន្មានខែមុន ខ្ញុំក៏ប្រើពាក្យនេះ ជំនួសពាក្យ "កម្មរង" ដែលខ្ញុំបានប្រើក្នុងការបោះពុម្ពអត្ថបទនេះលើកមុន ។

[៥] - ខ្ញុំសង្ឃឹមថា ឯ.ឧ.សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ សុខចិត្តត្រឡប់មកគំនិតដើមរបស់គាត់វិញ ពីព្រោះការប្រើដំណាក់ឃ្លា ជាចំណុចមួយនៃភាសាវិទ្យា ដែលជាវិទ្យាសាស្ត្រ និង ដែលយកវត្ថុវិស័យភាព(objectivité)ជាមូលដ្ឋាន ។ ការនិយមប្រើភាគច្រើននឹងកើតមានឡើងសម្រាប់ដំណាក់ឃ្លាស្របតាមសម្ព័ន្ធវិទ្យា បើអ្នកភាសាវិទ្យា/ភាសាវិទូស្រុះស្រួលគ្នាណែនាំអ្នកប្រើអក្សរខ្មែរឱ្យបោះបង់ទម្លាប់ចាស់ ។

ដោយគេធ្លាប់ប្រទះជាញឹកញយនូវការប្រើដំណកឃ្លាបែបនេះ  ខ្ញុំសុំផ្តល់ឧទាហរណ៍តែបីទេ  ( គ្រាន់តែជាចំ-ណាប់អារម្មណ៍) ដូចខាងក្រោម :

( ១) - "សូមអតិថិជនទាំងអស់ មេត្តាជ្រាប **និង**អនុវត្តតាមសេចក្តីជូនដំណឹងនេះ ដោយសេចក្តីអនុគ្រោះ ". ( សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន AZ ក្នុងកាសែត "រស្មីកម្ពុជា" ចុះថ្ងៃពុធ ១៩ ធ្នូ ឆ្នាំ២០០៤ , ទំព័រ ក៣) ។

( ២) - "(...) ខ្ញុំមិននិយាយពីតម្លាភាព **ឬ**មិនតម្លាភាពទេ (...) ", ( "រស្មីកម្ពុជា"  ថ្ងៃសៅរ៍ ២០-០៨-០៥, ទំព័រ ក៧ < រឿងអាស្រូវដូរទីតាំងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ អត្ថបទរបស់ **យិន  លាងគង់** ) ។

( ៣) - "យើងប្រែពាក្យបរទេសដោយចេញជាន័យសេចក្តីខ្មែរត្រង់ៗ  តាមមុខវិជ្ជានីមួយៗ  **ឬ**ក៏រក្សាទុកសូរបរទេសដដែល គ្រាន់តែសំរួលសំណេរតាមខ្មែរ ។ ", ( អារម្ភកថានៃសទ្ទានុក្រមខេមរយានកម្ម លេខ២ ឆ្នាំ១៩៧៣[៦] ) ។

## ១.៣- ដំណកឃ្លាខាងឆ្វេងផងនិងខាងស្តាំផងនៃឃ្លាប់ចង

ការប្រើឃ្លាប់ចង ដោយមានដំណកឃ្លាខាងឆ្វេងផងនិងខាងស្តាំផង មានជាឧទាហរណ៍ដូចខាងក្រោម :

( ១) - "(...) ខ្ញុំសូមសំដែងការស្វាគមន៍ **និង** ពរសព្ទសាធុការយ៉ាងកក់ក្តៅបំផុតជូនចំពោះឯកឧត្តម **និង** លោកជំទាវទាំងអស់ ដែល (...) ", (សុន្ទរកថារបស់សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន  សែន** បោះពុម្ពផ្សាយក្នុង "**យុទ្ធសាស្ត្រចតុកោណ**" នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) ។

( ២) - "ក្រសួងអប់រំ យុវជន **និង** កីឡា" ( នៅលើក្បាលលិខិតរបស់ក្រសួងអប់រំ , សារាចរ លេខ ០៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ និង នៅលើផ្លាកដាក់នៅមុខក្រសួងសាមីនេះ) ។

( ៣) -  " ក្រសួងសេដ្ឋកិច្ច **និង** ហិរញ្ញវត្ថុ " ( ក្បាលលិខិត លេខ ៧៦៦៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩) ។

( ៤) - " (...) សម្តម **ឬ** សំគម , សម្តី **ឬ** សំដី ជាដើម (...) ", ( សម្តេច ជួន ណាត *និទាន* , ទំព័រ ឆ, សម្រាប់បោះពុម្ពវចនានុក្រមខ្មែរឡើងវិញ គ្រាទី៥ ឆ្នាំ១៩៦៧) ។

( ៥) - "(...)តែងតែទាស់ភ្នែក **ឬ** ទាស់ត្រចៀកអ្នកដែលពុំទាន់ស៊ាំនឹងពាក្យនេះ ។" ( អារម្ភកថានៃសទ្ទា-នុក្រមខេមរយានកម្ម លេខ១ ឆ្នាំ១៩៦៩) ។

( ៦) - "គុណនាម គឺជាពាក្យដែលបញ្ជាក់លក្ខណៈឱ្យនាម **ឬ** សព្វនាម ។" ( អ៊ុក វិបុល, វេយ្យាករណ៍ខ្មែរ-ទំនើប, ថ្នាក់ទី១២, បោះពុម្ពដោយ "គ្រឹះស្ថានបោះពុម្ព (...)" ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ) ។

---

[៦] - ការដកឃ្លាបែបនេះចាប់មានក្នុងសទ្ទានុក្រមខេមរយានកម្ម លេខ២ ឆ្នាំ១៩៧៣ ។ ក្នុងសទ្ទានុក្រមខេមរយានកម្ម លេខ១ ឆ្នាំ១៩៦៩ គេដកឃ្លាខាងឆ្វេងផងនិងខាងស្តាំផង ជាទូទៅ ( សូមមើលឧទាហរណ៍ ១.៣- ( ៥ ) ) ។

### ១.៤-ការប្រើជំណាកឃ្លាខាមួយឈ្នាប់ចង ដោយគោរពវចនានុក្រម(ចងករឡៀមតូចៗឱ្យបានជាករឡៀមធំដោយឥតជកឃ្លា ហើយ ចងករឡៀមធំទៅនឹងករឡៀមធំដោយជកឃ្លាខាងឆ្វេងផងខាងស្ដាំផង)

(១)- "ក្នុងគ្រានេះ, ខ្ញុំលៃពេលម៉ោង (...), បានដកស្រង់យកកាព្យ (...), សុភាសិត**និង**ភាសិតបុរាណខ្លះ **និង** កាព្យរបស់ខ្ញុំខ្លះ (...), (និទាន,ទំព័រ ង, សម្រាប់បោះពុម្ពវចនានុក្រមខ្មែរឡើងវិញ គ្រាទី៥ ឆ្នាំ១៩៦៧)) ។

(២)-(...)" ស្វែងរកជំនួយឧបត្ថម្ភ ពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ**និង**អន្តរជាតិ **និង** ពីប្រភពផ្សេងៗទៀត ".(បទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិភាសាខ្មែរ.ចុះផ្សាយក្នុងព្រឹត្តិបត្រលេខ១ , ទំព័រ១២ នៃគណៈកម្មាធិការនេះ ។

### ១.៥- ការប្រើជំណាកឃ្លាខាមួយឈ្នាប់ចង បែបសេរីនិយម

សាធារណជនខ្លះ (បុគ្គលឬភ្នាក់ងារស្ថាប័ន) ដែលក្នុងនោះមានមន្ត្រីខ្លះនៃក្រសួងអប់រំផងដែរ ហាក់ដូចជាយល់ថា គេអាចប្រើជំណាកឃ្លាខាងឆ្វេងនៃឈ្នាប់ចង ឬ ខាងឆ្វេងផងនិងខាងស្ដាំផង ឬក៏ គ្មានជំណាកឃ្លា បានដូចគ្នា. ឧទាហរណ៍ :

(១)- "ក្រសួងអប់រំ យុវជន **និង** កីឡា" ( នៅលើក្បាលលិខិតរបស់ក្រសួងអប់រំ , សារាចរ លេខ ០៣ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៦ និង នៅលើផ្លាកដាក់នៅមុខក្រសួងសាមីនេះ) ។

(២)- "ក្រសួងអប់រំ យុវជន **និង**កីឡា" ( នៅលើក្របសៀវភៅសិក្សាផ្សព្វផ្សាយដោយក្រសួងអប់រំ និង នៅលើក្បាលលិខិតឧទ្ទេសនាមរបស់ក្រសួងនេះ លេខ៤៤៣៤អយក.ឧទន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ប៉ុន្តែ នៅក្នុងលិខិតដដែល គេសរសេរ "<u>រដ្ឋមន្ត្រីកសួងអប់រំ យុវជន</u> **<u>និង</u>** <u>កីឡា</u>" ត្រង់កន្លែងដែលរដ្ឋមន្ត្រីចុះហត្ថលេខា) ។

(៣)-"លោកអភិបាលក្រុងបានអះអាងបែបនេះនៅក្នុងឱកាសដែលរូបលោករួមជាមួយសហការី**និង**លោកឧត្តមសេនីយ៍ ម៉ៅ សុផាន់ (...) ទៅពិនិត្យមើលការងារបង្កបង្កើនផលស្រូវ (...) ។ (...) ទម្លាក់មកតាមប្រឡាយមេកាត់តាមសង្កាត់ពងទឹក ព្រៃវែង ប្រទះឡាង **និង**សាក់សំពៅ ដើម្បីឱ្យប្រជាកសិករបានទឹកធ្វើស្រែគ្រប់ៗគ្នា ។". ("រស្មីកម្ពុជា" ថ្ងៃអាទិត្យ. ច័ន្ទ ទី០៧-០៨ ខែសីហា ឆ្នាំ២០០៥ , ទំព័រ ក៣ ) ។

(៤)- "អ្នកជំនួញ **និង** ពលរដ្ឋគ្រប់រូបគប្បីការពារការឆបោក ក្លែងបន្លំ **និង**អំពើទុច្ចរិត". (ការផ្សាយដំណឹង ពីមន្ទីរសារការីនៃព្រះរាជាណាចក្រកម្ពុជា ចុះក្នុង "រស្មីកម្ពុជា" ថ្ងៃព្រហស្បតិ៍ ៣០ - ០៦ - ០៥ ទំព័រ ក១) ។

(៥)- "(...) សមត្ថកិច្ចរបស់លោកគ្មានលទ្ធភាព**ឬ**បទបញ្ជាពីអាជ្ញាធរខេត្តឱ្យដេញ **ឬ**ឱ្យសង្ឃទាំងនោះរុះរើខ្លោងទ្វារនោះចេញវិញឡើយ ។ (...) ", ( "រស្មីកម្ពុជា" ថ្ងៃសៅរ៍ ២០-០៨-០៥ , ទំព័រ ក១០ < ព្រះសង្ឃផ្អើលទៅចាប់ដីធ្វើវត្តនៅជើងភ្នំព្រះវិហារ. អត្ថបទរបស់ **ជាយ័ន**) ។

## ២-និន្នន័យទាក់ទងនឹងការប្រើជំណាកឃ្លា ជាមួយកម្មវេសកាលដើមល្បះ :

### ២.១-ការដាក់កម្មវេសកាលនៅដើមល្បះឱ្យជាប់នឹងប្រធាននៃល្បះ មានជាឧទាហរណ៍ខ្លះៗ ដូចខាងក្រោម :

(១) - "ទាក់ទងនឹងហេតុការណ៍ខាងលើនេះប្រភពព័ត៌មានពីអ្នកស្រុកនៅកន្លែងកើតហេតុបានឱ្យដឹងថា (...)", ("រស្មីកម្ពុជា" ថ្ងៃអង្គារ ០៩-០៨-០៥ , ទំព័រ ក៧ < ឡើងលបកូនក្រមុំគេកណ្ដាលយប់ត្រូវប៉ូលិសឃាត់ខ្លួន អត្ថបទរបស់ ពេជ្រ និល) ។

(២) - "(...) ។ បច្ចុប្បន្នស្រុកមានទំនប់ស្ទាក់ទឹកចំនួន៣កន្លែង (...)", ("រស្មីកម្ពុជា" ថ្ងៃអង្គារ ០៩-០៨-០៥ , ទំព័រ ក៣ < ខេត្តកំពង់ធំ : ធ្វើទំនប់ស្ទាក់ទឹក**និង**ផ្លាស់ប្ដូរទម្លាប់ធ្វើស្រែទើបអាចរំដោះបាននូវកង្វះខាតស្បៀង អត្ថបទរបស់ រចនា) ។

### ២.២- ដោយមានជកឃ្លា នៅចន្លោះកម្មវេសកាលនិងប្រធាននៃល្បះ :

(១) - " (...) ។ បន្ទាប់មក អ្នកបើកបរបានបើកទ្វារចុះចេញពីឡានដើរធ្វើព្រងើយត្រឡប់ទៅកន្លែងផឹកស៊ីវិញ ។ (...)", ("រស្មីកម្ពុជា" ថ្ងៃអាទិត្យ & ច័ន្ទ ទី២១ & ២២ ខែសីហា ឆ្នាំ ២០០៥ , ទំព័រ ក៦ < សែនចិនស្រវឹងយូនបើកឡានបុកកូនខ្មែររបួសធ្ងន់៥ស្រាលម្នាក់ អត្ថបទរបស់ អូភា) ។

(២) - "ឆ្នាំ២០០៤ កម្ពុជាផលិតអង្ករបាន៤លានតោន ។ (...)", ("រស្មីកម្ពុជា" ថ្ងៃអង្គារ-០៩-០៨-០៥ , ទំព័រ ក៧ < ប្រព័ន្ធទីផ្សារពាណិជ្ជកម្មនៅកម្ពុជាសាំញ៉ាំច្រើន. មតិរបស់លោក អ៊ិន ម៉ិនថា អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម ដែលគាត់បានផ្ដល់ក្នុងសិក្ខាសាលាមួយនាក្រុងព្រះសីហនុ កាលពីដើមខែកក្កដា ២០០៥, ស្រង់ដោយ "រស្មីកម្ពុជា") ។

(៣) - "(...) មុននឹងផ្ដើមការរៀបរៀង , គណៈកម្មការបានប្រឹក្សាយ៉ាងយូរ (...)", (*និទាន,* សម្រាប់ការបោះពុម្ពវចនានុក្រមខ្មែរឡើងវិញ គ្រាទី៥ ទំព័រ ក) ។

### ២.៣- ជកឃ្លា បែបសេរីនិយម :

"ថ្ងៃមុន នាយអូកា លោតកញ្ឆោញចេក (...) ។ ថ្ងៃមុនអាក្លើខ្ញុំវារកស៊ីខាងធ្វើកុននោះ វាប៉ាវលោកអ្នកអន្ទ្រើសខាងវប្បធម៌ម៉ាតុ (...)", ("រស្មីកម្ពុជា" ថ្ងៃអាទិត្យទី២១, ថ្ងៃចន្ទទី២២ ខែសីហា ឆ្នាំ២០០៥ , ទំព័រក៧< អ្នកវប្បធម៌ស្រុកយើង អត្ថបទរបស់ រ៉ូហ្សា) ។

## ៣-សញ្ញាភក្សៀស :

សញ្ញានេះត្រូវបានអ្នកប្រើប្រាស់អក្សរខ្មែរខ្លះប្រកាសមិនឱ្យប្រើ ដោយហេតុថា វាជាសញ្ញាខ្ចីពីក្រៅ ។ ចំពោះបញ្ហានេះ ខ្ញុំសុំស្រង់ល្បះមួយរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត មកពិនិត្យពិចារណាឱ្យឃើញថា តើលោកមានការភាន់ច្រឡំឬយ៉ាងណា ដ្បិតលោកបានប្រើសញ្ញានេះយ៉ាងសន្ធឹកសន្ធាប់ក្នុងវចនានុក្រមរបស់លោក ។ ប៉ុន្តែ មុននឹង

ពិនិត្យពិចារណាលើល្បះរបស់លោក ខ្ញុំសុំរំលឹកថា សញ្ញាប្រើក្នុងប្រយោគ ( ឬ សញ្ញាប្រយោគ) បង្កើតដោយបុព្វបុរសខ្មែរ មានតែមួយចំនួនតូច ដូច សញ្ញាខណ្ឌ , សញ្ញាខណ្ឌចប់ , បរិយោសាន , ដំណកឃ្លា , បេយ្យាលៈ , សញ្ញាចុចពីរគូស , ...។ រីឯសញ្ញាឯទៀតជាច្រើន ( មានចំនួនជាង២០) ជាសញ្ញាខ្ចីពីក្រៅ រួមមាន[៧] : សញ្ញាបូក, សញ្ញាសង (ដក), សញ្ញាស្មើ, អព្ភន្តរៈ, វង់ក្រចក , រ៉ាត់ , ឃ្នាប , សញ្ញាសួរ , សញ្ញាឧទាន, ព្រួញ, បន្ទាត់ទ្រេត, សញ្ញាធំជាង/ទៅជា (>), សញ្ញាតូចជាង/មកពី (<), ផ្ទុយពី/ខុសពី (≠), ស្មើរតែដូចគ្នា (#) ។ល។

## ៣.១- សម្រង់សេចក្ដីមួយល្បះរបស់សម្ដេច ជួន ណាត ដើម្បីបង្ហាញផលប្រយោជន៍នៃសញ្ញាក្បៀស :

**នេះជាល្បះដែលចំណងជើងខាងលើបានបង្ហើប :** "ក្នុងសិលាចារឹក ខ្មែរបុរាណច្រើនប្រើ រ ពេញតួ ,សម្រាប់ប្រើដាក់លើអក្សរតួចុង[៨] ដើម្បីធ្វើអក្សរតួដើមបន្ទាប់នោះឱ្យមានសូរសំឡេងញ៉ូរ , **ប្រើចំពោះតែភាសាសំស្ក្រឹតឬសំស្ក្រឹតក្លាយ**[៩] , ដូចជា គ័ភ៌ , ទុគ៌ត , ទុព៌ល , ធម៌ , បព៌ត , ព័ណ៌ , ធម៌អាចិ , ជាដើម ; ប៉ុន្តែ បើមានស្រះដែលទើសពិបាកសរសេរនោះ ត្រូវដាក់អក្សរ រ ពេញតួពីលើជើងអក្សរខាងចុងវិញ , ដូចជា ទុរ្ភិក្ស , មូរ្តិ , រាមកេរ្តិ៍, តិរ្ថិយ[១០] , អន្យតិរ្ថិយ ជាដើម ; ចួនកាលមិនមានស្រះទើសទែងទេ ប៉ុន្តែគួរឱ្យច្រឡំពិបាកអាន ក៏ត្រូវដាក់តួ រ លើជើងអក្សរខាងចុងបានដែរ, ដូចជា កម៌និ , អស្ចារ្យ៌ , អាចារ្យ៌ , ប្រើជា ក្ស៊ែន , អស្ចារ្យ , អាចារ្យ ជាដើម ( ប្រើសម្រួលឱ្យងាយមើល ងាយថា) ។ បើមានអក្សរ រ ជាតួប្រកបពីខាងចុង , នឹងប្រើជារបាទ (រេផៈ) នេះផងពុំ បានឡើយ , ដូចជា ជ័រ , ដើមសង្ស័រ , ញ៉័រ, ទទ័រ ជាដើម ( សរសេរយ៉ាងនេះត្រឹមត្រូវហើយ) កុំសរសេរជា ជ័រ៌ ,... ទទ័រ៌ ឬក៏ ជារ៌ ,... ទទារ៌ ដូច្នេះឡើយ"[១១] ។

## ៣.២- ការវិភាគពិចារណា :

សម្ដេចព្រះសង្ឃរាជ ជួន ណាត ប្រាកដជាបានពិចារណាច្រើនលើបញ្ហាអក្សរសាស្ត្រខ្មែរ, លោកប្រាកដជាបានឈ្វេងយល់ថា ខ្មែរបានខ្ចីសញ្ញាប្រយោគពីក្រៅជាច្រើន ដូច្នេះហើយ លោកឥតមានគំនិតចង្អៀតចង្អល់ទេ លោកបានប្រើសញ្ញាក្បៀសជាច្រើន ។

បើលោកមិនប្រើសញ្ញានេះនៅកន្លែងខ្លះ ហើយ ប្រើតែដំណកឃ្លា ដូចអ្នកខ្លះគេចង់បាននោះ លោកក៏អាចធ្វើបានដែរ ប៉ុន្តែ បញ្ញាញាណរបស់យើងមិនអាចមិនទទួលស្គាល់ថា ល្បះរបស់លោក ( ដែលក្នុងនោះមានប្រើសញ្ញាក្បៀស) មានភាពច្បាស់ជាងការប្រើតែដំណកឃ្លាសុទ្ធនោះទេ ។ ម្យ៉ាងទៀត ចំពោះកន្សោម " ប្រើចំពោះតែភាសាសំស្ក្រឹតឬ

---

[៧] - គេអាចមានមតិថា គេឥតត្រូវការសញ្ញាយ៉ាងសន្ធឹកសន្ធាប់ទាំងនោះទេ ប៉ុន្តែ គប្បីយើងទទួលស្គាល់ថា អ្នកស្រាវជ្រាវជាន់ខ្ពស់ដែលមានការចាំបាច់ច្រើន ចៀសសញ្ញាទាំងនោះមិនផុតទេ ។

[៨] - ដោយយើងគ្មានលទ្ធភាពដាក់អក្សរ រ ពេញតួលើតួអក្សរឯទៀត សូមសាធារណជនជ្រាបថា គឺនៅកន្លែងដែលមានសញ្ញារបាទនេះហើយ ដែលខ្មែរបុរាណដាក់អក្សរ រ ពេញតួ ។

[៩] - បន្ទាត់គូសខាងក្រោមកន្សោមពាក្យ ដូចមានមកនេះ ត្រូវបានធ្វើឡើងពីសំណាក់ម្ចាស់សិក្សាកថា ដើម្បីទាញអារម្មណ៍លើភាពចាំបាច់នៃការប្រើសញ្ញាក្បៀស ។

[១០] - អ្នកនិពន្ធមួយចំនួន បានប្រើសញ្ញាក្បៀស ( ដូចសម្ដេច ជួន ណាត ដែរ) មាន អ្នកវេយ្យាករណ៍ អ៊ុយ ជួន ជាដើម ។

[១១] - សូមមើលពាក្យ "របាទ" ក្នុងវចនានុក្រមខ្មែរ ( វ.ឯ.ម) ។

សំស្រ្តីតក្លាយ" គេមិនអាចប្រើតែដំណាកឃ្លាបានទេ បើពុំនោះសោត ល្បះត្រូវមានភាពសាំញ៉ាំមិនខាន : បើគេមិនប្រើសញ្ញាក្បៀសគេក៏ត្រូវប្រើវង់ក្រចកដែរ ហើយ វង់ក្រចកក៏ជាសញ្ញាខ្ចីពីក្រៅមកដែរ ។

៣.៣- ការប្រើសញ្ញាក្បៀសដោយអ្នកនិពន្ធផ្សេងទៀត :

ទោះបីអ្នកខ្លះខំឃាត់មិនឱ្យគេប្រើសញ្ញាក្បៀសយ៉ាងណាក្តី ក៏នៅតែមានអ្នកខ្លះទៀតប្រើសញ្ញាក្បៀសជាហូរហែ.

ឧ.១- កាសែតរស្មីកម្ពុជា មានកិត្តិយសសូមជម្រាបជូនអតិថិជន ដែលជាវកាសែតរស្មីកម្ពុជា ជាប្រចាំតាមគេហដ្ឋាន, ក្រសួង, មន្ទីរ, ស្ថាប័ន, អង្គការនិងក្រុមហ៊ុននានា ឱ្យបានជ្រាបថា (...) , ("រស្មីកម្ពុជា" ថ្ងៃសុក្រ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០),

ឧ.២- ពាក្យដែលជានិបាតស័ព្ទ ដូចពាក្យថា : ផង, ក្តី, ក៏ដោយ, ដែរ, ទោះ, (...) ជាដើម ហៅថា "អលិង្គ" ។ (អ៊ុយ ជូន, វេយ្យាករណ៍ពិសេស, ទំព័រ ១១៣, រោងពុម្ព គីម គី បណ្ណាគារ, លេខ ៤៤ វិថីតេជោ-ដំឌិន, ភ្នំពេញ ឆ្នាំ១៩៥៨) ។

## ៤- <u>បញ្ញត្តិមូលដ្ឋានចាំបាច់ និង សេចក្តីសន្និដ្ឋានបណ្តើរៗ</u> :

### ៤.១- អំពីឃ្លា :

ចំពោះពាក្យ "ឃ្លា" វចនានុក្រមខ្មែរបានពន្យល់ដូចនេះ[១២] : "**ល្បះ**[១៣] ពាក្យ , ល្បះសេចក្តី ដែលមានទំនងត្រូវដកឱ្យដាច់ ឱ្យឃ្លាត : សេចក្តីមួយឃ្លា, មើលកាព្យឱ្យដឹងឃ្លា, សរសេរដកឃ្លា" ។ អត្ថន័យបង្កប់ក្នុង "<u>សេចក្តីមួយឃ្លា</u>" និង "<u>សរសេរដកឃ្លា</u>" នេះ ជាមូលដ្ឋានសម្រាប់ឱ្យយើងនាំគ្នាសរសេរដកឃ្លា នៅពេលបច្ចុប្បន្ន *ប៉ុន្តែ "<u>សេចក្តីមួយឃ្លា</u>"[១៤] ជាបញ្ញត្តិឥតមូលដ្ឋានវត្ថុវិស័យ (sans fondement objectif ) អាស្រ័យហេតុនេះ យើងប្រើដំណាកឃ្លាផ្សេងៗគ្នា ។*

### ៤.២- អំពីឈ្នាប់ :

គួររំលឹកថាឈ្នាប់មានពីរក្រុម គឺ ឈ្នាប់ចង (conjonction de coordination) និង ឈ្នាប់រណប/ឈ្នាប់ឃ្លា (conjonction de subordination ):

- ឈ្នាប់ចង មាន : *និង , ហើយ , ឬ , ប៉ុន្តែ ....*
- ឈ្នាប់រណប/ឈ្នាប់ឃ្លា មាន : *ពីព្រោះ , បើ /ប្រសិនបើ /បើសិនណា , ក្រោយពី , មុននឹង, ...* ។

**ឈ្នាប់ចង និង ឈ្នាប់រណប មានលក្ខណៈសម្ព័ន្ធប្លែកគ្នា, ឧទាហរណ៍ :**

---

[១២] - សូមកុំច្រឡំ "ដូចនេះ" និង "ដូច្នេះ" ។

[១៣] - "ល្បះ (លែងប្រើហើយ) មើលក្នុងពាក្យរបះ *ន.* និង *កិ* ផង" ។ "របះ *ន.* ការរះឱ្យមានឃ្លា ។ ឈ្មោះវណ្ណយុត្តិមួយប្រភេទមានរូបសញ្ញាបែបនេះ (។ ) សម្រាប់រះខណ្ឌឃ្លាក្នុងប្រយោគវែងខ្ចីទីមួយៗ" វចនានុក្រមខ្មែរដោយសម្តេច ជួន ណាត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥, ១៩៦៧ ។ **ប៉ុន្តែ ពាក្យ "ប្រយោគ" ត្រូវបានគេជំនួសដោយពាក្យ "ល្បះ" (ពាក្យ "ប្រយោគ" ឬ "ល្បះ" ត្រូវនឹងពាក្យបារាំង** phrase **និង ពាក្យអង់គ្លេស** sentence) ។

[១៤] - គំនូសគូសពីក្រោមជាទង្វើរបស់អ្នកនិពន្ធសិក្សាកថានេះ ។

(១) - <u>ជាមួយឈ្នាប់ចង</u> : កន្សោមពាក្យពីរ/ល្បះពីរ ភ្ជាប់ដោយឈ្នាប់ចង " និង, ហើយ, ឬ, ..."

បើយើងចាត់ទុក *ឈ្នាប់ចង* ថាជាចំណែករបស់កន្សោមពាក្យទី២ ( ឬល្បះទី២) ដូចនេះ :

**(១.១.ក ) - "(...)ពីអង្គការក្រៅរដ្ឋាភិបាលជាតិ <u>និង</u>ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ "** ,

ការប្តូរទីតាំងរវាងកន្សោមពាក្យទាំងពីរបំផ្លាញវេយ្យាករណភាពនៃសេចក្តីដើម ដូចខាងក្រោម :

**(១.២.ក) - " * <u>និង</u>ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ពីអង្គការក្រៅរដ្ឋាភិបាលជាតិ "** ។

ប៉ុន្តែ បើយើង<u>មិន</u>ចាត់ទុក *ឈ្នាប់ចង* ថាជាចំណែករបស់កន្សោមពាក្យទី២ ( ឬ ល្បះទី២) ដូចនេះ :

**(១.១.ខ) - "ពីអង្គការក្រៅរដ្ឋាភិបាលជាតិ <u>និង</u> ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ "**, ការប្តូរទីតាំងរវាងកន្សោមពាក្យទាំងពីរ<u>មិន</u>បំផ្លាញវេយ្យាករណភាពនៃសេចក្តីដើមទេ ដូចខាងក្រោម :

**(១.២.ខ) - "ពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ <u>និង</u> ពីអង្គការក្រៅរដ្ឋាភិបាលជាតិ "** ។

(២) - <u>ជាមួយឈ្នាប់រណប</u> :

ល្បះល្បាយ/ល្បះផ្សំពីរខាងក្រោម ( ក្រោយពីមានការប្តូរទីតាំងរវាងល្បះទោលទាំងពីរដែលជាធាតុផ្សំនៃល្បះល្បាយ) ជាល្បះត្រឹមត្រូវដូចគ្នា :

**(២.១) - ខ្ញុំខានមកធ្វើការអស់បីថ្ងៃ ពីព្រោះខ្ញុំឈឺ** ,

**(២.២) - ពីព្រោះខ្ញុំឈឺ ខ្ញុំខានមកធ្វើការអស់បីថ្ងៃ** ។

<u>សង្កេត</u> :

(១) - ឈ្នាប់ចងមាននុខងារជាចំណងសម្រាប់ចងពាក្យពីរម៉ាត់, កន្សោមពាក្យពីរកន្សោម, ល្បះពីរឬច្រើន ដែលមានប្រភេទដូចគ្នា។ ពាក្យ/កន្សោមពាក្យនិងល្បះទាំងនោះ ឥតនៅក្រោមនិវាទនៃឈ្នាប់ចងទេ។ ចំណងគ្រាន់តែចង : ចងឱ្យតឹង (គ្មានដំណកឃ្លា) ចងធូរៗ (ដកឃ្លាខាងឆ្វេងផងខាងស្តាំផង)។

(២) - ឈ្នាប់រណប ដែលមិនមែនជាចំណង ជាចំណែកមួយរបស់ល្បះរណប : ដូច្នេះ[១៥] វាត្រូវនៅជាប់នឹងល្បះរណប។

## ៤.៣- សម្ព័ន្ធវិទ្យារបស់ លោក ណូអាម ឆុមស្គី ( Noam Chomsky).

សម្ព័ន្ធវិទូដ៏ល្បីល្បាញឈ្មោះ ណូអាម ឆុមស្គី បានសិក្សាអំពីសម្ព័ន្ធ ដោយបង្ហាញឋានានុក្រមនិងទំនាក់ទំនងរវាងចំណែកនីមួយៗនៃល្បះយ៉ាងល្អិតល្អន់ ចាប់ពីកន្សោមធំៗដែលជាកន្សោមច្បង រហូតដល់កន្សោមបន្តបន្ទាប់ ។ គាត់តាងល្បះជារូបមន្តដូចនេះ :

**ល្បះ ⟶ កន្សោមនាមប្រធានល្បះ +[១៦] កន្សោមកិរិយាប្រណាប់ប្រធាន[១៧] + (កន្សោមធ្លាក់)**

<u>កំណត់សម្គាល់</u> : វេយ្យាករណ៍លោក ណូអាម ឆុមស្គី ហៅជាភាសាបារាំងថា Grammaire Générative et Transformationnelle បានវិភាគឃើញ :

⌒

[១៥] - សូមកុំច្រឡំ "ដូច្នេះ" និង "ដូចនេះ" ។

[១៦] - អ្នកខ្លះបានបញ្ចេញមតិថា ការប្រើសញ្ញា (+) មិនត្រឹមត្រូវទេ គប្បីប្រើសញ្ញា (  )វិញទើបត្រឹមត្រូវ ។

[១៧] - អ្នកខ្លះប្រើពាក្យ "បម្រាប់ប្រធាន" ។ ពាក្យ "បម្រាប់" មានន័យថា "ការប្រាប់" ឬ "លទ្ធផលនៃការប្រាប់" ។ រីឯពាក្យ "ប្រណាប់ប្រធាន" បង្កើតឡើងតាមគំរូ "ទ្រាប់ > ទ្រនាប់" ។ ទ្រនាប់គឺជាឧបករណ៍សម្រាប់ទ្រាប់ ដូច្នេះ "ប្រណាប់ប្រធាន" គឺជាឧបករណ៍ដែលប្រាប់ប្រធាន ។

- កន្សោមនាមដែលផ្អែកលើនាម,
- កន្សោមកិរិយាដែលផ្អែកលើកិរិយាសព្ទ,
- កន្សោមគុណនាមដែលផ្អែកលើគុណនាម,
- កន្សោមគុណកិរិយាដែលផ្អែកលើគុណកិរិយា,
- កន្សោមធ្នាក់ដែលផ្អែកលើធ្នាក់,

ប៉ុន្តែ គាត់ឥតបានវិភាគឃើញមាន*កន្សោមឈ្នាប់ទេ ពីព្រោះ :

- ឈ្នាប់ចង ជាចំណងសម្រាប់ចងពាក្យ/កន្សោមពាក្យ/ល្បះ ពីរឬច្រើនឱ្យជាប់គ្នា ,
- ឈ្នាប់រណប ជាឈ្នាប់សម្រាប់បង្កើតល្បះរណបដែលមិនមែនជាកន្សោមធម្មតាទេ :
  ឈ្នាប់រណបជាចំណែកមួយនៃល្បះរណប វាត្រូវនៅជាប់នឹងល្បះរណប ។

នៅក្នុងប្រណាប់ប្រធានក៏មានកន្សោមធ្នាក់ដែរ ប៉ុន្តែ កន្សោមនោះជាកន្សោមធ្នាក់ក្រោមឱវាទផ្ទាល់នៃកិរិយាសព្ទនៃប្រណាប់ប្រធាន (ឧ. ម្សិលមិញ ខ្ញុំបានជួបប្រធាននៃតុលាការកំពូល) រីឯកន្សោមធ្នាក់ ដែលនៅក្រៅប្រណាប់ប្រធានវិញ ជាកន្សោមឯករាជ្យ ហើយ គេប្រើវង់ក្រចកក្នុងន័យសន្មតថា "កន្សោមមិនចាំបាច់សម្រាប់វេយ្យាករណភាពនៃល្បះ" : បើគេប្រើវា គឺដើម្បីសេចក្ដីត្រូវការក្នុងការសម្ដែងមតិ, ឧ. ខ្ញុំដើរ តាមផ្លូវលំ ជាមួយមិត្តម្នាក់ ,... ("ខ្ញុំដើរ" មានលក្ខណៈគ្រប់គ្រាន់សម្រាប់វេយ្យាករណភាពនៃល្បះទៅហើយ . រីឯកន្សោមធ្នាក់ "តាមផ្លូវលំ ជាមួយមិត្តម្នាក់ ...." , វាគ្រាន់តែជាកន្សោមសម្រាប់ផ្ដល់ព័ត៌មាន ដើម្បីបង្គ្រប់សេចក្ដីដែលអ្នកនិយាយចង់បង្ហាញតែប៉ុណ្ណោះ) ។

បើយើងផ្អែកលើកន្សោម យើងមានមូលដ្ឋានវត្ថុវិស័យ (base objective) ដើម្បីដកឃ្លា : ដកឃ្លាខាងចុងកន្សោមនាមប្រធាននៃល្បះ ដកឃ្លាខាងចុងកន្សោមកិរិយាប្រណាប់ប្រធាននៃល្បះ, ... (បើកន្សោមទាំងនោះវាមិនខ្លីពេក), ឧទាហរណ៍ : "(...) លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំឱ្យអាត្មាជួយរៀបចំបន្ថែម (...)", (*និវេទនកថា* សម្រាប់ការបោះពុម្ពវចនានុក្រមខ្មែរឡើងវិញ គ្រាទី៥ , ទំព័រ ជ) ។

## ៤.៤- អំពីកត្តារួម :

ម្យ៉ាងទៀត ភាសាវិទ្យាបច្ចុប្បន្នបានយកគណិតវិទ្យានិងរូបវិទ្យាធ្វើជាគំរូ ហើយ បានខ្ចីវិធីមួយចំនួនពីវិទ្យាសាស្ត្រជាក់[១៨] ទាំងពីរនេះ ដូចជា អាគូស្ទិក (acoustique) , ដំណាក់កត្តារួម (mise en facteur commun) ចតុត្ថសមាមាត្រ[១៩] (quatrième proportionnelle) , ជាដើម ។ ក្នុងសម្ព័ន្ធ គេប្រើដំណាក់កត្តារួមជាញឹកញាប់ ។

[១៨] - គេច្រើនហៅវិទ្យាសាស្ត្រទាំងពីរនេះ (គណិតវិទ្យានិងរូបវិទ្យា) ថា ជាវិទ្យាសាស្ត្រពិត ដូច្នេះ វិទ្យាសាស្ត្រឯទៀតៗ (ដូច វិទ្យាសាស្ត្រសេដ្ឋកិច្ច , វិទ្យាសាស្ត្រនយោបាយ , ភូមិវិទ្យា , ប្រវត្តិវិទ្យា , ភាសាវិទ្យា , ... ) ជាវិទ្យាសាស្ត្រមិនពិត ជាវិទ្យាសាស្ត្រក្លែងក្លាយ ។ ដើម្បីចៀសបញ្ហាដែលអាចចោទឡើងបែបនេះ ខ្ញុំសុំប្រើកន្សោមពាក្យ "វិទ្យាសាស្ត្រជាក់" ជំនួស "វិទ្យាសាស្ត្រពិត" វិញ ។

ចំពោះការបែងចែកថា មុខវិជ្ជាណាជា science និង មុខវិជ្ជាណាមិនមែនជា science, គួររំលឹកថា លោក កេង វ៉ាន់សាក់ បានបញ្ចេញមតិថា មុខវិជ្ជាណាដែលមាន "សាស្ត្រ" នៅខាងចុងមិនមែនជា science ទេ ។ បើចង់បង្ហាញថា វិជ្ជាណាមួយជា science គេត្រូវដាក់ "វិទ្យា" ខាងចុង ។ ខ្ញុំបានសួរគាត់ថា "ចុះវិទ្យាសាស្ត្រ" ដែលមាន "សាស្ត្រ" នៅខាងចុង មិនមែនជា science ទេឬ ? ឬក៏ ត្រូវដាក់ថា "វិទ្យាវិទ្យា" វិញ ? ។ គាត់ឆ្លើយមិនរួច ប៉ុន្តែ ក្រោយមក សិស្សគាត់ ដែលមានឱកាសកាន់ការធំៗក្នុងគណៈកម្មាធិការជាតិខេមរយានកម្ម បានដូរ "ភូមិសាស្ត្រ" ឱ្យទៅជា "ភូមិវិទ្យា" . "គណិតសាស្ត្រ" ឱ្យទៅជា "គណិតវិទ្យា" ។ ល ។ ដោយ "វិទ្យាសាស្ត្រ" ត្រូវគេទុកឱ្យមាន "សាស្ត្រ" នៅខាងចុងដដែល មុខវិជ្ជាណា ដែលមាន "សាស្ត្រ" នៅខាងចុងដូច "វិទ្យាសាស្ត្រ" ទើបជា science ដូច្នេះ បំណងរបស់លោក កេង វ៉ាន់សាក់ មិនបានសម្រេចឡើយ ។

[១៩] - ពាក្យ "ចតុត្ថសមាមាត្រ" ជាវាក្យសព្ទខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ & ចាវ គន្ធ បណ្ណាគារ ចិត ឆាច .

ដើម្បីជាការរំលឹកឡើងវិញ ខ្ញុំសុំលើកយកដំណាក់កត្តារូមសាមញ្ញមួយមកពិនិត្យ គឺ a ( b + c )។ ដោយ a ជាកត្តារូមរបស់ b ផងនិងរបស់ c ផង គេត្រូវប្រើវង់ក្រចកដើម្បីកុំឱ្យ a ជាប់នឹង b តែម្នាក់ឯង : បើគេសរសេរ ab + c , a ជារបស់ b ម្នាក់ឯង វាមិនមែនជារបស់ c ផងទេ។

ក្នុងសម្ព័ន្ធ ក៏ដូចគ្នានេះដែរ គេមិនត្រូវដាក់កត្តារូមសម្រាប់កន្សោមពីរឱ្យជាប់នឹងកន្សោមណាមួយតែម្នាក់ឯងនោះទេ។ ល្បះខាងមុខនេះ ជាល្បះមិនត្រូវតាមវិធីកត្តារូមទេ : *លោកគ្រូ អ្នកគ្រូនៃសាលាស្វាយធំ បានប្រាប់ខ្ញុំថា ,(...) ពីព្រោះកន្សោមផ្ទាក់ "នៃសាលាស្វាយធំ " ដែលជាកត្តារូមរបស់ "លោកគ្រូ" ផង និង របស់ "អ្នកគ្រូ" ផងនោះ ត្រូវបានគេប្រគល់ឱ្យទៅអ្នកគ្រូតែម្នាក់ឯង ។

## III- __សេចក្ដីសន្និដ្ឋាន__ :

### ១- __ការប្រើដំណកឃ្លាជាមួយឈ្នាប់ចង__ :

ដោយផ្អែកលើទឡ្ហីករណ៍វត្ថុវិស័យ[២០] (argument objectif) និង ប្រើនិទស្សន៍[២១] (démonstration) ជាច្រើន ខ្ញុំបានបង្ហាញឱ្យឃើញថា ដោយឈ្នាប់ចងជាចំណងដាច់ឡែកពីពាក្យ/កន្សោមពាក្យ/ល្បះដែលគេចងភ្ជាប់គ្នានោះ គេមិនត្រូវចាត់ទុកវាថា ជាចំណែកមួយនៃពាក្យ/កន្សោមពាក្យ/ល្បះខាងស្ដាំឡើយ : ដូច្នេះ ការប្រើដំណកឃ្លាតែខាងឆ្វេងនៃឈ្នាប់ចង ដោយភ្ជាប់ឈ្នាប់នេះទៅនឹងពាក្យ/កន្សោមពាក្យ/ល្បះដែលនៅខាងស្ដាំនោះ ជាការប្រើប្រាស់មិនស្របតាមសម្ព័ន្ធវិទ្យាទេ។

**ការប្រើដំណកឃ្លាជាមួយឈ្នាប់ចង មានពីរករណី ៈ**

__ករណីទី__ ១ : ឈ្នាប់ចងមិនតម្រូវឱ្យមានដំណកឃ្លាទេ ប៉ុន្តែ បើគេចង់ទាញអារម្មណ៍លើភាគទាំងពីរភ្ជាប់ដោយឈ្នាប់នេះ គេអាចដកឃ្លាបាន ( គ្មានកំហុសផ្នែកសម្ព័ន្ធវិទ្យាទេ ឱ្យតែគេចៀសកំហុសដែលទើបត្រូវបានបង្ហាញខាងលើ) :

- __ការប្រើឈ្នាប់ចងដោយឥតដកឃ្លា__ :

ឧ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ,

- __ការប្រើឈ្នាប់ចងដោយមានដកឃ្លា__ :

ឧ. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

__ករណីទី__ ២ : ឈ្នាប់ចងតម្រូវឱ្យមានដំណកឃ្លា ពីព្រោះដំណកឃ្លាមានប្រើក្នុងកន្សោមឬល្បះស្រាប់ ( មុនមកដល់ឈ្នាប់) :

ឧ. ក្រសួងអប់រំ យុវជន និង កីឡា[២២] ។

### ២- __កម្រេចសភាពដើមល្បះ__ :

---

ភ្នំពេញ . ១៩៦៤ ( សូមមើលពាក្យ "proportionnel" ) ។

[២០] - ពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ (ដ.ឯ.ម.) ។

[២១] - ពាក្យខ្ចីពីវចនានុក្រមបារាំង-ខ្មែរ (ដ.ឯ.ម.) ។

[២២] - ការដាក់ឱ្យ " និង " នៅជាប់នឹង " កីឡា " ជាការប្រើប្រាស់មិនស្របតាមសម្ព័ន្ធវិទ្យាទេ ។

កម្មទេសកាលដើមល្បះជាកន្សោមមួយ គឺជាកន្សោមធ្លាក់ ( ក្នុងករណីតិចតួចមួយចំនួន គេមិនប្រើធ្លាក់ទេ ដូច : *ម្សិលមិញ, ថ្ងៃស្អែក ....*) ក្នុងករណីនៃកម្មទេសកាលដើមល្បះនេះ គេត្រូវប្រើដំណកឃ្លាជាដាច់ខាត ហើយ សម្ដេចព្រះសង្ឃរាជ ជួន ណាត និយមប្រើសញ្ញាក្បៀសថែមទៀតផង :

ឧ. "(...) <u>មុននឹងផ្ដើមការរៀបរៀង</u>, គណៈកម្មការបានប្រឹក្សាយ៉ាងយូរ (...)", ( *និទាន*, សម្រាប់ការបោះពុម្ពវចនានុក្រមខ្មែរឡើងវិញ គ្រាទី៥ ទំព័រ ក) ។

៣-<u>សញ្ញាក្បៀស</u> :

ក្នុងករណីខ្លះ សញ្ញាក្បៀសមានប្រយោជន៍ជួយឱ្យល្បះកាន់តែច្បាស់ ( ដូចឧទាហរណ៍ខាងលើ) ឬ ជាការចាំបាច់ ( ដូចឧទាហរណ៍នៃចំណុច ១-៣.១- ស្ដីពី " **ទិន្នន័យទាក់ទងនិងដំណកឃ្លាជាចួយឈ្នាប់ចង** ") ។

៤-<u>កត្តារួម</u> :

- **កត្តារួមអាចនៅខាងដើមនៃកន្សោមពាក្យ.**

ឧ. កម្លាំងកាយ កម្លាំងចិត្ត > <u>កម្លាំង</u>កាយចិត្ត ( ការសរសេរ "កម្លាំងកាយ ចិត្ត" បែបនេះមិនស្របតាមសម្ព័ន្ធវិទ្យាទេ ពីព្រោះ "កម្លាំង" ត្រូវបានប្រគល់ឱ្យ "កាយ" តែម្នាក់ឯង) ។

- **កត្តារួមក៏អាចនៅខាងចុងនៃកន្សោមពាក្យដែរ.**

ឧ.១- "ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង > ឃុំ ស្រុក ខេត្ត <u>ស្វាយរៀង</u>" ( គប្បីកុំដាក់ "ស្វាយរៀង " ឱ្យជាប់នឹង "ខេត្ត" ដើម្បីចៀសការប្រគល់ "ស្វាយរៀង" ឱ្យទៅ "ខេត្ត" តែម្នាក់ឯង).

ឧ.២- "កាសែតរស្មីកម្ពុជា មានកិត្តិយសសូមជម្រាបជូនអតិថិជន ដែលជាវកាសែតរស្មីកម្ពុជា ជាប្រចាំតាមគេហដ្ឋាន, ក្រសួង, មន្ទីរ, ស្ថាប័ន, អង្គការនិងក្រុមហ៊ុននានា[២៣] <u>ឱ្យបានជ្រាបថា</u> (...)". ( "រស្មីកម្ពុជា" ថ្ងៃសុក្រ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០)។

ឧ.៣- "ឈ្នាប់ចង **និង** ឈ្នាប់រណប <u>មានលក្ខណៈសម្ព័ន្ធប្លែកគ្នា</u>" ឬ " ឈ្នាប់ចង**និង**ឈ្នាប់រណប<u>មានលក្ខណៈសម្ព័ន្ធប្លែកគ្នា</u>" ប៉ុន្តែ ការសរសេរបែបនេះវិញ : "ឈ្នាប់ចង **និង** ឈ្នាប់រណប<u>មានលក្ខណៈសម្ព័ន្ធប្លែកគ្នា</u>"[២៤] មិនស្របតាមសម្ព័ន្ធវិទ្យាទេ ពីព្រោះកត្តារួម "<u>មានលក្ខណៈសម្ព័ន្ធប្លែកគ្នា</u>" ត្រូវបានប្រគល់ឱ្យ "ឈ្នាប់រណប" តែម្នាក់ឯង ។

---

[២៣] - ក្នុងល្បះដើមឥតមានដកឃ្លាខាងស្ដាំ "នានា" ទេ ប៉ុន្តែ ដោយខ្ញុំចង់កែតម្រូវការប្រើកត្តារួមឱ្យស្របតាមសម្ព័ន្ធវិទ្យា ខ្ញុំក៏សុំដកឃ្លាត្រង់កន្លែងនេះ ( សូមម្ចាស់អត្ថបទមេត្តាអនុគ្រោះដល់ខ្ញុំ) ។

[២៤] - សូមពិនិត្យការប្រើដំណកឃ្លាក្នុងបែបទាំង៣នៃ ឧ.៣ ( ដំណកឃ្លាត្រឹមត្រូវក្នុងបែបទី១និងទី២, ដំណកឃ្លាមិនត្រឹមត្រូវក្នុងបែបទី៣) ។

# គន្ថនិទ្ទេសសង្ខេប


## ស្នាដៃមូលដ្ឋាន :

- Chomsky Noam, La nouvelle syntaxe, Editions du Seuil, Paris 1987,
- Chomsky Noam, Aspects de la théorie syntaxique, Editions du Seuil, Paris 1971,
- Chomsky Noam, Structures syntaxiques, Editions du Point, Paris 1969,
- Gross Maurice, Grammaire transformationnelle du français : syntaxe du nom, Larousse 1977,
- Gross Maurice, Méthodes en syntaxe, Hermann 1975,
- Gross Maurice, Grammaire transformationnelle du français : syntaxe du verbe, Larousse 1968,
- Pottier Bernard, Introduction à l'étude des structures grammaticales fondamentales, Publication de la FLSH de Nancy 1969.

## ជាស្នាដៃមូលដ្ឋានផង & ជាឯកសារសម្រាប់ស្រង់ឧទាហរណ៍ផង :

(សម្ដេច) ជួន ណាត (ក្រោមការដឹកនាំ), វចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៧។

## ឯកសារសម្រាប់ស្រង់ឧទាហរណ៍ :

- សុន្ទរកថារបស់សម្ដេចតេជោ ហ៊ុន សែន ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទី១ នីតិកាល ទី៤ នៃរដ្ឋសភា បោះពុម្ពផ្សាយក្នុង "យុទ្ធសាស្ត្រចតុកោណ" នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨) ។
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គឹម សេង ភ្នំពេញ . ១៩៥៨ ;
- រស្មីកម្ពុជា . សារព័ត៌មានប្រចាំថ្ងៃ ភ្នំពេញ (ខែកក្កដា &ខែសីហា ឆ្នាំ២០០៥) ;
- លិខិតរដ្ឋបាលនៃក្រសួងនិងស្ថាប័នមួយចំនួន។

# អំពីគុណនាមក្នុងភាសាខ្មែរបច្ចុប្បន្ន

ដោយបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ សាស្ត្រាចារ្យភាសាវិទ្យា
និង ដោយលោក ប៊ី សុខគង់ អ្នកស្រាវជ្រាវ ផ្នែកភាសាវិទ្យា
នៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា[១]

តាមប្រវត្តិនៃការសិក្សាអំពីភាសា យើងបានដឹងថា *គុណនាម* គឺជាប្រភេទពាក្យមួយដែលគេបានស្គាល់តាំងពីយូរយារណាស់មកហើយសម្រាប់ភាសាអឺរ៉ុប គឺតាំងពីសម័យកាលមុនគ្រិស្តសករាជមកម្លេះ។ នៅសម័យកាលក្រិកបុរាណ, លោកអារីស្តូត (៣៨៤-៣២២ មុន គ.ស) បានបន្តគំនិតពីលោកប្លាតុង (៤២៨-៣៤៨ មុន គ.ស) ទាក់ទងនឹងការពិចារណាអំពីភាសា ដែលក្នុងនោះលោកអារីស្តូតបានបន្ថែមប្រភេទពាក្យមួយទៀត គឺ *គុណនាម* ទៅលើពាក្យពីរប្រភេទ គឺ *នាមសព្ទ* និង *កិរិយាសព្ទ* ដែលលោកប្លាតុងបានពិចារណារកឃើញ។

នៅក្នុងការសិក្សាស្រាវជ្រាវអំពីភាសាខ្មែរ អ្នកស្រាវជ្រាវខ្លះបានបញ្ចេញមតិថា ភាសាខ្មែរឥតមានគុណនាមទេ[២] ឯអ្នកស្រាវជ្រាវខ្លះទៀត គេហាក់ដូចជានៅស្ទាក់ស្ទើរក្នុងការបែងចែករវាងគុណនាមនិងនាមសព្ទ , រវាងគុណនាមនិងកិរិយាសព្ទ[៣]។

តាមរយៈអត្ថបទនេះ ទោះបីក្នុងចំណងជើងមានតែពាក្យ "គុណនាម" ក្នុងន័យទូលាយក្តី យើងនឹងផ្តោតការសិក្សាពិចារណារបស់យើងជាពិសេសទៅលើ "គុណនាមប្រក្រតី" ដែលអ្នកស្រាវជ្រាវមិនទាន់យល់ដូចគ្នានៅឡើយ។

## ១- អ្វីជាគុណនាម[៤]

### ១.១- ពិនិត្យនិយមន័យមួយចំនួនដែលមានកន្លងមក :

អ្នកនិពន្ធ ពូវ អ៊ុម បានសរសេរថា "ពាក្យដែលសំដែងលក្ខណៈរបស់នាមឬធ្វើនាមឱ្យមាន**បទ** ដូចពាក្យថា : ថ្មរឹង - មនុស្សចាស់ - ដែកស្និត (...) រឹង ចាស់ ស្និត ស្រួយ ប្រាប់លក្ខណៈ ថ្ម - មនុស្ស - ដែក (...) ហៅថាគុណនាម។ នាមនាមមានលក្ខណៈសម្រេចហើយហៅថា **គុណបទ**។ គុណនាមមានបីយ៉ាងគឺ បកតិគុណនាម១, វិសេសគុណនាម១, អតិវិសេសគុណនាម១"[៥]។

---

[១]- សិក្សាកថានេះជាលទ្ធផលនៃការកែសម្រួលនិងការបញ្ចូលគំនិតថ្មីមួយចំនួនធំ ដោយបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ ក្នុងអត្ថបទដើមរបស់លោក ប៊ី សុខគង់ ចុះផ្សាយក្នុងទស្សនាវដ្តីនៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា លេខពិសេស ខែកក្កដា ឆ្នាំ២០០៨។

[២]- មតិនេះសំដៅលើ "គុណនាមប្រក្រតី"។

[៣]- មតិអវិជ្ជមានឬស្ទាក់ស្ទើរលើអត្ថិភាពនៃគុណនាមប្រក្រតីជាមតិអ្នកស្រាវជ្រាវជំនាន់ក្រោយ រីឯអ្នកវេយ្យាករណ៍ជំនាន់មុន មានលោក ពូវ អ៊ុម លោក ខ្សៀវ ជុំ លោក អ៊ុយ ជូន ជាដើម លោកមិនដែលស្ទាក់ស្ទើរទេ ហើយ មិនដែលច្រឡំគុណនាមដែលជាគុណបទ (épithète) របស់នាមសព្ទជាមួយនឹងនាមសព្ទឬកិរិយាសព្ទដែលជាកម្មរបស់នាមសព្ទនោះឡើយ ពីព្រោះ លោកបានបញ្ជាក់ថាគុណនាមអាចដាក់ទៅជាវិសេសគុណ (ឧ.ធំជាង, តូចជាង....) និងជាអតិវិសេសគុណនាម (ឧ.ធំណាស់ ធំពេក....)។

[៤]- គឺ គុណនាមប្រក្រតី។

[៥]- ពូវ អ៊ុម : ***វេយ្យាករណ៍ខ្មែរ*** .បណ្ណាគារ គីម សេង ឆ្នាំ១៩៥៨, ទំព័រ២៩។

អ្នកនិពន្ធ អ៊ុយ ជូន ចាត់ទុកគុណនាមថាជានាមមួយបែប។ គាត់សរសេរថា "<u>នាម</u>ដែលសម្រាប់តែសម្ដែងលក្ខណៈរបស់<u>នាមនាម</u>ណាមួយ"[៦] ដើម្បីឱ្យដឹងថា <u>នាមនាម</u>នោះល្អ ឬ អាក្រក់ . ខ្មៅ ឬ ស . ខ្ពស់ ឬ ទាប . ដូចពាក្យថា ខ្មៅ . ស . ល្អ . អាក្រក់ ជាដើម ហៅថា "គុណនាម"។ លោកចែកគុណនាមចេញជា៣យ៉ាងទៀតគឺ : បកតិគុណនាម១. វិសេសគុណនាម១ (ខ្មៅជាង.សល្មម,...). អតិវិសេសគុណនាម១. (ឧ. ខ្ពស់ស្រឡឹម. ជ្រៅស្រឡូង. ល្អណាស់....)"[៧]។

អ្នកនិពន្ធ ខៀវ ជុំ បានសរសេរថា "(...) ពាក្យសម្រាប់ធ្វើនាមនិងសព្វនាម ឱ្យមានសេចក្ដីឆ្លែកផ្សេងចេញទៅ។ ពាក្យតទៅនេះជាពាក្យគុណសុទ្ធ មិនទាន់ផ្សំជាមួយនាមនិងសព្វនាម ស. ខ្មៅ. ខូច. ខិល (...)"[៨]។

សៀវភៅវេយ្យាករណ៍ថ្នាក់ទី៥ របស់ក្រសួងអប់រំ (១៩៨៣) បានឱ្យនិយមន័យគុណនាម ដោយសរសេរថា "គុណនាម គឺជាសម្ដីសម្ដែងលក្ខណៈរបស់នាម។ គុណនាមមានដូចជា :

(១) - គុណនាមប្រក្រតី (ឬ បកតិគុណនាម), ឧ. សតិអារម្មណ៍ល្អ. គោលជំហរនឹងនរ ... ;

(២) - គុណនាមចំនួន (ឬ សំខ្យាសព្ទ), ឧ. នៅក្នុងក្រោលនេះ មានគោឈ្មោលប្រាំនឹម[៩] , ..."។

តាមលោកសាស្ត្រាចារ្យ ឃិន សុខ[១០] "គុណនាមជាពាក្យដែលគេបន្ថែមទៅលើនាម ដើម្បី :

(១) - បញ្ជាក់គុណលក្ខណៈរបស់នាម :

- ដីនេះក្រហម, ផ្ទះនេះតូច (...) ។

(២) - សម្គាល់នាម :

- ផ្ទះនោះ, ផ្ទះគាត់, តុពីរ (...) ។

ឯលោក អ៊ុក វិបុល ឱ្យនិយមន័យគុណនាមថា "គឺជាពាក្យដែលបញ្ជាក់លក្ខណៈឱ្យនាម ឬ សព្វនាម"[១១]។ អ្នកនិពន្ធរូបនេះបានចែកគុណនាមជា១២ប្រភេទ ប៉ុន្តែ គាត់យកគុណនាមប្រក្រតីទៅចែកជា៥ប្រភេទរួចទៅហើយ (គុណនាមគុណភាព. ឧ. ល្អ. អាក្រក់. ...). (គុណនាមពណ៌. ឧ. ស. ខ្មៅ. ...). (គុណនាមទំហំ. ឧ. ធំ. តូច. ...).

---

[៦] - បន្ទាត់គូសពីក្រោមត្រូវបានធ្វើឡើងដោយអ្នកនិពន្ធអត្ថបទ។

[៧] - អ៊ុយ ជូន : ***វេយ្យាករណ៍ពិសេស*** . បណ្ណាគារ គីម គី ភ្នំពេញ ១៩៥៨. ទំព័រ៩៩។ ពាក្យ *នាម* ដែលលោក អ៊ុយ ជូន បានប្រើ មិនមែនជានាមសព្ទ ដែលយើងប្រើសព្វថ្ងៃនេះទេ "គុណនាមជា<u>នាម</u>មួយបែប"។ ចំពោះគាត់ នាមមាន នាមនាម (នាមសព្ទ និង គុណនាម) ។

[៨] - ខៀវ ជុំ : ***វេយ្យាករណ៍យើង***. បោះពុម្ពផ្សាយដោយ ទៀន ហុងសេង ភ្នំពេញ ១៩៦៦ . ទំព័រ៥៩។
តាមអ្នកនិពន្ធរូបនេះ ពាក្យដែលមិនទាន់ប្រើជាមួយនាមសព្ទហៅថា ***ពាក្យគុណ*** ដែលគាត់បានរាយឈ្មោះដូចតទៅ : " *ស. ខ្មៅ. ខូច. ខិល. ខ្ពក. ខ្ចី. ខ្ចិល. ខ្ពស់. ខ្លាំង. ខ្សោយ. ខ្សត់. ក្រ. ក្រាស់. ស្ដើង. ទាប (...)* " ។

[៩] - ក្រសួងអប់រំ : ***វេយ្យាករណ៍ថ្នាក់ទី៥***. បោះពុម្ពនៅមជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ១៩៨៣ . ទំព័រ ៩៤-៩៥។
នៅថ្នាក់ទី៦ ក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍របស់ក្រសួងអប់រំបានបញ្ចូលគុណនាមចំនួនក្នុងក្រុម " គុណនាមកំនត់ " (គុណនាមកំណត់) ដែលមាន : ១. គុណនាមចង្អុល. ២. គុណនាមកម្មសិទ្ធិ. ៣. គុណនាមសំណួរ. ៤. គុណនាមចំនួន. ៥. គុណនាមមិនច្បាស់។

[១០] - ឃិន សុខ : ***វេយ្យាករណ៍ភាសាខ្មែរ***. រាជបណ្ឌិត្យសភាកម្ពុជា សហការជាមួយអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា. រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ភ្នំពេញ ឆ្នាំ២០០៧ . ទំព័រ ១៩៥។

[១១] - អ៊ុក វិបុល : ***វេយ្យាករណ៍ទំនើប ថ្នាក់ទី១២***. គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយរបស់ក្រសួងអប់រំ ឆ្នាំ២០០១ . ទំព័រ១៧។

(គុណនាមអាយុ, ឧ. ចាស់, ក្មេង, ...), (គុណនាមទ្រង់ទ្រាយ, ឧ. មូល, ជ្រុង, ...) ។ ដូច្នេះ គុណនាម ពិតប្រាកដរបស់គាត់ មានតែ៨ ប្រភេទទេ គឺ :

១ - គុណនាមប្រក្រតី , ..........................................

២ - គុណនាមនាម, ឧ. ភាសាខ្មែរ, ផ្ទះថ្ម,... ................

៣ - គុណនាមកិរិយា, ឧ. បន្ទប់ដេក, អាងហែលទឹក, ..

៤ - គុណនាមចំនួន, ឧ. គោមួយក្បាល, ទីមួយ, ទីពីរ, ...

៥ - គុណនាមមិនច្បាស់, ឧ. ណា, ណាមួយ, ម្នាក់ៗ, ...

៦ - គុណនាមសំណួរ, ឧ. អ្វី, ស្អី, អ្វីមួយ, ...

៧ - គុណនាមចង្អុល, ឧ. សៀវភៅនេះ, គុនោះ, ...

៨ - គុណនាមកម្មសិទ្ធិ, ឧ. សៀវភៅខ្ញុំ, ផ្ទះគ្រូ, ... ។

## ១.២- ពិនិត្យពិចារណាមើលនិយមន័យខាងលើ :

បើយើងពិចារណាមើលនិយមន័យខាងលើ យើងឃើញថា អ្នកនិពន្ធទាំងប៉ុន្មានខាងលើឱ្យនិយមន័យប្រហាក់ប្រហែលៗគ្នាសម្រាប់គុណនាម គឺ គុណនាមជាពាក្យសម្រាប់ "សម្តែងលក្ខណៈឱ្យនាមសព្ទ" ហើយ និយមន័យទាំងនោះមានន័យទូលាយខ្លាំង ។ ម្យ៉ាងទៀត គប្បីបញ្ជាក់ថា អ្នកនិពន្ធបីរូបខាងដើម (ពូវ អ៊ុម, អ៊ុយ ជួន, ខៀវ ជុំ) មិនបានគិតដល់ពាក្យដែលក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍របស់ក្រសួងអប់រំហៅថា "គុណនាមកំនត់"[១២] (គុណនាមកំណត់) នោះទេ គឺ ពួកគាត់គិតដល់ត្រឹមតែគុណនាមប្រក្រតី ពីព្រោះ នៅពេលនោះ គុណនាមគឺជាគុណនាមប្រក្រតី ។ ចំពោះពាក្យផ្សេងៗទៀតដែលយើងរាប់បញ្ចូលក្នុងគុណនាមដែរ គឺ គុណនាមកំណត់នោះ គេមានពាក្យផ្សេងៗទៀតសម្រាប់សម្គាល់វា ដូចជា សំខ្យាសព្ទ (adjectif numéral), បកតិសំខ្យា (adjectif numéral cardinal), បូរណសំខ្យា (adjectif numéral ordinal) ។ ល ។ ឬ មិនទាន់មានឈ្មោះសម្រាប់ហៅនៅឡើយ (ឧ. "នេះ (និះ) <u>សព្ទ</u>, <u>ពាក្យ</u>សម្រាប់បង្ហាញ, សម្រាប់ចង្អុលអ្វីៗ ....", វចនានុក្រម សម្តេច ជួន ណាត (ក្រោមការដឹកនាំ) ។

<u>សង្កេត</u> :

(១)- និយមន័យ "ជាពាក្យសម្រាប់សម្តែងលក្ខណៈឱ្យនាមសព្ទ" មិនមែននិយមន័យឱ្យគុណនាមទេ ប៉ុន្តែ គឺជានិយមន័យសម្រាប់បញ្ញត្តិដែលភាសាវិទូបារាំងហៅថា "complétif" ដែលមានន័យថា "ពាក្យដែលបង្គ្រប់លក្ខណៈឱ្យគេ" ហើយ ដែលគេច្រើនប្រើផ្ទឹគ្នាជាគូថា "complétif–complété" គឺ "ពាក្យដែលបង្គ្រប់លក្ខណៈឱ្យគេ + ពាក្យដែលទទួលលក្ខណៈដែលគេផ្តល់ឱ្យ"[១៣], (ex. <u>Bon</u> coeur, <u>horse</u> race, <u>wash</u>board) ឬ "complété - complétif" គឺ "ពាក្យដែលទទួលលក្ខណៈដែលគេផ្តល់ឱ្យ + ពាក្យដែលបង្គ្រប់លក្ខណៈឱ្យគេ", (ex. homme <u>charitable</u>, papa-<u>gâteau</u>, machine <u>à écrire</u>).

(២) - ទោះផ្អែកលើនិយមន័យទូលាយក្តី ក៏ក្រុមអ្នកនិពន្ធនៃក្រសួងអប់រំមិនហ៊ានយកកម្មរបស់នាម (ដូច "ថ្ម" ក្នុង "ផ្ទះថ្ម" ជាដើម) មកធ្វើជាគុណនាម (ប្រក្រតី)នៅឡើយ ដូចមានឧទាហរណ៍ដែលយើងទើបបានស្រង់ជាភស្តុតាងស្រាប់(សតិអារម្មណ៍ល្អ, គោលជំហរនឹងនរ,...) ។

ដោយនិយមន័យសម្រាប់គុណនាមមានលក្ខណៈទូលាយពេក ដូចដែលយើងបានលើកឡើងខាងដើម អ្នកនិពន្ធខ្លះបានឆ្លៀតឱកាស ហើយ ចាត់ទុកពាក្យទាំងប៉ុន្មានដែលសម្តែងលក្ខណៈឱ្យនាមសព្ទថាជាគុណនាម (ផ្ទះថ្ម, ផ្ទះគាត់,

---

[១២] - វាក្យសព្ទ *គុណនាមកំនត់* (គុណនាមកំណត់) ត្រូវបានផ្សព្វផ្សាយដោយ សៀវភៅវេយ្យាករណ៍ថ្នាក់ទី៧ របស់ក្រសួងអប់រំ ឆ្នាំ១៩៨៣ ទំព័រ ៧៤។

[១៣] - បន្ទាត់គូសពីក្រោមមានន័យថា "ពាក្យដែលសម្តែងលក្ខណៈឱ្យគេ" ។

បន្ទប់ដេក, ... ) ។

តើមតិបែបនេះស្របតាមលក្ខណៈសម្ព័ន្ធនៃភាសាខ្មែរឬទេ ? បន្ថែមលើការសង្កេតខាងលើ យើងនឹងព្យាយាម ពិនិត្យពិចារណា ដូចតទៅ :

**១.២.១- <u>ពិនិត្យមើលលក្ខណៈសម្ព័ន្ធនៃពាក្យមួយចំនួនដែលត្រូវបានគេចាត់ទុកជាគុណនាម តាមរយៈតេស្ត "វចនាបថ"</u> :**

ឧទាហរណ៍ :

(១) - ផ្ទះធំ.

(២) - ផ្ទះថ្ម .

(៣) - បន្ទប់ដេក ។

តាមទម្រង់ស្ទើលើ[១៤] (ស្រទាប់លើ) កន្សោម *ផ្ទះថ្ម*, *បន្ទប់ដេក* & *ផ្ទះធំ* មានទម្រង់ដូចគ្នា ប៉ុន្តែ បើចូលដល់ទម្រង់ជ្រៅវិញ កន្សោមទាំងបីឥតមានលក្ខណៈសម្ព័ន្ធដូចគ្នាទេ ពីព្រោះ :

- គេអាចថា *ផ្ទះដ៏ធំ*, *ផ្ទះធំពេក*, *ផ្ទះធំណាស់*, *ផ្ទះនេះធំជាងផ្ទះនោះ* ... ប៉ុន្តែ គេមិនអាចថា * *ផ្ទះដ៏ថ្ម*, * *ផ្ទះថ្មណាស់*, ... ឬ * *បន្ទប់ដ៏ដេក* , * *បន្ទប់ដេកណាស់*, ... នោះទេ។

- គេអាចថា *ផ្ទះធ្វើពីថ្ម*, *បន្ទប់សម្រាប់ដេក*, ... ប៉ុន្តែ គេមិនអាចថា * *ផ្ទះធ្វើពីធំ* ,* *ផ្ទះសម្រាប់ធំ*, ... នោះក៏ទេដែរ ។

<u>កំណត់សម្គាល់</u> : សញ្ញាផ្កាយ (*) ខាងលើ មានន័យថា កន្សោម/ល្បះដែលនៅខាងស្តាំ នៃសញ្ញានេះ ជាកន្សោម/ល្បះដែលមិនអាចទទួលយកបាន។

**១.២.២- <u>ពិនិត្យមើលលក្ខណៈសម្ព័ន្ធនៃពាក្យមួយចំនួនដែលត្រូវបានគេចាត់ទុកជាគុណនាម តាមរយៈតេស្ត "លុបពាក្យគោលចេញ"</u> :**

ឧទាហរណ៍ :

(៤) - ផ្ទះធំនេះនៅជាប់ផ្លូវលំ .

(៥) - ផ្ទះថ្មនេះនៅឆ្ងាយពីផ្លូវថ្នល់ .

(៦) - ប្រពន្ធខ្ញុំចូលចិត្តអានសៀវភៅ .

(៧) - បន្ទប់ដេកនៅផ្ទះនេះធ្វើឱ្យយើងស្រួលខ្លួន ។

**បើយើងលុបពាក្យគោលខាងឆ្វេងក្នុងល្បះទាំងបួនខាងលើ យើងបានល្បះខាងក្រោម :**

---

[១៤] - "ស្ទើ *ន.* ស្រទាប់ (...) ដែលសើរើឡើងបានដោយងាយ" (វចនានុក្រម សម្តេច ជួន ណាត ) ។

(៤ផ្ទួន) - * ធំនេះនៅជាប់ផ្លូវលំ[១៥] .

(៥ផ្ទួន ) - ថ្មនេះនៅឆ្ងាយពីផ្លូវថ្នល់ .

(៦ផ្ទួន ) - ខ្ញុំចូលចិត្តអានសៀវភៅ .

(៧ផ្ទួន) - ដេកនៅផ្ទះនេះធ្វើឱ្យយើងស្រួលខ្លួន ។

**តេស្ត "លុបពាក្យគោលចេញ" ខាងលើបានបង្ហាញលក្ខណៈសម្ព័ន្ធពីរបែបប្លែកគ្នា :**

<u>**ករណីទី១**</u> : *ធំ* មិនអាចប្រើតែម្នាក់ឯងជាប្រធាននៃល្បះបានទេ ( ពាក្យនេះជាគុណនាមប្រក្រតី).

<u>**ករណីទី២**</u> : *ថ្ម , ខ្ញុំ & ដេក* អាចប្រើតែឯងជាប្រធាននៃល្បះបាន[១៦] ( មិនមែនជាគុណនាមប្រក្រតីទេ គេប្រើវាជាកម្មរបស់ : *ថ្ម* , *ខ្ញុំ* , *ដេក* , ដែល តាមលំដាប់លំដោយ ជានាមសព្ទ, សព្វនាម និង កិរិយាសព្ទ ហើយ ដែលអាចប្រើដូចគុណនាម( ប្រក្រតី) ក្នុងមួយករណី ប៉ុន្តែ ក្នុងករណីឯទៀតៗ គុណនាម( ប្រក្រតី) នេះមិនអាចប្រើតាមគេបានទេ ។

## ១.២.៣- <u>ពិនិត្យមើលលក្ខណៈសម្ព័ន្ធនៃពាក្យមួយចំនួនដែលត្រូវបានគេចាត់ទុកជាគុណនាមតាមរយៈតេស្ត</u> " <u>ដំណូរទីតាំង</u> " :

ដូចយើងបានឃើញខាងលើស្រាប់ អ្នកវេយ្យាករណ៍មួយចំនួនបានបែងចែកគុណនាមជាគុណនាមប្រក្រតីនិងគុណនាមកំណត់ ។ ដើម្បីឱ្យដឹងថា ការបែងចែកបែបនេះផ្អែកលើមូលដ្ឋានវេយ្យាករណ៍ជាក់លាក់ឬយ៉ាងណា គប្បីយើងពិនិត្យលក្ខណៈន័យនិងលក្ខណៈសម្ព័ន្ធរបស់កន្សោម/ល្បះមួយចំនួន ( មានល្បះចាស់ខ្លះនិងល្បះថ្មីខ្លះ) តាមការបែងចែកខាងលើ ដូចតទៅ :

### ១.២.៣.១- <u>លក្ខណៈដូចគ្នាផ្អែកលើទីតាំង រវាងគុណនាមប្រក្រតី និង គុណនាមកំណត់មួយចំនួន</u> :

<u>**ឧទាហរណ៍ទាក់ទងនឹងគុណនាមប្រក្រតី**</u> :

(៨) - កម្មករ**ថ្មី**លើកដៃសំពះសួរនាងនារី ( *ថ្មី* ត្រូវបានគេចាត់ទុកជាគុណនាមប្រក្រតី) .

---

[១៥] - នៅពេលក្រោយ យើងនឹងសិក្សាឱ្យឃើញថា តើ "ល្អ" និង "អាក្រក់" ដែលជាគុណនាម និង ដែលអាចប្រើជាកម្មរបស់កិរិយាសព្ទ "បាន" ក្នុងសុភាសិត "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" នោះ វាជាករណីពិសេស ដូចក្នុងសុភាសិតបារាំង ''Pierre qui roule n'amasse pas mousse'' ដែលឥតប្រើ ''article'' នោះ ឬ យ៉ាងណា ។

[១៦] - ក្នុងករណីខ្លះ ការលុបពាក្យគោលចេញ អាចបណ្តាលឱ្យល្បះមានលក្ខណៈមិនធម្មតា ប៉ុន្តែ គប្បីយើងចាំថា ដើម្បីឱ្យល្បះមានលក្ខណៈធម្មតា ល្បះនោះត្រូវមានលក្ខណៈសមស្របពីរយ៉ាង : ១- មានវេយ្យាករណភាព ( ភាពស្របតាមក្បួនវេយ្យាករណ៍) ; ២- មានលក្ខណៈសមស្របតាមធម្មជាតិឬតាមជំនឿក្នុងសង្គម . ឧ.* *ដីរបោះ* ជាល្បះមានវេយ្យាករណភាព ( ល្បះ * *ដីរបោះ* នេះ មានទម្រង់ដូចល្បះ *សេះរបោះ/ កញ្ចាល់របោះ* ដែរ ប៉ុន្តែ តាមធម្មជាតិឬតាមជំនឿ ខ្មែរយើងទុកល្បះ * *ដីរបោះ* ជាល្បះដែលមិនអាចទទួលយកបាន ពីព្រោះវាមានតែវេយ្យាករណភាព ប៉ុន្តែ ខ្វះភាពសមស្របតាមធម្មជាតិឬតាមជំនឿ) ។

**<u>ឧទាហរណ៍ទាក់ទងនឹងគុណនាមកំណត់</u>**[១៧] :

(៩) - បុរស<u>នោះ</u> ក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ[១៨] (*នោះ* ត្រូវបានគេចាត់ទុកជាគុណនាមចង្អុល) .

(១០) - តុ<u>ពីរ</u> (*ពីរ* ត្រូវបានគេចាត់ទុកជាគុណនាមចំនួន) .

(១១) - និស្សិត<u>ទាំងឡាយ</u>ត្រូវខំរៀន (*ទាំងឡាយ* ត្រូវបានគេចាត់ទុកជាគុណនាមមិនច្បាស់) .

(១២) - សៀវភៅខ្ញុំ/ ផ្ទះគ្រូ (*ខ្ញុំ/ គ្រូ* ត្រូវបានគេចាត់ទុកជាគុណនាមកម្មសិទ្ធិ[១៩]) .

(១៣) - គាត់ប្រកបការងារអ្វី ?[២០] (*អ្វី* ត្រូវបានគេចាត់ទុកជាគុណនាមសំណួរ) ។

បើយើងធ្វើការប្តូរទីតាំងនៃពាក្យ *ថ្មី* មកខាងឆ្វេងនៃនាមសព្ទ *កម្មករ*, ប្តូរពាក្យ *នោះ* មកខាងឆ្វេង នៃនាមសព្ទ *បុរស*, ប្តូរពាក្យ *ទាំងឡាយ* មកខាងឆ្វេងនៃនាមសព្ទ *និស្សិត* , ប្តូរពាក្យ *អ្វី* មកខាងឆ្វេងនៃនាមសព្ទ *ការងារ* , យើងទទួលបាននូវកន្សោម /ល្បះ ដូចខាងក្រោម :

(៨ផ្ទួន ) - " * ថ្មីកម្មករ លើកដៃសំពះសួរនាងនារី " .

(៩ផ្ទួន ) - " * **<u>នោះ</u>**បុរស ក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ " .

(១០ផ្ទួន) - " * ពីរតុ " .

(១១ផ្ទួន ) - " * **<u>ទាំងឡាយ</u>**និស្សិតត្រូវខំរៀន " .

(១៣ផ្ទួន) - " * គាត់ប្រកប**អ្វី**ការងារ? " ។

យើងសង្កេតឃើញថា ពាក្យទាំងប៉ុន្មាន ដែលយើងបានប្តូរទីតាំង បានបណ្តាលឱ្យកន្សោម/ល្បះ<u>ឈប់</u>មានលក្ខណៈស្របតាមក្បួនវេយ្យាករណ៍ខ្មែរ[២១] ។

**១.២.៣.២- <u>លក្ខណៈន័យប្លែកគ្នា រវាង គុណនាមពិនិត្យនៅចំណុចខាងលើ និង គុណនាមចំនួន</u> :**

---

[១៧] - ក្រសួងអប់រំ : ***វេយ្យាករណ៍ថ្នាក់ទី៦,*** បោះពុម្ពនៅមជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា ១៩៨២ , ទំព័រ ៧៣ ។ នៅថ្នាក់ទី៦ ក្រុមអ្នកនិពន្ធសៀវភៅវេយ្យាករណ៍របស់ក្រសួងអប់រំបានបញ្ចូលគុណនាមចំនួនក្នុងក្រុម "គុណនាមកំនត់ " (គុណនាមកំណត់) ដែលមាន : ១. គុណនាមចង្អុល, ២. គុណនាមកម្មសិទ្ធិ, ៣. គុណនាមសំណួរ, ៤. គុណនាមចំនួន, ៥. គុណនាមមិនច្បាស់ ។

[១៨] - ល្បះ (៨).(៩) ដកស្រង់ពីរឿង កុលាបប៉ៃលិន របស់លោក ញ៉ុក ថែម បោះពុម្ពឡើងវិញដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយរបស់ក្រសួងអប់រំ ឆ្នាំ២០០១ ទំព័រ១៧ ។

[១៩] - សូមមើលចំណុច ១.២.៣.៣. ។

[២០] - ដកស្រង់ចេញពីសៀវភៅ ***វេយ្យាករណ៍*** ថ្នាក់ទី៦, ក្រសួងអប់រំ ឆ្នាំ១៩៨២ , ទំព័រ៧៦ ។

[២១] - គប្បីយើងចាំថា គុណនាមប្រក្រតីមួយចំនួន ខ្ចីពីភាសាបាលី-សំស្ក្រឹត ត្រូវគេដាក់នៅខាងឆ្វេងនៃនាមសព្ទ (តាមសម្ព័ន្ធនៃភាសានេះ) ដូច : រាជរដ្ឋាភិបាល, ពុទ្ធិកសាកលវិទ្យាល័យ.... ទោះបីជាពាក្យក្រុមនេះមួយចំនួនត្រូវបានទទួលខ្មែរូបនីយកម្មជាបន្តបន្ទាប់ក៏ដោយ ដូច : បកតិគុណនាម > គុណនាមប្រក្រតី, ហេតុកិរិយា > កិរិយាហេតុ, ... ។

កន្សោម *តុពីរ* (ឧ.ទី១០) អាចប្តូរទៅជាកន្សោម *ពីរតុ* (១០ផ្ទះ)ដែលមានលក្ខណៈស្របនឹងក្បួនវេយ្យាករណ៍នៃភាសាខ្មែរ ប៉ុន្តែ យើងបានដឹងទាំងអស់គ្នាហើយថា កន្សោមទាំងពីរនេះមានន័យផ្សេងគ្នា ។

### ១.២.៣.៣- **បន្ថែក រវាងពាក្យពិនិត្យនៅចំណុចខាងលើ និង ពាក្យ *ខ្ញុំ* / *គ្រូ* ( ប្រពន្ធខ្ញុំ / ផ្ទះគ្រូ)** :

ចំពោះពាក្យ *ខ្ញុំ* ក្នុងកន្សោម *ប្រពន្ធខ្ញុំ* វិញ (ឧ.ទី៦) ដូចយើងបានឃើញនៅចំណុច ១.២.២.ស្រាប់ មិនមែនជាគុណនាមកម្មសិទ្ធិទេ ។ បើយើងអាចប្រើតេស្តដើម្បីបង្ហាញឱ្យឃើញថា សព្វនាម *ខ្ញុំ* មិនមែនជាគុណនាមកម្មសិទ្ធិទេនោះ យើងគង់នឹងអាចបង្ហាញឱ្យឃើញថា នាមសព្ទ *គ្រូ* (ក្នុងកន្សោម*ផ្ទះគ្រូ* , ឧ.ទី១២) ក៏មិនមែនជាគុណនាមកម្មសិទ្ធិដែរ ។ ក្រោយពីបានពិនិត្យពិចារណាលើចំណុចជាច្រើន យើងបានសង្កេតឃើញថា នាមសព្ទនិងសព្វនាម (ជាពិសេស សព្វនាមបុរិសៈ) អាចប្រើជាមួយពាក្យ *របស់* បាន. ឧទាហរណ៍ : *ប្រពន្ធរបស់ខ្ញុំ* ឬ *ផ្ទះរបស់គ្រូ* ។ ទោះបីមានការប្រើពាក្យ *របស់* នៅកណ្តាលក្តី ឬ ប្រើផ្ទាល់នឹងនាមសព្ទក្តី សព្វនាមបុរិសៈ *ខ្ញុំ* និង នាមសព្ទ *គ្រូ* មានមុខងារជាកម្ម (complément) របស់នាមសព្ទ *ប្រពន្ធ* និង របស់នាមសព្ទ *ផ្ទះ*[២២] ។

### ១.២.៣.៤- **លក្ខណៈស៊ីជម្រៅមានបន្ថែក រវាង គុណនាមប្រក្រតី និង គុណនាមកំណត់** :

ក្រោយពីបានលុប "គុណនាមកម្មសិទ្ធិ"[២៣] ចេញពីបញ្ជីគុណនាមកំណត់ យើងសង្កេតឃើញថា គុណនាមប្រក្រតីនិងគុណនាមកំណត់ មានលក្ខណៈស៊ីជម្រៅប្លែកគ្នាលើបីចំណុច :

**ចំណុចទី១** - គុណនាមកំណត់ខ្លះអាចក្លាយទៅជាសព្វនាមដោយមិនចាំបាច់មានពាក្យជំនួយ. ឧទាហរណ៍ :

(១៤) - នេះជាផ្ទះខ្ញុំ .

(១៥) - ? ណាជារបស់ឯង? (សញ្ញាសួរដើមល្បះមានន័យថា "មិនប្រាកដជាត្រឹមត្រូវទាំងស្រុងទេ").

(១៦) - ខ្ញុំយកទាំងអស់ .

(១៧) - ឱ្យខ្ញុំបីសិនមក! ។

បញ្ជាក់.- ចំពោះគុណនាមប្រក្រតី គេត្រូវប្រើពាក្យជំនួយដើម្បីឱ្យកន្សោម/ល្បះមានលក្ខណៈវេយ្យាករណ៍សមស្រប, ឧ. ខ្ញុំយកអាធំ ឯងយកអាតូចទៅ! ។

---

[២២] - ភាសាវិទ្យាទូទៅបានបង្ហាញឱ្យឃើញថា ភាសាក្នុងលោកមានលក្ខណៈប្លែកគ្នាលើចំណុចខ្លះប៉ុន្តែ វាក៏មានលក្ខណៈសកលលើចំណុចជាច្រើនផងដែរ : ពិតមែនតែភាសាឡាតាំងឬភាសាបាឡីអាចប្រើវិធីកម្លាយដើម្បីធ្វើនាមសព្ទឱ្យដូររូបទៅជាគុណនាមក្តី ក៏ភាសានេះមានប្រើនាមសព្ទក្នុងមុខងារជាកម្ម (cas génitif ឬ ឆដ្ឋីវិភត្តិ) ផងដែរ (ដើម្បីឱ្យងាយយល់ដល់សាធារណជនខ្មែរ ដែលចេះភាសាបារាំងស្ទើរតែទាំងអស់គ្នា យើងអាចយកឧទាហរណ៍ដូចនេះ : *ambiance familiale* និង *ambiance de famille* ដែលក្នុងនោះ *familiale* ជាគុណនាមដែលមានមុខងារជាគុណបទ (épithète) របស់នាមសព្ទ *ambiance* និង *de famille* ជាកម្ម (complément) របស់នាមសព្ទ *ambiance* ។

[២៣] - គួររំលឹកថា ទោះបីពាក្យខ្មែរគ្មានវចនៈនិងលិង្គក្តី ក៏ខ្មែរអាចសម្តែងមតិទាក់ទងនឹងចំនួនឬភេទរបស់មនុស្ស/សត្វ បានដែរ : ដូចគ្នានេះ ទោះភាសាខ្មែរគ្មានគុណនាមកម្មសិទ្ធិក្តី ក៏យើងអាចសម្គាល់កម្មសិទ្ធិបានដែរ ដោយសារកម្ម (ផ្ទះគ្រូខ្ញុំ = ផ្ទះរបស់គ្រូរបស់ខ្ញុំ/?ផ្ទះនៃគ្រូនៃខ្ញុំ), (សញ្ញាសួរមានន័យថា "ការប្រើបែបនេះមានលក្ខណៈវេយ្យាករណ៍សមស្រប ប៉ុន្តែ គេមិនទាន់ធ្លាប់ប្រើនៅឡើយ") ។

**<u>ចំណុចទី២</u>** - មានតែគុណនាមប្រក្រតីទេទើបអាចប្រើជាវិសេសគុណនាមបាន, ឧទាហរណ៍ :

(១៨) - ផ្លូវនេះ**<u>ត្រង់ជាង</u>**ផ្លូវនោះ .

(១៩) - ពូសុខ**<u>ពូកែជាង</u>**ពូសៅ ។

**<u>ចំណុចទី៣</u>** - មានតែគុណនាមប្រក្រតីទេទើបអាចប្រើជាអតិវិសេសគុណនាមបាន, ឧទាហរណ៍ :

(២០) - កាំបិតនេះ**<u>មុតណាស់</u>** .

(២១) - ទីនេះ**<u>ក្រខ្វក់ពេក</u>**បានជាមនុស្សមានសុខភាពមិនល្អ ។ល។

## ១.៣. <u>ហេតុអ្វីក៏អ្នកស្រាវជ្រាវខ្លះបានប្រកាសថាភាសាខ្មែរគ្មានគុណនាម (ប្រក្រតី) ឬ ស្ទាក់ស្ទើរ</u> ?

លោកស្រី ពូវ សៅរស់ អ្នកស្រាវជ្រាវខ្មែរល្បីឈ្មោះម្នាក់នៅប្រទេសបារាំង បានប្រកាសនៅឱកាសដែលគាត់ធ្វើបាឋកថាមួយនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញថា ភាសាខ្មែរឥតមានគុណនាមទេ ប៉ុន្តែ ក្រោយមកគាត់បានប្តូរមតិយោបល់វិញ ដោយទទួលស្គាល់ថា ភាសាខ្មែរមានគុណនាម ។

រីឯលោក Franklin Huffman គ្រូបង្រៀនភាសាខ្មែរនៅ Yale University វិញ គាត់បានហៅគុណនាមនៃភាសាខ្មែរថា "adjectival verbs" ។ លោកសាស្ត្រាចារ្យរូបនេះ ដែលបានហៅគុណនាមនៃភាសាខ្មែរថា "adjectival verbs" បែបនេះ ប្រាកដជាបានពិចារណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយដោយមិនមើលឃើញតែអ្វីដែលស្រដៀងគ្នារវាងគុណនាម (ប្រក្រតី) និងកិរិយាសព្ទនោះទេ បើពុំនោះសោតគាត់ហៅវាថាជាកិរិយាសព្ទឬកិរិយាសព្ទមួយបែប (អកម្មកិរិយា ជាដើម) ហើយ អះអាងថា ភាសាខ្មែរគ្មានគុណនាម (ប្រក្រតី) ទេទៅហើយ ។ បើគាត់ធ្វើបែបនេះ គាត់បានចាត់ទុក *<u>តូច</u>* ក្នុង *មនុស្សនេះ<u>តូចណាស់</u>* ថាជាកិរិយាសព្ទធម្មតាដូចអ្នកអក្សរសាស្ត្រខ្មែរខ្លះដែលបានអះអាងនោះទៅហើយ ប៉ុន្តែ "adjectival verbs" របស់គាត់មិនអនុញ្ញាតឱ្យគាត់អះអាងបែបនេះបានទេ[២៤] ។

**ការហៅគុណនាម (ប្រក្រតី) ខ្មែរថា "adjectival verbs" ជាការសមស្រប ពីព្រោះគុណនាម (ប្រក្រតី) ខ្មែរមានលក្ខណៈដូចកិរិយាសព្ទតែលើចំណុចមួយចំនួន ហើយ ក៏មានលក្ខណៈប្លែកពីកិរិយាសព្ទជាច្រើនចំណុចផងដែរ :**

**(១) - <u>ចំណុចដូចគ្នា</u> :**

(១.១) - វាអាចប្រើប្រហាក់ប្រហែលនឹងកិរិយាសព្ទ, ឧទាហរណ៍ :

(២២) - ពូសយ<u>ចាស់ហើយ</u> .

(២៣) - <u>ផ្ទះនេះចាស់ទ្រុឌទ្រោម</u>[២៥] ។

(១.២) - វាអាចមានកម្លាយដូចកិរិយាសព្ទដែរ, ឧទាហរណ៍ :

---

[២៤] - ដោយយើងមិនទាន់មានពេលដើម្បីសិក្សាលើបញ្ហានេះឱ្យកាន់តែស៊ីជម្រៅនិងឱ្យគ្រប់ជ្រុងជ្រោយ យើងគ្រាន់តែទាញអារម្មណ៍មិត្តអ្នកអានឱ្យជ្រាបថា ភាសាខ្មែរមិនប្រើ "ណាស់, ពេក, ..." ជាប់ផ្ទាល់នឹងកិរិយាសព្ទទេ (ឧ.* មនុស្សនេះ<u>ដើរណាស់</u>) : គេត្រូវបន្ថែមកិរិយាវិសេសន៍នៅចន្លោះកិរិយាសព្ទនិងពាក្យ "ណាស់, ពេក, ..." នេះ (ឧ.មនុស្សនេះ<u>ដើរលឿនណាស់</u>) ឬក៏ គេបន្ថែមកិរិយាសព្ទជំនួយខាងឆ្វេងនៃកិរិយាសព្ទសាមី (ឧ.មនុស្សនេះ<u>ចូលចិត្តដើរណាស់</u>, ហើយ ផ្ទុយទៅវិញ គេមិនអាចថា "* មនុស្សនេះ<u>ចូលចិត្តតូចណាស់</u>" ដូចជាមួយនឹងកិរិយាសព្ទនោះទេ ។

[២៥] - ប៉ុន្តែ *ចាស់ហើយ* និង *ចាស់ទ្រុឌទ្រោម* មិនមែនជាកិរិយាសព្ទធម្មតាទេ គឺជាគុណប្រធាន (attribut) : វាប្លែកពីកិរិយាសព្ទធម្មតា (យើងអាចផ្អែកលើសម្ព័ន្ធវិទ្យាដើម្បីបង្ហាញបន្ថែករវាង "<u>adjectival verbs</u>" និង កិរិយាសព្ទធម្មតា ដោយមិនយកការយល់បង់ (ការមើលឃើញតែមួយជ្រុង) មកធ្វើជាត្រីមុខឡើយ) ។

(២៤) - គុណនាម *ធំ* > នាមកម្លាយ *ទំហំ* (ដូច កិរិយាសព្ទ *ឈាន* > នាមកម្លាយ *ជំហាន*), ...។

**(២) - ចំណុចប្លែកគ្នា :**

ប៉ុន្តែ គុណនាម ( ប្រក្រតី) ខ្មែរនិងកិរិយាសព្ទខ្មែរក៏មានបន្លែកពីគ្នាលើច្រើនចំណុចដែរ :

(២.១) - ដើម្បីប្រៀបធៀបឬសម្តែងកម្រិតខ្ពស់បំផុត :

- គេប្រើ "ជាង, ណាស់,..." ជាប់ផ្ទាល់និងគុណនាម ( ឧ.ឯងធំជាងខ្ញុំ, ឯងធំណាស់) ;
- គេត្រូវបន្ថែមកិរិយាវិសេសន៍នៅចន្លោះកិរិយាសព្ទនិងពាក្យ "ជាង, ណាស់, ..." , ( ឧ.ឯងដើរលឿន ជាងខ្ញុំ, ឯងដើរលឿនណាស់" ។

(២.២) - គេអាចដាក់គុណនាមជាវិធីបង្អាប់បាន ប៉ុន្តែ គេមិនអាចធ្វើបានជាមួយកិរិយាសព្ទទេ :

- ជាមួយគុណនាម : ចាស់ > កញ្ចាស់, ភ្លឿ > កន្លឿ....
- ជាមួយកិរិយាសព្ទ : ដួល > * កណ្តួល យំ > * កញ្ញំ, ...

បញ្ជាក់ : សញ្ញា (*) នេះ ប្រាប់ថា ពាក្យដែលនៅខាងស្តាំឥតមានក្នុងភាសាខ្មែរទេ។

## ២- សេចក្តីសន្និដ្ឋាន និង សំណើ :

ដើម្បីឱ្យការសិក្សាអំពីភាសាមានលក្ខណៈវត្ថុវិស័យ (caractère objectif) គប្បីយើងចែកឱ្យដាច់ រវាង "ប្រភេទពាក្យ" និង "មុខងារនៃពាក្យ" ហើយ យើងក៏មិនគួរប្រើពាក្យតែមួយសម្រាប់សំគាល់ប្រភេទពាក្យផងនិងមុខងាររបស់ពាក្យផងនោះដែរ ពីព្រោះវានាំឱ្យមានភាពច្របូកច្របល់។ ចំពោះនិយមន័យសម្រាប់គុណនាមវិញ យើងក៏ត្រូវលៃយ៉ាងណាឱ្យនិយមន័យនោះសំគាល់តែមុខងាររបស់គុណនាមសុទ្ធសាធ។

យើងបានដឹងហើយថា ពាក្យនៃអរិយភាសានីមួយៗត្រូវបានគេចែកជាប្រភេទ (ឬ ថ្នាក់) ដែលមានឈ្មោះខុសគ្នា គឺ : នាម , គុណនាម , កិរិយាសព្ទ , កិរិយាវិសេសន៍ , ...។ ពាក្យមួយប្រភេទៗត្រូវបានវេយ្យាករណ៍វិភាគឱ្យឃើញថា មានមុខងារផ្សេងៗ ដែលមានឈ្មោះក៏ផ្សេងៗពីគ្នាដែរ : គប្បីយើងគោរពគោលការណ៍នេះ ដើម្បីចៀសវាងភាពច្របូកច្របល់។

ផ្អែកលើការពិនិត្យពិចារណានិងនិទស្សន៍ (démonstration)[២៦] ខាងលើ យើងកំណត់ន័យឱ្យគុណនាមប្រក្រតីដូចនេះ[២៧] :

"គុណនាមប្រក្រតីជាពាក្យមួយប្រភេទ សម្រាប់ប្រើជាមួយនាមសព្ទ ហើយ ដែលគេអាចប្រើ ជាគុណបទ (ឧ. កូន**ល្អ**), ជាគុណប្រធាន (ឧ. ផ្ទះនេះ**ចាស់**គ្រេនគ្រោម), ជាវិសេសគុណនាម (ឧ. ផ្លូវនេះ**ត្រង់ជាង** ផ្លូវនោះ), ជាអតិវិសេសគុណនាម (ឧ. កាំបិតនេះ**មុតណាស់**), មិនអាចប្រើតែម្នាក់ឯងក្នុងល្បះដោយឥតមាននាមសព្ទភ្ជាប់ជាមួយនោះទេ (ឧ.* ធំនេះនៅជាប់នឹង* លំ), ... ។

---

[២៦] - ពាក្យខ្ចីពីវចនានុក្រមបារាំងខ្មែររបស់ លោក តិប យក់ & ថាវ គន្ធ បណ្ណាគារ ប៊ុត នាង. លេខ ១៧៦ វុក្ខវិថីខេមរភូមិន្ទ ភ្នំពេញ ឆ្នាំ១៩៦២។

[២៧] - សូមកុំច្រឡំ "ដូចនេះ" និង "ដូច្នេះ"។

# <u>គន្ថនិទ្ទេស</u>


*<u>ស្នាដៃជាភាសាខ្មែរៈ</u>*

- កេង វ៉ាន់សាក់, វេយ្យាករណ៍ខ្មែរសង្ខេប សូរស័ទ្ទខ្មែរ, ផ្សព្វផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ ១៩៦៦,
- ក្រសួងអប់រំ : វេយ្យាករណ៍ ថ្នាក់ទី៥, រោងពុម្ពរណសិរ្ស, ភ្នំពេញ ១៩៨៣,
- ក្រសួងអប់រំ : វេយ្យាករណ៍ ថ្នាក់ទី៦, រោងពុម្ពរណសិរ្ស, ភ្នំពេញ ១៩៨៣,
- ក្រសួងអប់រំ : *វេយ្យាករណ៍ ថ្នាក់ទី៧* , រោងពុម្ពរណសិរ្ស , ភ្នំពេញ ១៩៨៣,
- ក្រសួងអប់រំ : *វេយ្យាករណ៍ ថ្នាក់ទី៨* , រោងពុម្ពរណសិរ្ស , ភ្នំពេញ ១៩៨៦,
- ខៀវ ជុំ ( ភិក្ខុ ធម្មបាលោ ), វេយ្យាករណ៍យើង, រោងពុម្ព ទៀង ហុង សេង, ភ្នំពេញ ១៩៦៦,
- គីម សែត, វេយ្យាករណ៍ទំនើប នឹងវិធីសម្ពន្ធ, បណ្ណាគារ វង់ រស្មី, កំពង់ចាម ១៩៦៣,
- ឃីន សុខ, វេយ្យាករណ៍ភាសាខ្មែរ, បោះពុម្ពនៅរោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន, ភ្នំពេញ ២០០៧,
- ជុំ ស៊ុនណាង , *បកតិគុណនាមក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២ នៃរាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ ២០០៣,
- ញ៉ឹក នូវ ( អ្នកឧកញ៉ាមហាមន្ត្រី), វេយ្យាករណ៍ខ្មែរ, រោងពុម្ពព្រះបរមរាជវាំង ភ្នំពេញ ១៩៥៩,
- ថូ ធន, វេយ្យាករណ៍ អក្ខរាវិរុទ្ធ, ក្រចេះ ១៩៦៥,
- ឪ. គាមមុនី, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ ជឹង ងួនហួត, លេខ ៣០ស្ទួន វិថីប៉ាស្ទ័រ, ភ្នំពេញ ១៩៥៥,
- នៅ ស៊ុន : "ភាសាខ្មែរក្នុងចំណោមភាសាអ៊ុស្ទូឡង់ និង ភាសាមិនមែនអ៊ុស្ទូឡង់" នៅក្នុង : Sorn Samnang (Ed.) *ខេមរវិទ្យា* volume II, ភ្នំពេញ ១៩៩៩,
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរសម្រាប់ថ្នាក់មជ្ឈិមដ្ឋាន-ឧត្តមដ្ឋាន, បណ្ណាគារ គីម សេង លេខ២១២, វុក្ខវិថីខេមរភូមិន្ទ, ភ្នំពេញ ១៩៥៨,
- ព្រុំ ម៉ល់ : "លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យក្នុងភាសាខ្មែរ ", នៅក្នុង : *ទស្សនាវដ្តី* នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា , លេខ២ មិថុនា ២០០១,
- សូ មុយឃៀង & ថោង ផែល, វេយ្យាករណ៍ខ្មែរ, រោងពុម្ព បណ្ណាគារ ពេជ្រនិល, ភ្នំពេញ ១៩៧១,
- ឡុង សៀម : *បញ្ហាវចនសព្ទវិទ្យាខ្មែរ* , ផ្សាយដោយអ្នកនិពន្ធ , ភ្នំពេញ ១៩៩៩,
- អ៊ុក វិបុល, វេយ្យាករណ៍ខ្មែរទំនើប ថ្នាក់ទី១២, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ, ១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ២០០១,
- អ៊ុយ ជួន, វេយ្យាករណ៍ពិសេស, រោងពុម្ព គីម គី បណ្ណាគារ លេខ៤៤ វិថីតេជោដំឌិន, ភ្នំពេញ ១៩៥៨,
- អៀវ កើស : *ភាសាខ្មែរ* , បណ្ណាគារ មិត្តសេរី , ភ្នំពេញ ១៩៦៧។

ស្នាដៃជាភាសាបរទេស:


- Huffman Franklin, *Modern spoken Cambodian* , New Haven & London , Yale University Press 1970;
- Judith Jacob, *Cambodian linguistics* , *litterature and history*, School of Oriental and African Studies (London) 1993 ;
- Khin Sok, *La grammaire du khmer moderne*, You Feng , Paris 1999 ;
- Lemaréchal Alain, *Les parties du discours*, Presses Universitaires de France 1989 ;
- Long Seam , "contacts externes des langues Mon-Khmer ", in : *Bulletin de l'École Française d'Extrême- Orient,* Tome LXX, Paris 1981;
- Maspéro Georges, *Grammaire de la langue khmère*, École Française d'Extrême–Orient , Imprimerie Nationale (Paris), 1915;
- Prum Marc, "Analyse sommaire des structures du cambodgien", in: Revue, N°1 pp.48-57, Septembre 2000 de l'Institut de la Langue Nationale de l'Académie Royale du Cambodge ;
- Prum Marc , *Linguistique appliquée à l'enseignement* , Université Nationale de Côte d'Ivoire, Abidjan 1995;
- Prum Marc, *Initiation à la Linguistique*, Université de Toliara (Madagascar),1990;
- Prum Marc , "Processus sociolinguistique de la transformation du système lexicologique du khmer ", in: *Revue Tétralogiques* , No 7 - 1989,pp.61-73,UFR du Langage de l'Université de Rennes II , Presses Universitaires Rennes II , France ;
- Vogel Sylvain, " Introduction à une grammaire du secondaire pour le Cambodge", in : *Cahiers d'Etudes franco-cambodgiens,* No1-1994, Cercle de Linguistique Franco-Khmer de l'Université de Phnom Penh;

# ការប្រើប្រាស់និងការវិវត្តនៃកម្មវាចកៈសម័យមុនអង្គរនិងសម័យអង្គរ

**រៀបរៀងដោយ : មាឃ បូរ៉ា** បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា នៃរាជបណ្ឌិត្យសភាកម្ពុជា

**ដឹកនាំដោយ** : សាស្ត្រាចារ្យបណ្ឌិត **ឡាំ ម៉ល់**

## ១. ការប្រើប្រាស់កម្មវាចកៈសម័យមុនអង្គរនិងសម័យអង្គរ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើសិលាចារឹកកន្លងមក យើងខ្ញុំសង្កេតឃើញថា កម្មវាចកៈ មានការប្រើប្រាស់តាំងពីសម័យមុនអង្គរនិងសម័យអង្គរមកម្ល៉េះ ហើយការប្រើប្រាស់លក្ខណៈកម្មវាចកៈ នេះ មានការប្រែប្រួលរូបសព្ទ និង មានការប្រើពាក្យជំនួយផងដែរ ។

### ១.១- ការប្រើប្រាស់កម្មវាចកៈសម័យមុនអង្គរ

នៅសម័យមុនអង្គរ យើងខ្ញុំសង្កេតឃើញថា បុព្វជនយើងប្រើប្រាស់កម្មវាចកៈមានស្ទើរតែគ្រប់ សិលាចារឹកទាំងអស់ ។ ទោះគ្មានកិរិយាសព្ទជំនួយដូច "être" ឬ" to be" នៃភាសាអង់គ្លេសឬភាសាបារាំង ទេ ក៏ប៉ុន្តែ ទោះយ៉ាងនេះក៏ដោយ ក៏នៅសម័យមុនអង្គរ គេមានប្រើប្រាស់ល្បះកម្មវាចកៈដែរ ។ ហើយ ព្រមទាំងមានកិរិយាសព្ទមួយចំនួនមានការប្រែប្រួលរូបសព្ទ នៅពេលចងជាល្បះជាមួយនឹងពាក្យឯទៀត សម្រាប់ល្បះកម្មវាចកៈ. ឧទាហរណ៍ **ក្ញុំ អំនោយ សិនាហ្វ ប្រគត អាយ ត វិហារ** kñuṃ aṃnoy sināhv pragat āy ta vihār K.505[១] ដែលមានន័យថា ខ្ញុំបម្រើឱ្យ(ដោយ) មន្ត្រីសិនាហ្វ ដើម្បី ផ្គត់ផ្គង់ដល់ព្រះវិហារ ។ មិនតែប៉ុណ្ណោះ កិរិយាសកម្មមួយចំនួនមានការប្រែប្រួលរូបសព្ទផងដែរ នៅ ពេលចងជាល្បះ ជាមួយពាក្យឯទៀត សម្រាប់បង្កើតល្បះកម្មវចកៈ ដូច កិរិយាសព្ទ **ជាហ្វ ទុញ ជួន** ជាដើម ។

#### ១.១.១- ការប្រែប្រួលរូបសព្ទ

យើងខ្ញុំសង្កេតឃើញថា សម័យមុនអង្គរមានប្រើប្រាស់ល្បះដែលមានលក្ខណៈកម្មវាចកៈ ដោយ ការប្រើប្រាស់អន្តោបទ /-amn-/ និង /-ɔmn-/ ផ្សំជាមួយកិរិយាសព្ទ ដើម្បីបង្កើតពាក្យកម្លាយដែលជា កិរិយាសព្ទសម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ ។

---

[១] G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME V, PARIS ,1953, p.23.

### ១.១.១.១- ពាក្យកម្លាយកើតចេញពីកិរិយាសព្ទ ដើម្បីសម្គាល់លក្ខណៈកម្មវាចកៈ

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ** : ក្ញុំ *អំនោយ* ជំអញ ឰ ត វ្រះ កម្រតាង៑ អញ មហាគណបតិ kñuṃ aṃnoy jaṃ añ ai ta vraḥ kamrataṅ añ mahāgaṇapati.K.600N,611A.D,l.2 ដែលមានន័យថា "អ្នកបម្រើថ្វាយដោយមន្ត្រីជំអញ ចំពោះអាទិទេពមហាគណបតិ"[២]។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា ពាក្យ "**អំនោយ**"ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ "**ឱយ** " ដែលជារូបសព្ទនៃកិរិយាសព្ទប្រើក្នុងលក្ខណៈកម្មវាចកៈ នៅក្នុងសម័យមុនអង្គរ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺពាក្យ "មន្ត្រី**ជំអញ**" ស្ថិតនៅខាងក្រោយកិរិយាសព្ទ "**អំនោយ**" ដែលបានក្លាយទៅជា**កម្ម** ហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)**។ ចំណែកឯពាក្យ "**ក្ញុំ**" ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ(រងអំពើ)នៅក្នុងល្បះ។ ជាពិសេស កិរិយាសព្ទ "**ឱយ** "នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន តាមរយៈអន្តេបទ /-amn-/ មកជាពាក្យ"**អំនោយ**"វិញ ហើយ "**អំនោយ**"នៅក្នុងល្បះនេះមិនមែនជា "**នាមសព្ទ**"ទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើ ពាក្យ "**អំនោយ**"ជានាមសព្ទ ដែលមានន័យថា "**ការឱ្យ**" ឬមានន័យថា "**ទាន**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ" **អំនោយ** " កាលពីសម័យមុនជាកិរិយាសព្ទសម្គាល់លក្ខណៈកម្មវាចកៈ។

ពាក្យ " **អំនោយ** " ដែលជានាមសព្ទ គឺជាពាក្យដែលកកើតឡើងអស់ពេលយ៉ាងយូរបន្តិចម្តងៗក្លាយមកជានាមសព្ទ ដូច អត្ថបទសិលាចារឹកនៃប្រាសាទឪឡោក បានសរសេរថា **អំនោយ បោញ មិត្រ សិង៑ ត វ្រះ [កម្រតា]ង៑ អញ ស្រីនៃមិសេស្វរ** aṃnoy poñ mitra siṅ ta vraḥ çrī naimiçeçvara K.808, VII-VIII A.D.l.6 ដែលមានន័យថា "អំណោយរបស់បោញមិត្រសិង (ថ្វាយ)ចំពោះអាទិទេពស្រីនៃមិសេស្វរ"។

ម្យ៉ាងទៀត យើងអាចនិយាយបានថា នាមសព្ទ"**អំនោយ**" បានកកើតឡើងដោយសារកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ បើកិរិយាសព្ទក្នុងភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេ នៅពេលនោះប្រហែលជាបុព្វបុរសយើងប្រើល្បះកត្តុវាចកៈ ដូចនេះ " **ជំអញ ឱយ ក្ញុំ ឰ ត វ្រះ កម្រតាង៑ អញ មហាគណបតិ** ដែលមានន័យថា មន្ត្រីជំអញឱ្យអ្នកបម្រើ ចំពោះអាទិទេពមហាគណបតិ" ទៅវិញ។

---

[២] សូមមើល ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* (តាមសិលាចារឹកសតវត្សទី៦-៨),រោងពុម្ពភ្នំពេញ. ២០០០. ទំព័រ២៧ ។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ស្រេ អំនោយ បោញ ត គុ មាស**. sre aṃnoy poñ ta gui māś K.493,671A.D.,l.19[3] មានន័យថា *ស្រែបានផ្តល់ដោយបោញ(មានប្រវែងមួយមាស)*។ នៅក្នុងល្បះនេះ យើងឃើញថា ពាក្យ "**អំនោយ** " ជាពាក្យកម្លាយចេញពីកិរិយាសព្ទ"**ឱយ** " ហើយ ពាក្យ "**អំនោយ** " នេះជាកិរិយាសព្ទស្នូលនៅក្នុងល្បះ។ ដូច្នេះ យើងឃើញថា ល្បះនេះមានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺពាក្យ "**បោញ** " ដែលជាអ្នកធ្វើអំពើស្ថិតនៅខាងក្រោយកិរិយាសព្ទ "**អំនោយ**" ហើយ វាបានក្លាយទៅជា**កម្ម** ហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)**។ ចំណែកឯពាក្យ"**ស្រេ**" ដែលជាអ្នករងអំពើ ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ)នៅក្នុងល្បះ។

ប្រសិនបើ ពាក្យ"**អំនោយ**"ជានាមសព្ទ ដែលមានន័យថា"**ការឱ្យ**"ឬមានន័យថា "**ទាន**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ "**អំនោយ**" កាលពីសម័យមុនជាកិរិយាសព្ទប្រកបដោយន័យកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **បោញ ឱយ ស្រេ ត គុ មាស** ដែលមានន័យថា បោញឱ្យស្រែ(មានប្រវែងមួយ)មាស នេះទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

### ១.១.១.២- ការប្រើប្រាស់អន្តេបទ/-ɔmn-/ ផ្សំជាមួយកិរិយាសព្ទសម្គាល់លក្ខណៈកម្មវាចកៈ

នៅក្នុងភាសាខ្មែរ អន្តេបទ [-អ៎ម/ន-]និង[-អ៊៎ម/ន-] ជាអន្តេបទ ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់លទ្ធផល/អំពើ[4] ក៏ប៉ុន្តែ នៅសម័យមុនអង្គរ អន្តេបទនេះ ប្រើផ្សំជាមួយកិរិយាសព្ទ ដើម្បីសម្គាល់លក្ខណៈកម្មវាចកៈ ផងដែរ។

#### ១.១.១.២.១- លក្ខណៈសម្គាល់កម្មវាចកៈដែលបង្ហាញកម្មភ្នាក់ងារ( អ្នកធ្វើអំពើ)

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : ស្រេ ត្នៃ កេត ត្រវង បោញ ភាគយុង *ទំនុញ* ត បោញ ភទ្រវិសេស**
sre tṅai ket travaṅ poñ bhāgayuṅ daṃnuñ ta poñ bhadraviçeṣa K.22,VII.A.D,l.32[5], ស្រែខាងកើតត្រពាំងបោញភាគយុងទិញដោយបោញភទ្រវិសេស។ តាមរយៈឧទាហរណ៍នេះយើងអាចសង្កេតឃើញថា រូបសព្ទ "**ទំនុញ**" ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ "**ទុញ**" ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ។ នៅក្នុងល្បះនេះ យើងឃើញ មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺពាក្យ "**បោញ ភទ្រវិសេស** "ស្ថិតនៅខាងក្រោយកិរិយាសព្ទ"**ទំនុញ**" ដែលបានក្លាយទៅជា**កម្ម**ហៅថា **កម្ម ភ្នាក់ងារ**

---

៣ សូមមើល : ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* ជ.ឯ.ម. ២០០០. ទំព័រ ២៥៩។

៤ សូមមើល ព្រុំ ម៉ល់ : ***វេយ្យាករណ៍ទម្រង់និយម នៃភាសាខ្មែរទំនើប***. ការផ្សាយរបស់អ្នកនិពន្ធ. ឆ្នាំ២០០៦.ទំព័រ៦។

៥ សូមមើល : ឡុង សៀម : *វចនានុក្រមខ្មែរបុរាណ* ជ.ឯ.ម. ២០០០. ទំព័រ ៣២៥ ។

(**ធ្វើអំពើ**)។ ចំណែកឯ កន្សោមពាក្យ " **ស្រែ ត្លៃ កេត ត្រពាំង បោញ ភាគយុង** " ស្ថិតនៅពីមុខកិរិយាសព្ទ ដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ(រងអំពើ)នៅក្នុងល្បះ។ ជាពិសេសកិរិយាសព្ទ "**ទុញ**"នេះបានផ្លាស់ប្ដូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តោបទ /-ɔmn-/ មកជាពាក្យកម្លាយ "**ទំនុញ**"វិញ ហើយ ពាក្យ " **ទំនុញ** "នៅក្នុងល្បះនេះមិនមែនជា"**នាមសព្ទ**"នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើ ពាក្យ"**ទំនុញ**" គឺជានាមសព្ទដែលមានន័យថា "**ទំនិញឬរបស់របរសម្រាប់ដោះដូរ** ឬក៏ **របស់របរសម្រាប់លក់នោះ**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះយើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ "**ទំនុញ**" កាលពីមុនជាពាក្យកម្លាយចេញពីកិរិយាសព្ទ "**ទុញ**" ដែលជា កិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈ។បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះគួរតែបុព្វបុរសយើងសរសេរថា "**បោញភទ្រ វិសេស ទុញ ស្រែ ត្លៃ កេត ត្រពាំង បោញ ភាគយុង** ដែលមានន័យថា *បោញ ភទ្រវិសេសទិញស្រែខាងកើតត្រពាំងបោញភាគយុង* បែបនេះ ទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

តាមរយៈការបកស្រាយខាងលើ គេអាចធ្វើការសន្និដ្ឋានបានថា ភាសាខ្មែរកាលពីសម័យមុនអង្គរមានការប្រើប្រាស់ល្បះដែលមានន័យកម្មវាចកៈ។ មិនតែប៉ុណ្ណោះ សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម កាលពីលោកនៅមានព្រះជន្មនៅឡើយ លោកបានសន្និដ្ឋានថា ភាសាខ្មែរអាចផ្ដល់ឥទ្ធិពលរបស់ខ្លួន នៅក្នុងការប្រើប្រាស់កិរិយាសព្ទបែបនេះទៅលើភាសាថៃនិងភាសាឡាវ ថែមទៀតផង។

តាមការវិភាគវែកញែកខាងលើ យើងអាចទាញរូបមន្តបានថា :

| ប្រធាន(រងអំពើ)+ កិរិយាសព្ទ + កម្មភ្នាក់ងារ(ធ្វើអំពើ) |
|---|

### ១.១.១.២.២- លក្ខណៈសម្គាល់កម្មវាចកៈដែលមិនបង្ហាញកម្មភ្នាក់ងារ( អ្នកធ្វើអំពើ)

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : ក្ញុំ ១ ជំនោន អាករ ត វ្រះ កម្រតាង អញ ស្រី ខន្ទលិង្គ** «kñuṃ 1 jaṃnon ākara ta vraḥ kamratāṅ añ çrī khandaliṅga»[6] K.561,681.A.D.,l.36 ដែលមានន័យថា ខ្ញុំបម្រើម្នាក់ត្រូវបានថ្វាយជាពន្ធអាករ ដល់អាទិទេពខន្ទលិង្គ។ តាមរយៈឧទាហរណ៍នេះយើងអាចសង្កេតឃើញថា រូបសព្ទ "**ជំនោន**" ជាពាក្យកម្លាយចេញពីកិរិយាសព្ទ "**ជោន**" ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាលក្ខណៈសម្គាល់កម្មវាចកៈ។ ពាក្យ"**ក្ញុំ**"ស្ថិតនៅឆ្វេងកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់**កម្មវាចកៈ (រងអំពើ)**នៅក្នុងល្បះ ហើយ គេមិនបានបង្ហាញអំពីកម្មភ្នាក់ងារ

---

[6] សូមមើល G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME II, op.cit, P.41.

ដែលជាអ្នកធ្វើអំពើ។ ជាពិសេស កិរិយាសព្ទ "**ជាហ្វ**" នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ/-ɔmn-/ មកជាពាក្យកម្លាយ "**ជំនោងិ**" វិញ ហើយ ពាក្យ "**ជំនោងិ**" នៅក្នុងល្បះនេះមិនមែនជា"**នាមសព្ទ**"នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈសម្គាល់កម្មវាចកៈ។ ប្រសិនបើ ពាក្យ" **ជំនោងិ** " គឺជានាមសព្ទដែលមានន័យថា"**ការជូន ឬ ជំនូន**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ " **ជំនោងិ** " កាលពីមុន ដែលជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ "**ជោងិ**" ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈសម្គាល់កម្មវាចកៈ។

បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈ ទេនោះ គួរតែបុព្វបុរសយើងសរសេរថា "**(បោញ៊ វិទ្យាកុមារ) ជោងិ ក្ញុំ ១ អាករ ត វ្រះ កម្រតាង៑ អញ៑ ស្រី ខន្ទលិង្គ**" មានន័យថា *(បោញ៊ វិទ្យាកុមារ) ជូនខ្ញុំបម្រើជាពន្ធអាករដល់អាទិទេពស្រី ខន្ទលិង្គ* បែបនេះ ទើបសមថា ភាសាខ្មែរគ្មានលក្ខណៈសម្គាល់កម្មវាចកៈនោះ។ តាមរយៈល្បះនេះ យើងឃើញថា កន្សោមពាក្យ "**(បោញ៊ វិទ្យាកុមារ)**" មានមុខងារជាប្រធាន ដែលជាអ្នកធ្វើអំពើនៅក្នុងល្បះ ហើយ ពាក្យ "**ក្ញុំ ១ អាករ**" ជាកម្មបទ ដែលជាអ្នករងអំពើនៅក្នុងល្បះ។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ស្រេ ជំនាហ្វ អាយ៑ ល្វាង៑** sre jaṃnāhv āy lvāṅ[7] K.811, VII-VIII.A.D.,l.3 ដែលមានន័យថា ស្រែដែលបានទិញនៅឯល្វាង។ តាមរយៈឧទាហរណ៍នេះ យើងអាចសង្កេតឃើញថា រូបសព្ទ "**ជំនាហ្វ**" ជាពាក្យកម្លាយចេញពីកិរិយាសព្ទ "**ជាហ្វ**" ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាលក្ខណៈសម្គាល់កម្មវាចកៈ។ នៅក្នុងល្បះនេះ យើងសង្កេតឃើញថា ប្រធានដែលជាកម្មភ្នាក់ងារ ( អ្នកធ្វើអំពើ ) មិនត្រូវបានគេបង្ហាញ។ ចំណែកឯ កន្សោមពាក្យ"**ស្រេ**" ស្ថិតនៅពីឆ្វេងកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់**កម្មវាចកៈ(រងអំពើ)**នៅក្នុងល្បះ។ ជាពិសេស កិរិយាសព្ទ " **ជាហ្វ** "នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ /-ɔmn-/ មកជាពាក្យ កម្លាយ" **ជំនាហ្វ** "វិញ ហើយ ពាក្យ " **ជំនាហ្វ**"នៅក្នុង ល្បះនេះមិនមែនជា"**នាមសព្ទ**"នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈសម្គាល់កម្មវាចកៈ។ ប្រសិនបើ ពាក្យ "**ជំនាហ្វ**" គឺជានាមសព្ទដែលមានន័យថា "**ការជាវ ឬ ការទិញ**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ"**ជំនាហ្វ**" កាលពីមុនជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ" **ជាហ្វ** " ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈសម្គាល់កម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសសរសេរថា " **(ម្រតាញ៑ ស្វាមិ)ជាហ្វ ស្រេ អាយ៑ ល្វាង៑** " ដែលមានន័យថា *(ម្រតាញ៑ ស្វាមិ)ជាវស្រែនៅឯល្វាង* បែបនេះ ទើបសមថា ភាសាខ្មែរគ្មានលក្ខណៈសម្គាល់កម្មវាចកៈនោះ។ តាមរយៈល្បះនេះ

---

[៧] សូមមើល G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME VI, op.cit., P.63.

យើងឃើញថា កន្សោមពាក្យ "(**ម្រតាញ ស្វាមិ**)" មានមុខងារជាប្រធាន ដែលជាអ្នកធ្វើអំពើនៅក្នុងល្បះ ហើយ ពាក្យ"**ស្រែ**"ជាកម្មបទ ដែលជាអ្នករងអំពើ នៅក្នុងល្បះ។

តាមរយៈការបកស្រាយខាងលើ យើងអាចធ្វើការសន្និដ្ឋានបានថា ភាសាខ្មែរកាលពីសម័យមុនអង្គរមានការប្រើប្រាស់ល្បះដែលមានន័យកម្មវាចកៈ ហើយ យើងអាចទាញរូបមន្តបានថា :

| ប្រធាន(រងអំពើ)+ កិរិយាសព្ទ + Ø + កន្សោមនិបាត/កន្សោមធ្នាក់ |
|---|

កំណត់សម្គាល់ : សញ្ញា "Ø "នេះ គ្មានការបង្ហាញពីកម្មភ្នាក់ងារ(ធ្វើអំពើ) ។

## ១.១.២- លក្ខណៈនៃកម្មវាចកៈដែលប្រែប្រួលនៅក្នុងសម្ព័ន្ធ

យើងសង្កេតឃើញថា ល្បះដែលមានការប្រើពាក្យជំនួយ ដើម្បីបញ្ជាក់លក្ខណៈកម្មវាចកៈក្នុងអត្ថបទសិលាចារឹកនានានៅសម័យមុនអង្គរមាន :

កាលពីសម័យមុនអង្គរ ល្បះដែលបញ្ជាក់ន័យនៃលក្ខណៈកម្មវាចកៈ លោកសរសេរដោយការប្រែប្រួលមុខងារនៅក្នុងសម្ព័ន្ធ និង ជាពិសេស លោកសរសេរដោយមានការបញ្ជាក់ពីពេលកន្លងទៅដោយប្រើពាក្យ"មន៑/មាន៑ man/mān"ដាក់ពីខាងឆ្វេងកិរិយាសព្ទស្នូលនៅក្នុងល្បះ។ ពាក្យ"**មន៑**"នេះវចនានុក្រមខ្មែរបុរាណ(តាមសិលាចារឹកសតវត្សទី៦-៨)បានឱ្យនិយមន័យ ក្នុងន័យទី១ថា"*មាន បាន ជា អត្ថិភាព ម៉្យាងផងសំដែងចេញនូវអតីតកាលពេញលេញ*"[៨] និង ន័យទី២ "*ប្រើជាសន្ធានភ្ជាប់* "[៩]។ ពាក្យ "**មន៑**" នេះភ្ជាប់ទៅជាមួយកិរិយាសព្ទ ដើម្បីជាជំនួយនៃលក្ខណៈសម្គាល់ន័យកម្មវាចកៈ។

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : ស្រែ *មន៑ ទុញ្* ត ភវកីត្តិ.** sre man duñ ta bhavakīrtti K.22,VII.A.D,l.35[10], ដែលមានន័យថា *ស្រែមួយបានទិញដោយភវកីត្តិ* ។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា "**ប្រធាន**" ជាអ្នករងអំពើ ហើយ "**កម្មបទ**"ជាអ្នកធ្វើអំពើ បានសេចក្តីថា ពាក្យ "**ភវកីត្តិ**"នៅក្នុងល្បះនេះជាកម្មភ្នាក់ងារ (ធ្វើអំពើ)ហើយ ពាក្យ"**ស្រែ**"មានមុខងារជា"**ប្រធាន**"ជាអ្នករងអំពើ។ ដូច្នេះ យើងសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសយើងគួរសរសេរថា "**ភវកីត្តិ មន៑ ទុញ្ ស្រែ**"វិញ ដែលមានន័យថា មន្ត្រីភវកីត្តិបានទិញស្រែ។ នោះទើបសមថាល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតា ដែលមានទម្រង់ **ប្រធាន+កិរិយាសព្ទ+កម្មបទ** នោះ។

---

[៨] សូមមើល : ឡុង សៀម : ***វចនានុក្រមខ្មែរបុរាណ*** ជ.ឯ.ម. ២០០០. ទំព័រ ៤៥៣ ។

[៩] -ដ- ទំព័រ ៤៥៣ ។

[១០] -ដ- ទំព័រ ៣៣៦។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ស្រេ ផលទ *មនិ ជាហ្វ* ត កុរាក ជ្មេង**. sre phalada man jāhv ta kurāk jmeṅ K.493,657A.D.,l.20[11] ដែលមានន័យថា *ស្រែផលទបានទិញដោយកុរាកជ្មេង*។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា "**ប្រធាន**"ជាអ្នករងអំពើ ហើយ "**កម្មបទ**"ជាអ្នកធ្វើអំពើ បានសេចក្តីថា ពាក្យ"**កុរាក ជ្មេង**" នៅក្នុងល្បះនេះជាកម្មភ្ជាក់ងារ(ធ្វើអំពើ) ហើយ ពាក្យ"**ស្រេ ផលទ**"មានមុខងារជា"**ប្រធាន**"ជាអ្នករងអំពើ។ ដូច្នេះ យើងសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសខ្មែរគួរសរសេរថា " **កុរាក ជ្មេង មនិ ជាហ្វ ស្រេ ផលទ** " វិញនោះ ទើបសមថា ល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតា ដែលមានទម្រង់ **ប្រធាន + កិរិយាសព្ទ + កម្មបទ** នោះ ។

**ឧទាហរណ៍ទី៣នៃល្បះកម្មវាចកៈ : ស្រេ *មានិ ជាហ្វ* អំវិ ត វ្រះ កំម្រតាង អញ កំម្រាង ស្រុក** sre mān jāhv amvi ta vraḥ kammratāṅ añ kammrāṅ sruk K.79, 639.A.D.l.8-9[12] ដែលមានន័យថា ស្រែបានទិញ ដោយអភិបាលខេត្ត ។ តាមរយៈឧទាហរណ៍នេះ យើងឃើញថា ពាក្យ"**ស្រេ**"មានមុខងារជាប្រធាន (រងអំពើ) នៅក្នុងល្បះ ហើយ កន្សោមពាក្យ "**វ្រះ កំម្រតាង អញ កំម្រតាង ស្រុក** "មានមុខងារជាកម្មបទ (ធ្វើអំពើ)ទៅលើប្រធាននៅក្នុងល្បះ។ ដូច្នេះ យើងអាចសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសយើងគួរសរសេរថា " **វ្រះ កំម្រតាង អញ កំម្រតាង ស្រុក *មានិ ជាហ្វ* ស្រេ** វិញនោះ ទើបសមថា ល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតា ដែលមានទម្រង់ **ប្រធាន + កិរិយាសព្ទ + កម្មបទ** នោះ។ ដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា នៅសម័យមុនអង្គរមានការប្រើប្រាស់ល្បះដែលមានលក្ខណៈកម្មវាចកៈនេះ ដោយការប្រើពាក្យជំនួយ ដើម្បីបង្កើតល្បះដែលមានលក្ខណៈកម្មវាចកៈ។ ដូច្នេះ យើងអាចគោងរូបមន្តលក្ខណៈកម្មវាចកៈដោយការប្រើពាក្យជំនួយបាន :

| ប្រធាន(រងអំពើ)+ មនិ/មានិ + ត + កម្មភ្នាក់ងារ(ធ្វើអំពើ) |
|---|

## ១.២- ការប្រើប្រាស់កម្មវាចកៈសម័យអង្គរ

តាមរយៈសិលាចារឹកសម័យអង្គរ យើងសង្កេតឃើញមានការប្រើប្រាស់កម្មវាចកៈ ដោយការប្រើអន្តែបទទម្រង់ /-ɔmn-/ ផ្សំជាកិរិយាសព្ទដើមបង្កើតបានពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់ប្រើប្រាស់ជាលក្ខណៈកម្មវាចកៈ និង មានការប្រើប្រាស់លក្ខណៈកម្មវាចកៈ ដោយមានពាក្យជំនួយផងដែរ។

---

[11] សូមមើល : ឡុង សៀម : ***វចនានុក្រមខ្មែរបុរាណ*** ជ.ឯ.ម. ២០០០. ទំព័រ ២៣៧។

[12] -ដ- ទំព័រ ២៣៧។

១.២.១- ការប្រែប្រួលរូបសព្ទ

យើងសង្កេតឃើញថា សម័យអង្គរមានការប្រើល្បះដែលមានលក្ខណៈកម្មវាចកៈនេះ ដោយការប្រើប្រាស់អន្តេបទ /-ɔmn-/ ផ្សំជាមួយកិរិយាសព្ទ ដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ ដូច នៅសម័យមុនអង្គរផងដែរ ។

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : អនក់ ជំនួន កម្រតេង អញ លក្សីន្ទ្រទេវី** anak jaṃnvan kamrateṅ añ lakṣmīndradevī[១៣] K.313b, 879A.D., 1.32 ដែលមានន័យថា មនុស្ស (ខ្ញុំបម្រើ) ថ្វាយ (ដោយ) កម្រតេងអញលក្សីន្ទ្រទេវី ។

តាមរយៈល្បះនេះ យើងអាចសង្កេតឃើញថា រូបសព្ទ "**ជំនួន**" ជាពាក្យកម្លាយចេញពីកិរិយាសព្ទ "**ជូន**" ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺកន្សោមពាក្យ " **កម្រតេង អញ លក្សីន្ទ្រទេវី** "ស្ថិតនៅខាងក្រោយកិរិយាសព្ទ "**ជំនួន**" ដែលបានក្លាយទៅជា**កម្ម**ហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)** ។ ចំណែកឯ កន្សោមពាក្យ"**អនក់** " ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធាន ក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ) នៅក្នុងល្បះ ។ ជាពិសេស កិរិយាសព្ទ "**ជូន** "នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ /-ɔmn-/ មកជាពាក្យកម្លាយ "**ជំនួន**" វិញ ហើយ ពាក្យ"**ជំនួន** "នៅក្នុងល្បះនេះមិនមែនជា"**នាមសព្ទ**" នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ ។ ប្រសិនបើ ពាក្យ" **ជំនួន** " គឺជានាមសព្ទដែលមានន័យថា "**ដង្វាយ ឬ ការជូន ការថ្វាយ,.**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ" **ជំនួន** "កាលពីមុនជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ " **ជូន** " ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈ ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសសរសេរថា " **កម្រតេង អញ លក្សីន្ទ្រទេវី ជូន អនក់** " ដែលមានន័យថា *កម្រតេងអញ លក្សីន្ទ្រទេវីថ្វាយមនុស្ស(ខ្ញុំបម្រើ)* បែបនេះទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ ។ តាមរយៈល្បះនេះ យើងឃើញថា កន្សោមពាក្យ " **កម្រតេង អញ លក្សីន្ទ្រទេវី** " មានមុខងារជាប្រធាន ដែលជាអ្នកធ្វើអំពើនៅក្នុងល្បះ ហើយ ពាក្យ"**អនក់**"មានមុខងារជាកម្មបទ ដែលជាអ្នករងអំពើនៅក្នុងល្បះ ។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ខ្ញុំ ជំនួន តេង មាធវី** khñuṃ jaṃnvan teṅ mādhavī K.240, 979A.D., 1.10 ដែលមានន័យថា ខ្ញុំបម្រើថ្វាយ (ដោយ) អ្នកស្រី តេង មាធវី ។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា រូបសព្ទ "**ជំនួន**" ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ"**ជូន**"ជារូបសព្ទនៃកិរិយា-

---

[១៣] Saveros Pou , **NOUVELLES INSCRIPTINS DU CAMBDGE**,II&III, Paris,2001,P.36

សព្ទ ដែលប្រើជាកម្មវាចកៈ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺ កន្សោមពាក្យ " **តេង មាធវី** "ស្ថិតនៅខាងក្រោយកិរិយាសព្ទ" **ជំនូន** " ដែលបានក្លាយទៅជាកម្ម ហៅថា កម្មភ្នាក់ងារ (ធ្វើអំពើ)។ ចំណែកឯ កន្សោមពាក្យ " **ខ្ញុំ** " ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារ ជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ(រងអំពើ)នៅក្នុងល្បះ។ ជាពិសេស កិរិយាសព្ទ "**ជូន** "នេះបាន ផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ/-ɔmn-/ មកជាពាក្យកម្លាយ" **ជំនូន** "វិញ ហើយ ពាក្យ " **ជំនូន** " នៅក្នុងល្បះនេះមិនមែនជា"**នាមសព្ទ**"នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។

ប្រសិនបើ ពាក្យ" **ជំនូន** " គឺជានាមសព្ទដែលមានន័យថា "**អំណោយ ឬ ការជូន ការថ្វាយ,...**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ " **ជំនូន** "កាលពីមុន ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ" **ជូន** " ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈ។ បើកាល ណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសយើងសរសេរថា " **តេង មាធវី ជូន ខ្ញុំ** " មានន័យថា *អ្នកស្រី តេង មាធវី ថ្វាយខ្ញុំបម្រើ* បែបនេះទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈ នោះ។ តាមរយៈល្បះនេះ យើងឃើញថា កន្សោមពាក្យ " **តេង មាធវី** " មានមុខងារជាប្រធាន ដែលជា អ្នកធ្វើអំពើនៅក្នុងល្បះ ហើយ ពាក្យ"**ខ្ញុំ**"មានមុខងារជាកម្មបទ ដែលជាអ្នករងអំពើនៅក្នុងល្បះ។

**ឧទាហរណ៍ទី៣នៃល្បះកម្មវាចកៈ : ស្រេ *ជំនូន* វាប បិ** sre jamnvan vāp pi K.780, X. A.D.l.24[១៤] ដែលមានន័យថា ស្រែ បានជូនដោយវាប បិ ។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា រូបសព្ទ " **ជំនូន** " ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ"**ជូន**"ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ។ នៅក្នុង ល្បះនេះ យើងសង្កេតឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺពាក្យ " **វាប បិ** "ស្ថិតនៅខាងក្រោយ កិរិយាសព្ទ " **ជំនូន** " ដែលបានក្លាយទៅជា**កម្ម** ហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)** ។ ចំណែកឯ ពាក្យ "**ស្រែ**" ស្ថិតនៅពីមុខកិរិយាសព្ទ ដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ(រងអំពើ) នៅក្នុង ល្បះ។ ជាពិសេស កិរិយាសព្ទ "**ជូន** "នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ /-ɔmn-/ មកជាពាក្យកម្លាយ"**ជំនូន** " វិញ។ ប្រសិនបើ ពាក្យ" **ជំនូន** " គឺជានាមសព្ទដែលមានន័យថា "**ការជូនឬ របស់របរ**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា ពាក្យ" **ជំនូន** "កាលពីមុនជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ "**ជូន** " ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈកម្ម វាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសយើងសរសេរថា **វាប បិ ជូន ស្រែ** ដែលមានន័យថា *វាប បិ ជូនស្រែ* បែបនេះទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

---

[១៤] G. COEDÈS : **INSCPITIONS DU CAMBODGE**, VOLUME VI, PARIS 1954, P.151.

ឧទាហរណ៍ទី៣នៃល្បះកម្មវាចកៈ : **អំវិ ត ប្លុ តទិង ទៅ ឧត្តរ ប្រសប ស្រែ** *ទំនុញ* **ឆ្លោញ វិទ្យាមយ** "aṃvi ta plu tadiṅ dau uttara prasap sre *daṃnuñ* chloñ vidyāmaya"[១៥] K.843C,1025 A.D.,l.29, ដែលមានន័យថា (ដីស្រែ) ពីផ្លូវទទឹងទៅទិសឧត្តររហូតដល់ស្រែ បានទិញដោយឆ្លោញវិទ្យាមយ ។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា រូបសព្ទ " **ទំនុញ** "ជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ"**ទុញ**" ជារូបសព្ទនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ នៅក្នុងសម័យអង្គរ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធាន គឺពាក្យ "**ឆ្លោញ វិទ្យាមយ**"ស្ថិតនៅខាងក្រោយកិរិយា-សព្ទ "**ទំនុញ**" ដែលបានក្លាយទៅជា**កម្ម** ហៅថា **កម្មភ្ជាក់ងារ (ធ្វើអំពើ)** ។ ចំណែកឯ កន្សោមពាក្យ "**អំវិ ត ប្លុ តទិង ទៅ ឧត្តរ ប្រសប ស្រែ**" ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធាន ក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ) នៅក្នុងល្បះ។ ជាពិសេស កិរិយាសព្ទ " **ទុញ** " នេះបានផ្លាស់ប្តូររូបសព្ទរបស់ខ្លួន ដោយផ្សំជាមួយអន្តែបទ /-ɔmn-/ មកជាពាក្យកម្លាយ"**ទំនុញ**" វិញ ហើយ ពាក្យ" **ទំនុញ** " នៅក្នុងល្បះនេះមិនមែនជា "**នាមសព្ទ**" ទេ វាគឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើពាក្យ"**ទំនុញ**" គឺជានាមសព្ទដែលមានន័យថា "**ទំនិញឬរបស់របរសម្រាប់ដោះដូរ** ឬក៏ **របស់របរសម្រាប់លក់នោះ**"នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ"**ទំនុញ**" កាលពីមុនជាពាក្យកម្លាយកើតចេញពីកិរិយាសព្ទ "**ទុញ**" ដែលជាកិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសសរសេរថា **ឆ្លោញ វិទ្យាមយ ទំនុញ អំវិ ត ប្លុ តទិង ទៅ ឧត្តរ ប្រសប ស្រែ** ដែលមានន័យថា *ឆ្លោញវិទ្យាមយបានទិញ (ដីស្រែ) ពីផ្លូវទទឹងទៅទិសឧត្តររហូតដល់ស្រែ* បែបនេះ ទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

តាមរយៈការបកស្រាយឧទាហរណ៍ខាងលើ គេអាចធ្វើការសន្និដ្ឋានបានថា ភាសាខ្មែរសម័យអង្គរ មានការប្រើប្រាស់ល្បះដែលមានន័យកម្មវាចកៈ ដោយការយកអន្តែបទ /-ɔmn-/ ដើម្បីបង្កើតល្បះដែលមានន័យកម្មវាចកៈ។ ដូច្នេះ យើងអាចទាញរូបមន្តបានថា :

| ប្រធាន(រងអំពើ)+ កិរិយាសព្ទ + កម្មភ្នាក់ងារ(ធ្វើអំពើ) |
|---|

១.២.២- លក្ខណៈនៃកម្មវាចកៈដែលប្រើពាក្យជំនួយ " គិ ti"

តាមរយៈសិលាចារឹកសម័យអង្គរ យើងសង្កេតឃើញមានការប្រើប្រាស់លក្ខណៈកម្មវាចកៈ

[១៥] G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME VII, PARIS 1964, P.112.

មួយបែបទៀត ដោយការប្រើពាក្យ "តិ"[១៦] ជារូបសព្ទសម្រាប់ដាក់ពីខាងឆ្វេងកិរិយាសព្ទ ដើម្បីបង្កើតលក្ខណៈកម្មវាចកៈ ។

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : ភូមិ វគ្គិ ខ្មាប្ប តិ ទុញ វាបិ អំមូត**.bhūmi vargga khmāpp *ti duñ* vāp ammṛta[១៧] K.265S,959A.D.l.23, ដែលមានន័យថា ដីភូមិរបស់អ្នកកាប់អុសបានទិញ ដោយមន្ត្រី(ឈ្មោះ) វាប អំមូត ។

តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា ពាក្យ "**វាបិ អំមូត**" ដែលជាអ្នកធ្វើអំពើក្លាយជា **កម្ម** នៅក្នុងល្បះ ដែលហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)** ហើយ កន្ទ្រោមពាក្យ "**ភូមិ វគ្គិ ខ្មាប្ប**" ដែលជាអ្នករងអំពើក្លាយជាប្រធានរបស់កិរិយាសព្ទ "**ទុញ**" ដែលភ្ជាប់ទៅដោយរូបសព្ទ "**តិ**" នៅក្នុងល្បះ តែនៅរងអំពើដដែល ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ "**តិ ទុញ**" កាលពីមុនជាពាក្យ ដែលផ្សំឡើង ដើម្បីសម្គាល់កិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈផងដែរ ។ បើកាលណាភាសាខ្មែរ គ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសយើងសរសេរថា **វាបិ អំមូត ទុញ ភូមិ វគ្គិ ខ្មាប្ប** ដែលមានន័យថា មន្ត្រី(ឈ្មោះ) *វាប អំមូត ទុញដីភូមិរបស់អ្នកកាប់អុស* បែបនេះ ទើបសមថា ភាសាខ្មែរ គ្មានលក្ខណៈកម្មវាចកៈ នោះ ហើយ ស្ថិតនៅក្នុងលក្ខណៈជាកត្តុវាចកៈ ។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ភូមិ ភោគេស្វរ តិ ទារ៑ ព្រះករុណា ប្រសាទ**. bhūmi bhogeçvara ti dār braḥ karuṇā prasāda[១៨] K.153, 1001A.D.,l.3 ដែលមានន័យថា ដីភូមិភោគេស្វរ ត្រូវបាន ថ្វាយដោយព្រះរាជទាន ។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា កន្ទ្រោមពាក្យ " **ព្រះករុណា ប្រសាទ** " ដែលជាអ្នកធ្វើអំពើក្លាយជា**កម្ម** នៅក្នុងល្បះ ដែលហៅថា **កម្មភ្នាក់ងារ (ធ្វើអំពើ)** ហើយ កន្ទ្រោមពាក្យ " **ភូមិភោគេស្វរ** " ដែលជាអ្នករងអំពើក្លាយជាប្រធានរបស់កិរិយាសព្ទ "**ទារ៑** " ដែលភ្ជាប់ ទៅដោយរូបសព្ទ "**តិ**" នៅក្នុងល្បះ ប៉ុន្តែនៅរងអំពើដដែល ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ "**តិ ទារ៑** "កាលពីមុនជាពាក្យដែលផ្សំឡើង ដើម្បីសម្គាល់កិរិយាសព្ទប្រកបដោយលក្ខណៈកម្មវាចកៈ ដែរ ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសយើងសរសេរថា **ព្រះករុណា ប្រសាទ ទារ៑ ភូមិភោគេស្វរ** ដែលមានន័យថា *ព្រះករុណាប្រទានដីភូមិភោគេស្វរ* បែបនេះទើប សមថា ភាសាខ្មែរគ្មានលក្ខណៈ កម្មវាចកៈនោះ ហើយ ស្ថិតនៅក្នុងលក្ខណៈកត្តុវាចកៈ ។

---

[១៦] ជាចុណ្ណសព្ទប្រើប្រាស់ពីមុខកិរិយាសព្ទ ដើម្បីបញ្ជាក់ពីកម្មវាចកៈ ដែលមានន័យថា ដែល ត្រូវ ។

[១៧] G. COEDÈS : **INSCPITIONS DU CAMBODGE**, VOLUME IV, PARIS 1952, P.103.

[១៨] G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME V, PARIS 1953, P.195.

ដូច្នេះ យើងអាចទាញរូបមន្តបានថា :

| |
|---|
| ប្រធាន(រងអំពើ)+ **ត** + កិរិយាសព្ទ + កម្មភ្នាក់ងារ (ធ្វើអំពើ) |

## ២. ការវិវត្តនៃលក្ខណៈកម្មវាចកៈ

តាមការសិក្សាស្រាវជ្រាវលើសិលាចារឹក យើងខ្ញុំសង្កេតឃើញថា មានការវិវត្តនៃលក្ខណៈកម្ម-វាចកៈ នៅក្នុងភាសាខ្មែរសម័យអង្គរ ដូចតទៅ :

### ២.១-ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រែប្រួលរូបសព្ទ

យើងខ្ញុំសង្កេតឃើញថា នៅក្នុងសម័យមុនអង្គរនិងសម័យអង្គរ ភាសាខ្មែរមានការប្រើល្បះដែលសម្គាល់លក្ខណៈកម្មវាចកៈ ដោយមានការប្រែប្រួលរូបសព្ទ ដូច កិរិយាសព្ទ "**ជាហ្វ**" ទៅជា "**ជំនាហ្វ**" ដែលស្ថិតនៅក្នុងប្រភេទពាក្យជាកិរិយាសព្ទ ដូច កិរិយាសព្ទដើមដែរ ។

#### ២.១.១-ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រែប្រួលរូបសព្ទ ពីសម័យមុនអង្គរមកសម័យអង្គរ

ល្បះដែលមានលក្ខណៈកម្មវាចកៈដែលប្រែប្រួលរូបសព្ទ ពីសម័យមុនអង្គរមកដល់សម័យអង្គរ យើងសង្កេតឃើញថា មិនមានលក្ខណៈសម្គាល់ដោយមានភាពច្បាស់លាស់ទេ គ្រាន់តែសម័យមុនអង្គរ ល្បះមួយចំនួនធំដែលមានលក្ខណៈសម្គាល់កម្មវាចៈ ដោយមានការប្រើភ្ជាប់ចុល្លសព្ទ[១៩] " **ត** " នៅពីខាងមុខកិរិយាសព្ទ ដើម្បីភ្ជាប់ទៅនឹងកម្មបទ ដែលហៅថា **កម្មភ្នាក់ងារ(ធ្វើអំពើ)** ។

**ឧទាហរណ៍ទី១នៃល្បះកម្មវាចកៈ : ស្រែ ត្នៃ កេត ត្រវាង បោញ ភាគយុង *ទំនុញ* ត បោញ ភទ្រវិសេស** sre tnai ket travaṅ poñ bhāgayuṅ daṃnuñ ta poñ bhadraviçeṣa K.22,VII.A.D,l.32[២០], ស្រែខាងកើតត្រពាំងបោញភាគយុងទិញដោយបោញភទ្រវិសេស ។ លុះមកដល់សម័យអង្គរ យើងសង្កេតឃើញថា ល្បះដែលមានលក្ខណៈសម្គាល់កម្មវាចកៈ ដោយមិនមានការប្រើភ្ជាប់ចុល្លសព្ទ "**ត** " ដូចនៅសម័យមុនអង្គរឡើយ ។

**ឧទាហរណ៍ទី២នៃល្បះកម្មវាចកៈ : ស្រេ *ជំនួន* វាប បិ** sre jaṃnvan vāp pi K.780, X.A.D.l.24[២១] ដែលមានន័យថា ដីស្រែបានជូនដោយវាប បិ ។ តាមរយៈឧទាហរណ៍នេះ យើងឃើញថា កន្សោមពាក្យ " **វាប បិ** " ដែលជា អ្នកធ្វើអំពើក្លាយជា**កម្ម** នៅក្នុងល្បះ ដែលហៅថា **កម្មភ្នាក់ងារ (ធ្វើអំពើ)** ហើយ

---

[១៩] យើងខ្ញុំ សូមប្រើបច្ចេកសព្ទ " **ចុល្លសព្ទ** " នេះ ត្រូវនឹងពាក្យបារាំងថា " **particule** " ដែលមិនមានន័យដោយខ្លួនឯង ។

[២០] សូមមើល : ឡុង សៀម : ***វចនានុក្រមខ្មែរបុរាណ*** ជ.ឯ.ម. ២០០០ ទំព័រ ៣២៩ ។

[២១] G. COEDÈS : INSCPITIONS DU CAMBODGE, VOLUME VI, PARIS 1954, P.151.

កន្សោមពាក្យ "**ស្រែ**" ដែលជាអ្នករងអំពើក្លាយជាប្រធានរបស់កិរិយាសព្ទ "***ជំនូន***" ដែលក្លាយមកពីកិរិយាសព្ទ "***ជូន***" ផ្សំជាមួយ អន្តបទ /-ɔmn-/ តែ នៅរងអំពើដដែល ។ បើកាលណា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែបុព្វបុរសសរសេរថា **វាប បិ ជូន ស្រែ** ដែលមានន័យថា *វាប បិ ជូនដីស្រែ* បែបនេះ ទើបសមថា ភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ ហើយ ស្ថិតនៅក្នុងលក្ខណៈកត្តុវាចកៈ ។

### ២.១.២-ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រែប្រួលរូបសព្ទ ពីសម័យអង្គរមកសម័យបច្ចុប្បន្ន

ល្បះដែលមានលក្ខណៈសម្គាល់កម្មវាចកៈ ដោយការប្រែប្រួលរូបសព្ទ ពីសម័យអង្គរមកដល់សម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញថា មិនមានការប្រើលក្ខណៈសម្គាល់កម្មវាចកៈ ដោយការប្រើ អន្តបទ /-amn-/និង/-ɔmn-/ ផ្សំជាមួយកិរិយាសព្ទ ដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទ សម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ ដូចនៅសម័យមុនអង្គរនិងអង្គរទេ ។ ដោយហេតុថា កិរិយាសព្ទ ដែលសម្គាល់លក្ខណៈកម្មវាចកៈនៅសម័យមុនអង្គរ ក៏ដូចសម័យអង្គរ មកដល់បច្ចុប្បន្ននេះរូបសព្ទទាំងនេះ បានក្លាយទៅជានាមសព្ទ ដូច រូបសព្ទ "**អំនោយ**" បានក្លាយទៅជានាមសព្ទ "**អំណោយ**" ដែលមានន័យថា "**ទាន ឬ តង្វាយ**", រូបសព្ទ "**ទំនុញ**" បានក្លាយទៅជានាមសព្ទដែលមានន័យថា "**ទំនិញឬរបស់របរ សម្រាប់ដោះដូរ** ឬក៏ **របស់របរសម្រាប់លក់នោះ**" អស់ទៅហើយ ។

**ឧទាហរណ៍** : - អំណោយរបស់រាជរដ្ឋាភិបាល ផ្ដល់ឱ្យជនរងគ្រោះដោយសារគ្រោះធម្មជាតិ ។

- ទំនិញត្រូវបានគេដឹកចេញពីកំពង់ផែខេត្តព្រះសីហនុ ។

តាមរយៈឧទាហរណ៍ទាំងពីរនេះ យើងសង្កេតឃើញថា ពាក្យ "អំណោយ"និង"ទំនិញ" ជានាមសព្ទ ។

### ២.២- ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រើរូបសព្ទជំនួយ

យើងសង្កេតឃើញថា នៅក្នុងសម័យមុនអង្គរ សម័យអង្គរ រហូតដល់បច្ចុប្បន្ន ភាសាខ្មែរមានការប្រើល្បះដែលមានលក្ខណៈសម្គាល់ន័យកម្មវាចកៈ ដោយមានការប្រើរូបសព្ទជំនួយ ដូចតទៅ +

### ២.២.១- ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រើរូបសព្ទជំនួយ ពីសម័យមុនអង្គរមកសម័យអង្គរ

ល្បះដែលមានលក្ខណៈសម្គាល់កម្មវាចកៈ ដោយប្រើរូបសព្ទជំនួយនៅសម័យមុនអង្គរ យើងសង្កេតឃើញថា មិនមានការប្រើរូបសព្ទជំនួយ ដើម្បីសម្គាល់លក្ខណៈកម្មវាចកៈទេ នៅសម័យមុនអង្គរ ។ លុះមកដល់សម័យអង្គរ ទើបយើងប្រទះឃើញមានការប្រើរូបសព្ទជំនួយ ដើម្បីសម្គាល់ល្បះដែលមានលក្ខណៈកម្មវាចកៈ ដោយការប្រើភ្ជាប់រូបសព្ទ "**តិ**" ដោយមានទីតាំងនៅខាងឆ្វេងនៃកិរិយាសព្ទបង្គោលនៅក្នុងល្បះ ។

**ឧទាហរណ៍ : ភូមិ វគ៌្គ ខ្មាប្ប *តិ ទុញ្* វាបិ អំម្ឫត**.bhūmi vargga khmāpp *ti duñ* vāp ammṛta[២២] K.265 S, 959 A.D.I.23, ដែលមានន័យថា ដីភូមិរបស់អ្នកកាប់អុសបានទិញដោយវាប អំម្ឫត។

២.២.២- ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រើរូបសព្ទជំនួយ ពីសម័យអង្គរមកសម័យបច្ចុប្បន្ន

ការវិវត្តនៃលក្ខណៈកម្មវាចកៈដែលប្រើរូបសព្ទជំនួយ ពីសម័យអង្គរមកសម័យបច្ចុប្បន្ន យើងសង្កេតឃើញថា សម័យអង្គរមានការប្រើរូបសព្ទ"**តិ**"ដាក់ខាងឆ្វេងកិរិយាសព្ទបង្គោល (ដូចមានការបង្ហាញក្នុងចំណុច ១.២.២-លក្ខណៈនៃកម្មវាចកៈដែលប្រើពាក្យជំនួយ"តិ ti") ។ លុះមកដល់សម័យបច្ចុប្បន្ន យើងមានការប្រើរូបសព្ទជំនួយ "**ដោយ, ត្រូវ, ត្រូវបាន,...**" ដើម្បីសម្គាល់លក្ខណៈកម្មវាចកៈ (ត្រង់ចំណុចនេះ យើងខ្ញុំនឹងបង្ហាញនៅក្នុង ជំពូកទី៣ ល្បះកម្មវាចកៈប្រើកិរិយាជំនួយ) ។

តាមរយៈនៃការសិក្សាវិភាគទៅលើសិលាចារឹកទាំងក្នុងសម័យមុនអង្គរ និង សម័យអង្គរ ដូចដែលបានសិក្សាខាងលើ គេអាចសន្និដ្ឋានបានថា ការប្រើប្រាស់លក្ខណៈសម្គាល់ន័យកម្មវាចកៈ ដោយការប្រើអន្តេបទ/-amn-/និង/-ɔmn-/ ផ្សំជាមួយកិរិយាសព្ទ ដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ និង ការប្រើចុណ្ណសព្ទ"particule" ដាក់ពីខាងឆ្វេងកិរិយាសព្ទ ដើម្បីបង្កើតលក្ខណៈកម្មវាចកៈ ។

[២២] G. COEDÈS : **INSCPITIONS DU CAMBODGE**, VOLUME IV, PARIS 1952, P.103.

## គន្ថនិទ្ទេស

**១- ជាភាសាបរទេស**


- ច័ន្ទ សំណព្វ : " នាមខ្មែរគ្មានភេទនិងវចនៈទេ" នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៣, លេខ ៤២, ខែ មករា-កុម្ភៈ-មីនា ឆ្នាំ២០០៣។
- ច័ន្ទ សំណព្វ : " ជុំវិញបញ្ហាបំលាស់ប្ដូរបំរើបំរាស់និងការបង្កើតពាក្យក្នុងភាសាខ្មែរទំនើប " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៣, លេខ ៤៤, ខែ កក្កដា-សីហា-កញ្ញា ឆ្នាំ២០០៣។
- ច័ន្ទ សំណព្វ : " វាក្យស័ព្ទនាម " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៤, លេខ ៤៦, ខែ មករា-កុម្ភៈ-មីនា ឆ្នាំ២០០៤។
- ច័ន្ទ សំណព្វ : " ផ្នែកមួយនៃអក្ខរាវិរុទ្ធខ្មែរ " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៦, លេខ ៥៥, ខែ មេសា-ឧសភា-មិថុនា ឆ្នាំ២០០៦។
- ច័ន្ទ សំណព្វ : " ព្យាង្គតំរូតក្នុងសម័យខេមរយានកម្ម " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៦, លេខ ៥៧, ខែ តុលា-វិច្ឆិកា-ធ្នូ ឆ្នាំ២០០៦។
- ច័ន្ទ សំណព្វ : " ធាតុនៃវេយ្យាករណ៍ ដែលប្រើសំរាប់បង្កើតពាក្យក្នុងភាសាខ្មែរ " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៧, លេខ ៥៨, ខែ មករា-កុម្ភៈ-មីនា ឆ្នាំ២០០៧។
- ច័ន្ទ សំណព្វ : " ធាតុនៃវេយ្យាករណ៍ ដែលប្រើសំរាប់បង្កើតពាក្យក្នុងភាសាខ្មែរ " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៧, លេខ ៥៨, ខែ មករា-កុម្ភៈ-មីនា ឆ្នាំ២០០៧។
- ច័ន្ទ សំណព្វ : " ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ *ការ* និងផ្នត់ចែក[-អំម/ណ-] / [-អំម/ន-]" នៅក្នុង : ***ទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ,*** ឆ្នាំទី៣៧, លេខ ៥៨, ខែ មេសា- ឧសភា- មិថុនា ឆ្នាំ២០០៧។
- ច័ន្ទ សំណព្វ : "ពាក្យកម្លាយ និង ពាក្យក្លាយ "នៅក្នុង : ***ទស្សនាវដ្ដី រាជបណ្ឌិតសភាកម្ពុជា*** ,លេខ ១ ឆមាសទី១ ឆ្នាំ២០០៩។
- ចែល ចោង :"កម្មវាចកៈក្នុងភាសាខ្មែរ" ,នៅក្នុង: ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា,*** លេខ ០២ មិថុនា ២០០១។
- នៅ ស៊ុន : "ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់ និង ភាសាមិនមែនអ៊ីសូឡង់ " នៅក្នុង : Sorn Samnang (Ed.) ***ខេមរវិទ្យា*** volume II, ១៩៩៩។
- នៅ ស៊ុន : "ភាសា និង ការបែងចែកជាអំបូរភាសា " នៅក្នុង : ***ទស្សនាវដ្ដី រាជបណ្ឌិតសភាកម្ពុជា ,*** លេខ ១ ឆមាសទី១ ឆ្នាំ២០០៩។
- ពុទ្ធសាសនបណ្ឌិត្យ : ***វចនានុក្រមខ្មែរ*** , បោះពុម្ពគ្រាទី៥ , ភ្នំពេញ ,ឆ្នាំ ១៩៦៧-៦៨។
-ព្រុំ ម៉ល់ :"លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យក្នុងភាសាខ្មែរ" , នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថាន***

***ភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** . លេខ ០២ មិថុនា ២០០១ ។
- ព្រុំ ម៉ល់ : "អំពីលក្ខណៈវិនិច្ឆ័យរូបនិយម" .នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** . លេខ ០៣ ឧសភា ២០០២ ។
- ព្រុំ ម៉ល់ : " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម" . នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** . លេខ ០៣ ឧសភា ២០០២ ។
- ព្រុំ ម៉ល់ : ***មូលដ្ឋាននៃសង្គមភាសាវិទ្យា*** .ផ្សាយដោយអ្នកនិពន្ធ. ភ្នំពេញ. ២០០៣ ។
- ព្រុំ ម៉ល់ : ***មូលដ្ឋាននៃ សូរវិទ្យា ស័ទ្ទតាវិទ្យា និង វិជ្ជាសន្ទាន*** . ផ្សាយដោយអ្នកនិពន្ធភ្នំពេញ . ២០០៣ ។
- ព្រុំ ម៉ល់ : ***មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ*** . ផ្សាយដោយអ្នកនិពន្ធ ភ្នំពេញ. ២០០៣ ។
- ព្រុំ ម៉ល់ : "ចំណុចគួរកត់សម្គាល់ ក្នុងភាសាខ្មែរបច្ចុប្បន្ន" . នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** . ឆ្នាំទី៤ លេខ ៤ ខែកញ្ញា គ.ស. ២០០៣ ។
- ព្រុំ ម៉ល់ : ***វេយ្យាករណ៍ទម្រង់និយម នៃភាសាខ្មែរទំនើប?*** ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ . ២០០៦ ។
- មាឃ បូរ៉ា : ***ការស្រាវជ្រាវវេយ្យាករណ៍ភាសាខ្មែរបុរេអង្គរ.*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១. រាជបណ្ឌិតសភាកម្ពុជា. ២០០២ ។
- ឡុង សៀម : " អំពីកិត្យានុភាព និងការអភិវឌ្ឍន៍ភាសាខ្មែរ ( ជាពិសេសតាមឯកសារភាសា មន-ខ្មែរ និងសិលាចារឹកកម្ពុជា)" នៅក្នុង : ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា*** , លេខ០២ មិថុនា ២០០១ ។
- ឡុង សៀម : ***អំពីភាសាវិទ្យា និងភាសាខ្មែរ*** . មហាវិទ្យាល័យបុរាណវិទ្យា . ២០០០ ។
- ឡុង សៀម : ***បញ្ហាវចនសព្ទវិទ្យាខ្មែរ*** . ផ្សាយដោយអ្នកនិពន្ធ . ភ្នំពេញ ១៩៩៩ ។
- ឡុង សៀម : ***ស្ថាននាមវិទ្យាខ្មែរ*** . ពុទ្ធសាសនបណ្ឌិត្យ . ភ្នំពេញ ១៩៩៧ ។
- វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា : ***វចនានុក្រមអក្សរវិរុទ្ធនៃភាសាខ្មែរ.*** ភ្នំពេញ.២០០៥ ។
- ឡុង សៀម : ***វចនានុក្រមខ្មែរបុរាណ*** ( តាមសិលាចារឹកសតវត្សទី៦-៨) ,រោងពុម្ពភ្នំពេញ . ២០០០ ។

**២- ជាភាសាបរទេស**

-Chomsky Noam, ***Syntactic Structures***. Mouton: The Hague, 1957.
-Chomsky Noam, ***Aspects of the Theory of Syntax***, MIT Press: Cambridge, Mass, 1965;
- G. Coedès, ***Inscriptions du Cambodge,*** Hanoi, BEFEO,Volume I, 1937.
- G. Coedès, ***Inscriptions du Cambodge,*** Hanoi, BEFEO,Volume II, 1942.
- G. Coedès, ***Inscriptions du Cambodge,*** Paris, BEFEO,Volume III, 1951.
- G. Coedès, ***Inscriptions du Cambodge,*** Paris, BEFEO,Volume IV, 1952.
- G. Coedès, ***Inscriptions du Cambodge,*** Paris, BEFEO,Volume V, 1953.
- G. Coedès, ***Inscriptions du Cambodge,*** Paris, BEFEO,Volume VI, 1954.
- G. Coedès, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVII, 1964.
- G. Coedès,***Inscriptions du Cambodge,*** Paris, BEFEO,VolumeVIII, 1966.
-Jenner Philip N, ***A chrestomathy of Pre-Angorian Khmer I, Dated Inscriptions from the seventh and Eighth Cenyuries( A.D.611-781),*** University of Hawaii, White Lotus, 1980.
-Jenner Philip N, ***A chrestomathy of Pre-Angorian Khmer II, Lexicon of the Dated***

*Inscriptions,* University of Hawaii, Publication by Author, 1981 .
-Jenner Philip N, ***A chrestomathy of Pre-Angorian Khmer III, Undated Inscriptions fram the Sixth to the Eighth Century,*** University of Hawaii, Publication by Author, 1988.
-Jenner Philip N, ***A chrestomathy of Pre-Angorian Khmer IV, Lexicon of the Undated Inscriptions,*** University of Hawaii, Publicaion by Author, 1982 .
-Judith M.Jacob, ***Introduction to Cambodian,*** Oxford University Press, London, 1968 ;
-Judith Jacob, ***Cambodian linguistic, literature and history,*** School of Oriental and African Studies, University of London 1993;
-Judith M.Jacob, ***Prefixation and infixation in old Mon,old Khmer, and modern Khmer, Cambodian linguistics, Literature and history, Collected Article,***University of London, 1993;
-L'académie des Inscriptions et Belles-Lèttres, ***Inscriptions du Cambodge,*** Paris, Tome I, 1926.
-L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome II, 1926.
-L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome III, 1927.
-L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome IV, 1928.
-L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome V, 1931.
-L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome VI, 1937.
-Pou Saveros, ***Dictionaire Vieux Khmer- Français-Anglais an Old Khmer-French Dictionary,*** Paris, Cedoreck, 1992.
- Prum Marc, ***Cours d'initiation à la linguistique,*** Université de Toliara (Madagasca), 1990;
-Prum Marc, ***Recueil des cours & conseils de recherche,*** Université de Tulear (Madagasca), 1991;
- Prum Marc , ***Linguistique appliquée à l'enseignement*** , Université Nationale de Côte d'Ivoire , 1995;
- Prum Marc , "Processus sociolinguistique de la transformation du système lexicologique du khmer ", in: ***Revue Tétralogiques*** , N° 7- 1989, pp.61-73,UFR du Langage , Presses Universitaires Rennes II , France ;
- Prum Marc, " Notion de genre et de nombre en cambogien ", in : ***Bulletin de la Communauté Khmère d'Outre-Mer,*** N° 3-1964, Paris ;
- Prum Marc , "Analyse sommaire des structures du cambodgien ", in : ***Bulletin de la Communauté Khmère d'Outre-Mer,*** N° 2 – 1962 , Paris ;
-Y.A. GORGONIYEV, ***The Khmer Language,*** Nauka, Moscow 1966;

# មូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមក្នុងអក្ខរក្រមខ្មែរចូលផ្សំក្នុងទីតាំងរេង

ដោយ លោក វ៉ាង់ ម៉ុង

មន្ត្រីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

## I. សេចក្តីផ្តើម

បញ្ហាសូរ "អ" ឬ "អ៊" នៃព្យញ្ជនៈរបស់ភាសាខ្មែរកើតមានច្រើនណាស់ ហើយវានាំឲ្យមានផលវិបាកសម្រាប់កូនខ្មែរក្នុងការសរសេរពាក្យ។ ប្រធានបទខាងលើមានបំណងលើកយកបញ្ហាមួយក្នុងចំណោមបញ្ហាទាំងនោះមកបង្ហាញ។ ការវិភាគ និង សន្និដ្ឋាននានាក្នុងសិក្សាកថានេះមិនមែនជាការបង្កើតទ្រឹស្តីថ្មី ឬ ជាការបង្ខំឲ្យអ្នកដទៃធ្វើតាមនោះទេ។ ផ្ទុយទៅវិញ វាគ្រាន់តែជាការវិភាគដោយផ្អែកលើហេតុផលដែលបានមកពីការឆ្លុះបញ្ចាំង តាមរយៈប្រព័ន្ធរបស់ភាសាខ្មែរដែលជាកេរដំណែលរបស់បុព្វបុរសខ្មែរប៉ុណ្ណោះ ។

## II. អ្វីជាមូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរេង?

### ១- អ្វីជា"មូលភេទ"[១]?

មូលភេទសំដៅទៅលើក្រុមសូរ "អ" ឬ "អ៊"[២] នៃព្យញ្ជនៈខ្មែរ ។ តារាងខាងក្រោមបែងចែកមូលភេទ "អ" និង "អ៊" នៃព្យញ្ជនៈទាំង ៣៣ តួ ក្នុងអក្ខរក្រមរបស់ភាសាខ្មែរ ។

| វគ្គ | ព្យញ្ជនៈដែលមានមូលភេទ"អ" | ព្យញ្ជនៈដែលមានមូលភេទ "អ៊" |
|---|---|---|
| វគ្គ *ក* | ក, ខ | គ, ឃ, ង |
| វគ្គ *ច* | ច, ឆ | ជ, ឈ, ញ |
| វគ្គ *ដ* | ដ, ឋ, ណ | ឌ, ឍ, |
| វគ្គ *ត* | ត, ថ | ទ, ធ, ន |
| វគ្គ *ប* | ប, ផ | ព, ភ, ម |

---

[១] ពាក្យ "មូលភេទ" ប្រើដោយក្រសួងអប់រំយុវជន និង កីឡា ។ សូមមើល "ក្រសួងអប់រំ យុវជន និង កីឡា៖ *វេយ្យាករណ៍ខ្មែរថ្នាក់ទី ៥* ។ ភ្នំពេញ៖ មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា, ១៩៨០ ទំ. ៥ " ។

[២] អ្នកខ្លះហៅថា "ព្យញ្ជនៈឃោសៈ និង ព្យញ្ជនៈអឃោសៈ" ដោយភាន់ច្រឡំ ។ គួររំលឹកថា ប្រព័ន្ធ "*ឃោសៈ* និង*អឃោសៈ*" និង ប្រព័ន្ធ "មូលភេទ *អ* និង *អ៊*" ជាប្រព័ន្ធពីរផ្សេងពីគ្នា ។

| វគ្គ | មូលភេទ "អ" | មូលភេទ "អ៊" |
|---|---|---|
| *សេស* វគ្គ | ស, ហ, ឡ, អ | យ, រ, ល, វ, |

## ២- អ្វីជា "កន្សោមព្យញ្ជនៈ"?

កន្សោមព្យញ្ជនៈគឺបន្សំនៃសញ្ញានិងសូរព្យញ្ជនៈពីរឬច្រើន ដោយឥតមានសូរស្រៈនៅផ្សំចន្លោះកណ្ដាលព្យញ្ជនៈទាំងនោះឡើយ។ លោក អៀវ កើស ហៅវាថា *ព្យញ្ជនៈផ្ញើជើង* ហើយលោកបានបន្ថែមថា សំឡេងរបស់ព្យញ្ជនៈផ្ញើជើង (កន្សោមព្យញ្ជនៈ) បានមកពីការបន្លឺសំឡេងព្យញ្ជនៈទីមួយកន្លះមាត្រា និង ព្យញ្ជនៈបន្ទាប់ពេញមាត្រា (ទំ. ១១០)។ ក្នុងករណី កត់សូរព្យញ្ជនៈមួយរបស់ភាសាបរទេស ដែលពុំមាននៅក្នុងភាសាខ្មែរ សញ្ញារបស់កន្សោមព្យញ្ជនៈគឺជាសញ្ញាសន្មតមួយដែលគេផ្សំដោយយល់ឃើញថា សំឡេងផ្សំនៃព្យញ្ជនៈដែលចូលផ្សំគ្នានោះប្រហាក់ប្រហែលនឹងសំឡេងព្យញ្ជនៈរបស់ភាសាបរទេសនោះ ។

"ស្រ" ក្នុង ពាក្យ "ស្រូវ" ជាកន្សោមព្យញ្ជនៈ ។

"ផ្ក" ក្នុងពាក្យ "ផ្កា" ជាកន្សោមព្យញ្ជនៈ ។

"ស្ត្រ" ក្នុងពាក្យ "ស្ត្រី" ជាកន្សោមព្យញ្ជនៈ ។

"ហ្វ" ក្នុងពាក្យកម្ចី "កាហ្វេ" ជាកន្សោមព្យញ្ជនៈ ។

## ៣- ព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើម នៃអក្សរក្រមខ្មែរ

វគ្គទាំង៥ ខាងដើមគឺ វគ្គ*ក* វគ្គ*ច* វគ្គ*ដ* វគ្គ*ត* និង វគ្គ*ប* ។ ឯព្យញ្ជនៈទីបីនៃវគ្គទាំង ៥ នេះគឺ *គ, ជ, ឌ, ទ,* និង *ព* ។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ឃ | ង | ។ | | | |
| ច | ឆ | ជ | ឈ | ញ | ។ | | | |
| ដ | ឋ | ឌ | ឍ | ណ | ។ | | | |
| ត | ថ | ទ | ធ | ន | ។ | | | |
| ប | ផ | ព | ភ | ម | ។ | | | |
| យ | រ | ល | វ | ស | ហ | ឡ | អ | ។ |

សូមកត់សម្គាល់ថាព្យញ្ជនៈទីបី នៃវគ្គទាំង ៥ នេះសុទ្ធតែមានមូលភេទ "អ៊" (សូមមើលតារាងមូលភេទ ក្នុងចំណុច ១ នៃលេខ II) ។

## ៤- ទីតាំងរងក្នុងកន្សោមព្យញ្ជនៈ

ទីតាំងរងក្នុងកន្សោមព្យញ្ជនៈសំដៅទៅលើទីតាំងមិនមែនទី ១ ។ ហេតុដូច្នេះ ដោយយកតាមគំនិតរបស់លោក អៀវ កើស ព្យញ្ជនៈដែលស្ថិតនៅទីតាំងរងក្នុងកន្សោមព្យញ្ជនៈត្រូវមានសំឡេងពេញមាត្រា ។ នៅក្នុងកន្សោមព្យញ្ជនៈ ព្យញ្ជនៈនៅក្នុងទីតាំងរងត្រូវមានរូបរាងជា "ជើង" ព្យញ្ជនៈ ។

*ស្គ* (ក្នុងពាក្យ *ស្គរ, ស្គន់, ស្គាល់* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *គ* ក្នុងទីតាំងទី ២ ឬទីតាំងរងនេះឯង ។

*ខ្ជ* (ក្នុងពាក្យ *ខ្ជីខ្ជា, ខ្ជិល, ខ្ជាប់* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ខ* ក្នុងទីតាំងទី ១ និង *ជ* ក្នុងទីតាំងរង ។

*ក្ន* (ក្នុងពាក្យ *ក្នឹង, ក្នុក, ក្នុងក្នាំង,* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ក* ក្នុងទីតាំងទី ១ និង *ន* ក្នុងទីតាំងរង ។

*ស្ទ* (ក្នុងពាក្យ *ស្ទាប, ស្ទឹង, ស្ទោង* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *ទ* ក្នុងទីតាំងរង ។

*ថ្ព* (ក្នុងពាក្យ *ថ្ពាល់, ថ្ពក់, ថ្ពង* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ថ* ក្នុងទីតាំងទី ១ និង *ព* ក្នុងទីតាំងរង ។

កន្សោមព្យញ្ជនៈខាងលើ (*ស្គ, ខ្ជ, ក្ន, ស្ទ,* និង *ថ្ព* )ជាគំរូនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង ។

### ៥- មូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង

កន្សោមព្យញ្ជនៈគំរូ (ដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង) ក្នុងចំណុច ៤ នៃលេខ II សុទ្ធតែមានមូលភេទ "អ៊" (/ɔː/) ទាំងអស់ គឺមានមូលភេទដូចមូលភេទព្យញ្ជនៈទីបីនៃវគ្គទាំង ៥ នោះ ។ ត្រង់នេះ យើងសូមប្រើសញ្ញាសូរវិទ្យាអន្តរជាតិមកកត់សូរដើម្បីឲ្យអ្នកអានមើលឃើញច្បាស់៖ *ស្គ* មានសូរ /skɔː/, *ខ្ជ* មានសូរ /kcɔː/, *ក្ន* មានសូរ /kdɔː/, *ស្ទ* មានសូរ /stɔː/, និង *ថ្ព* មានសូរ /tpɔː/។

ខាងក្រោមគឺជាសម្រង់ពាក្យ ដែលព្យាង្គដើមផ្ដើមដោយកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង ពីវចនានុក្រមខ្មែរ។

ក្នឹង ក្នុក ក្នុង/ក្នុង ក្នុំ ក្នាំង
ក្នម្ក ក្នម្កទេស

ខ្ជាក ខ្ជាក់ ខ្ជាង ខ្ជាន់ៗ ខ្ជាប់ ខ្ជាប់ខ្ជួន ខ្ជាយ ខ្ជីខ្ជា ខ្ជិល ខ្ជឹប
ខ្ជឹង ខ្ជីប ខ្ជើច ខ្ជេញ ខ្ជែង ខ្ជោក ខ្ជោកខ្ជាក ខ្ជោល ខ្ជាំ
ខ្ជាំងៗ ខ្ជះខ្ជាយ

ឆ្គង ឆ្គាំឆ្គង
ឆ្គង់ ឆ្គាម ឆ្គិត ឆ្គិន ឆ្គឺះ ឆ្គុង ឆ្គោះ

ថ្ពាម ថ្ពោល

*ស្គ* (ក្នុងពាក្យ *ស្គរ, ស្គន់, ស្គាល់* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *គ* ក្នុងទីតាំងទី ២ ឬទីតាំងរងនេះឯង ។

*ខ្ជ* (ក្នុងពាក្យ *ខ្ជីខ្ជា, ខ្ជិល, ខ្ជាប់* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ខ* ក្នុងទីតាំងទី ១ និង *ជ* ក្នុងទីតាំងរង ។

*ក្ឌ* (ក្នុងពាក្យ *ក្ឌឹង, ក្ឌុក, ក្ឌុងក្ឌាំង,* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ក* ក្នុងទីតាំងទី ១ និង *ឌ* ក្នុងទីតាំងរង ។

*ស្ទ* (ក្នុងពាក្យ *ស្ទាប, ស្ទឹង, ស្ទោង* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *ទ* ក្នុងទីតាំងរង ។

*ថ្ព* (ក្នុងពាក្យ *ថ្ពាល់, ថ្ពក់, ថ្ពង* ។ល។) ជាកន្សោមព្យញ្ជនៈដែលកើតពីព្យញ្ជនៈ *ថ* ក្នុងទីតាំងទី ១ និង *ព* ក្នុងទីតាំងរង ។

កន្សោមព្យញ្ជនៈខាងលើ (*ស្គ, ខ្ជ, ក្ឌ, ស្ទ,* និង *ថ្ព* )ជាគំរូនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង ។

### ៥- មូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង

កន្សោមព្យញ្ជនៈគំរូ (ដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង) ក្នុងចំណុច ៤ នៃលេខ II សុទ្ធតែមានមូលភេទ "អ៊" (/ɔː/) ទាំងអស់ គឺមានមូលភេទដូចមូលភេទព្យញ្ជនៈទីបីនៃវគ្គទាំង ៥ នោះ ។ ត្រង់នេះ យើងសូមប្រើសញ្ញាសូរវិទ្យាអន្តរជាតិមកកត់សូរដើម្បីឲ្យអ្នកអានមើលឃើញច្បាស់៖ *ស្គ* មានសូរ /sk<u>ɔː</u>/, *ខ្ជ* មានសូរ /kc<u>ɔː</u>/, *ក្ឌ* មានសូរ /kd<u>ɔː</u>/, *ស្ទ* មានសូរ /st<u>ɔː</u>/, និង *ថ្ព* មានសូរ /tp<u>ɔː</u>/។

ខាងក្រោមគឺជាសម្រង់ពាក្យ ដែលព្យាង្គដើមផ្ដើមដោយកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរង ពីវចនានុក្រមខ្មែរ។

ក្ឌឹង ក្ឌុក ក្ឌុង/ក្ឌួង ក្ឌុំ ក្ឌាំង
ក្ឌម្ព ក្ឌម្ពទេស

ខ្ជាក ខ្ជាក់ ខ្ជាង ខ្ជាន់ៗ ខ្ជាប់ ខ្ជាប់ខ្ជួន ខ្ជាយ ខ្ជីខ្ជា ខ្ជិល ខ្ជីប
ខ្ជឹង ខ្ជីប ខ្ជើច ខ្ជេញ ខ្ជែង ខ្ជោក ខ្ជោកខ្ជាក ខ្ជោល ខ្ជាំ
ខ្ជាំងៗ ខ្ជះខ្ជាយ

ឆ្គង ឆ្គាំឆ្គង
ឆ្ពង់ ឆ្ពាម ឆ្ពិត ឆ្ពិន ឆ្ពឹះ ឆ្ពុង ឆ្ពោះ

ថ្ពាម ថ្ពោល

# មូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមក្នុងអក្ខរក្រមខ្មែរចូលផ្សំក្នុងទីតាំងរេផ

ដោយ លោក វ៉ាង ម៉ូន

មន្ត្រីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

## I. សេចក្ដីផ្ដើម

បញ្ហាសូរ "អ" ឬ "អ៊ិ" នៃព្យញ្ជនៈរបស់ភាសាខ្មែរកើតមានច្រើនណាស់ ហើយវានាំឲ្យមានផលវិបាកសម្រាប់កូនខ្មែរក្នុងការសរសេរពាក្យ។ ប្រធានបទខាងលើមានបំណងលើកយកបញ្ហាមួយក្នុងចំណោមបញ្ហាទាំងនោះមកបង្ហាញ។ ការវិភាគ និង សន្និដ្ឋាននានាក្នុងសិក្សាកថានេះមិនមែនជាការបង្កើតទ្រឹស្ដីថ្មី ឬ ជាការបង្ខំឲ្យអ្នកដទៃធ្វើតាមនោះទេ។ ផ្ទុយទៅវិញ វាគ្រាន់តែជាការវិភាគដោយផ្អែកលើហេតុផលដែលបានមកពីការឆ្លុះបញ្ចាំង តាមរយៈប្រព័ន្ធរបស់ភាសាខ្មែរដែលជាកេរដំណែលរបស់បុព្វបុរសខ្មែរប៉ុណ្ណោះ ។

## II. អ្វីជាមូលភេទនៃកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរេផ?

### ១- អ្វីជា "មូលភេទ"[១]?

មូលភេទសំដៅទៅលើក្រុមសូរ "អ" ឬ "អ៊ិ"[២] នៃព្យញ្ជនៈខ្មែរ ។ តារាងខាងក្រោមបែងចែកមូលភេទ "អ" និង "អ៊ិ" នៃព្យញ្ជនៈទាំង ៣៣ តួ ក្នុងអក្ខរក្រមរបស់ភាសាខ្មែរ ។

| វគ្គ | ព្យញ្ជនៈដែលមាន មូលភេទ "អ" | ព្យញ្ជនៈដែលមាន មូលភេទ "អ៊ិ" |
|---|---|---|
| វគ្គ *ក* | ក, ខ | គ, ឃ, ង |
| វគ្គ *ច* | ច, ឆ | ជ, ឈ, ញ |
| វគ្គ *ដ* | ដ, ឋ, ណ | ឌ, ឍ, |
| វគ្គ *ត* | ត, ថ | ទ, ធ, ន |
| វគ្គ *ប* | ប, ផ | ព, ភ, ម |

[១] ពាក្យ "មូលភេទ" ប្រើដោយក្រសួងអប់រំយុវជន និង កីឡា ។ សូមមើល "ក្រសួងអប់រំ យុវជន និង កីឡា៖ *វេយ្យាករណ៍ខ្មែរថ្នាក់ទី ៥* ។ ភ្នំពេញ៖ មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា, ១៩៨០ ទំ. ៥" ។

[២] អ្នកខ្លះហៅថា "ព្យញ្ជនៈឃោសៈ និង ព្យញ្ជនៈអឃោសៈ" ដោយភាន់ច្រឡំ ។ គួររំលឹកថា ប្រព័ន្ធ "*ឃោសៈ* និង*អឃោសៈ*" និង ប្រព័ន្ធ "មូលភេទ *អ* និង *អ៊ិ*" ជាប្រព័ន្ធពីរផ្សេងពីគ្នា ។

## III. ការសង្កេតចំពោះការកត់សូរពាក្យបរទេសដោយកន្សោមព្យញ្ជនៈ បែបខាងលើ

នៅពេលខ្មែរមានទំនាក់ទំនងជាមួយប្រទេសនានាលើពិភពលោក ខ្មែរក៏ខ្ចីពាក្យពីភាសាបរទេស ដែលខ្មែរមានទំនាក់ទំនងជាមួយនោះ មកប្រើតាមតម្រូវការរបស់ខ្លួន ។ ការណ៍នេះជារឿងធម្មតា។

ទន្ទឹមនឹងការខ្ចីពាក្យមកប្រើជាផ្លូវការ បច្ចុប្បន្នខ្មែរក៏មានប្រើពាក្យបរទេសជាឈ្មោះ យីហោក្រុមហ៊ុន ឬទុកលទ្ធភាពឲ្យក្រុមហ៊ុនដែលល្បីឈ្មោះជាអន្តរជាតិប្រើប្រាស់ឈ្មោះជាភាសាបរទេសរបស់ខ្លួន ដោយមិនចាំបាច់បកប្រែឈ្មោះនោះជាភាសាខ្មែរឡើយ និងដោយគ្រាន់តែប្រើអក្សរខ្មែរកត់សូរសំឡេងភាសាបរទេសនោះ ។

នៅទីនេះ យើងនឹងលើកយកឈ្មោះយីហោហាងមួយចំនួនក្នុងទីក្រុងភ្នំពេញ ដែលប្រើឈ្មោះជាភាសាបរទេស ហើយកត់ត្រាជាអក្សរខ្មែរ ដោយប្រើកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំងប្រាំខាងដើមរបស់អក្ខរក្រមខ្មែរចូលផ្សំក្នុងទីតាំងរងមកកត់ត្រា ។

ពាក្យអង់គ្លេស *style* /stail/ ក្លាយជាពាក្យដ៏ពេញនិយមក្នុងការដាក់ឈ្មោះហាងក្នុងរាជធានីភ្នំពេញ។ ពាក្យនេះត្រូវខ្មែរអានមិនច្បាស់ថា /sta:j/ ហើយត្រូវខ្មែរកត់ត្រាដោយអក្សរខ្មែរបែបសំណេរផ្សេងៗពីគ្នា ពោលគឺពុំមានឯកភាពគ្នាឡើយ។សំណេរមួយចំនួនក្នុងចំណោមនោះមាន*ស្តាយ, ស្ទាយ៍, ស្ទៃយ៍* ។ តើសំណេរបែបណាក្នុងចំណោមសំណេរទាំងនេះត្រូវគ្នានឹងការអានរបស់ខ្មែរថា /sta:j/ នោះ?







សំណេរ *ស្កាយ* ផ្ដើមដោយកន្សោមព្យញ្ជនៈ *ស្ក* ដែលផ្សំពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *ក* (ព្យញ្ជនៈទីមួយនៃវគ្គ*ក*) ក្នុងទីតាំងរង។ សំណេរទីពីរផ្ដើមដោយកន្សោមព្យញ្ជនៈ *ស្ទ* ដែលផ្សំពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *ទ* (ព្យញ្ជនៈទីបីនៃវគ្គ*ត*) ក្នុងទីតាំងរង។ ឯសំណេរទីបីវិញវាផ្ដើមដោយកន្សោមព្យញ្ជនៈ *ស្ទ* ដែលផ្សំពីព្យញ្ជនៈ *ស* ក្នុងទីតាំងទី ១ និង *ទ* (ព្យញ្ជនៈទីបីនៃវគ្គ*ត*) ក្នុងទីតាំងរង។

ដូចយើងឃើញរួចហើយ តាមរយៈការបង្ហាញក្នុងចំណុច ៥ នៃ លេខ II ថា <u>កន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំង ៥ ខាងដើមចូលផ្សំក្នុងទីតាំងរងសុទ្ធតែមានមូលភេទ "អ៊"</u> ។ ហេតុនេះ កន្សោមព្យញ្ជនៈ *ស្ទ* ត្រូវមានមូលភេទ "អ៊" គឺត្រូវអានថា /stɔ:/ ហើយសំណេរ *ស្ទាយ៍*[៣] ត្រូវអានថា /stea:/ (មិនមែន /sta:j/ ឡើយ) ឯសំណេរ *ស្ទៃយ៍* ត្រូវអានថា /stɛj/ (ក៏មិនមែន /sta:j/ ដែរ) ។

ចំណែកកន្សោមព្យញ្ជនៈ *ស្ក* វិញ វាមានមូលភេទ "អ" ហេតុនេះ សំណេរ *ស្កាយ* ត្រូវអានថា /sta:j/ ។

បើដូច្នោះ សំណេរទីមួយ ( *ស្កាយ*) ជាសំណេរដែលស្របនឹងអំណាន /sta:j/ ដែលខ្មែរអានពាក្យបរទេស *style* មិនច្បាស់ ហើយប្រើវាក្នុងការដាក់ឈ្មោះហាងនានា ។

ក្រៅពីការប្រើកន្សោមព្យញ្ជនៈដើម្បីកត់សូរឈ្មោះយីហោហាងជាភាសាបរទេស យើងសូមលើកយកការប្រើកន្សោមព្យញ្ជនៈមួយបែបទៀតក្នុងការកត់សូរពាក្យកម្ចីក្រៅផ្លូវការ ដែលជាការកត់ត្រាដោយប្រើកន្សោមព្យញ្ជនៈដែលមានព្យញ្ជនៈទីបីនៃវគ្គទាំងប្រាំខាងដើមរបស់អក្ខរក្រមខ្មែរចូលផ្សំក្នុងទីតាំងរងដែរ ។

ពាក្យ spray /spra:j/ របស់ភាសាបារាំងត្រូវបានខ្មែរយកមកប្រើក្រៅផ្លូវការ ដោយហៅថា /spra:j/ និងអ្នកខ្លះកត់ត្រាដោយសំណេរ *ស្ព្រេយ៍* ( *ឧ. ស្ព្រេយ៍បំបាត់ខ្ទិនខ្លួន*)។ ឯពាក្យ spot /spɑt/ (ឈុតផ្សាយពាណិជ្ជកម្មខ្លីៗ) របស់ភាសាអង់គ្លេសត្រូវបានខ្មែរយកមកប្រើក្រៅផ្លូវការថា /spɔ:t/ ហើយអ្នកខ្លះកត់ត្រាដោយសំណេរ *ស្ពត* ( *ឧ. មានទទួលកាត់តវីដេអូ ថតស្ពតពាណិជ្ជកម្ម...*)។

---

[៣] ត្រង់នេះ យើងមិនបរិយាយអំពីការប្រើវណ្ណយុត្តិ "៍" មិនបានត្រឹមត្រូវក្នុងសំណេរនេះឡើយ ។

សំណោរទីមួយ (*ស៊្ព្រយ៍*) ត្រូវអានថា /sprɛjjɔ:/ ។ អ្នកសរសេរមិនយល់អំពីរបៀបប្រើអស្តា (៍) និងមិនយល់អំពីមូលភេទ "អ៊ី" របស់កន្សោមព្យញ្ជនៈ *ស្ព* (ដែលមានជើង *ព* ជាព្យញ្ជនៈទីបីនៃវគ្គទីប្រាំចូលផ្សំក្នុងទីតាំងរង) និង *ស្រ* ។ សំណោរដែលត្រឹមត្រូវតាមអំណាន /spra:j/ គួរតែជា *ស្ប្រ៉យ* ឬ *ស្ប្រាយ* ។

ឯសំណោរទីពីរ ( *ស្ពត* ) ត្រូវអានថា /spɔ:t/ ព្រោះកន្សោមព្យញ្ជនៈ *ស្ព* មានមូលភេទ "អ៊ី" ។ ឯសំណោរត្រឹមត្រូវតាមអំណាន /spɑ:t/ គួរតែជា *ស្ប៉ត* ។ [៤]

## IV. ការសង្កេតចំពោះការបង្កើតកន្សោមព្យញ្ជនៈដើម្បីកត់សូរមួយក្នុងភាសាបរទេស

តារាងខាងក្រោមបង្ហាញអំពីគូមូលភេទ "អ" និង "អ៊ី" នៃព្យញ្ជនៈក្នុងភាសាខ្មែរ ។

| មូលភេទ "អ" | មូលភេទ "អ៊ី" | មូលភេទ "អ" | មូលភេទ "អ៊ី" | មូលភេទ "អ" | មូលភេទ "អ៊ី" |
|---|---|---|---|---|---|
| ក | គ | ដ | ឌ | ម៉ | ម |
| ខ | ឃ | ឋ | ឍ | | |
| ង៉ | ង | ណ | ន | យ៉ | យ |
| | | ត | ទ | រ៉ | រ |
| ច | ជ | ថ | ធ | ឡ | ល |
| ឆ | ឈ | | | វ៉ | វ |
| ញ៉ | ញ | ប | ប៊ | ស | ស៊ |
| | | ផ | ភ | ហ | ហ៊ |
| | | ប៉ | ព | អ | អ៊ |

តារាងនេះបង្ហាញថា <u>ព្យញ្ជនៈខ្មែរចាំបាច់ត្រូវមានគូមូលភេទ "អ" និង "អ៊ី"</u>។ គួររំលឹកថា ព្យញ្ជនៈទាំងនេះមានប្រភពដើមមកពីឥណ្ឌា ហើយត្រូវខ្មែរកែច្នៃរូបរាង រហូតមានរូបដូចសព្វថ្ងៃ។ ព្យញ្ជនៈទាំងនេះដើមឡើយគ្មានគូមូលភេទ "អ" ឬ "អ៊ី" ទេ ដ្បិតភាសាបាលី និង សំស្ក្រឹតរបស់ឥណ្ឌាពុំមានមូលភេទ "អ" និង "អ៊ី" ដែរ។ ប៉ុន្តែ ចំពោះភាសាខ្មែរ ដើម្បីឲ្យព្យញ្ជនៈទាំងនេះអាចប្រកបជាមួយស្រៈនិងសម្គាល់សទ្ទតាស្រៈក្នុងភាសាខ្មែរបានគ្រប់សព្វនោះ ខ្មែរក៏ធ្វើឲ្យវាមានមូលភេទទាំងពីរនេះឡើង។ ចំណែកឯព្យញ្ជនៈដែលពុំមានគូមូលភេទ ( *ង, ញ, ប, ព, ម, យ, រ, វ, ស,* និង *អ*) ខ្មែរបានបង្កើតសញ្ញាវណ្ណយុត្តិពីរគឺ *មូសិកទន្ត* ( ៉ ) និង *ត្រីសព្ទ* ( ៊ ) ប្រើដាក់ពីលើវា ដើម្បីបង្កើតគូមូលភេទរបស់ព្យញ្ជនៈទាំងនោះ ( សូមមើលតារាងខាងលើ ) ។

[៤] នេះគ្រាន់តែជាការបង្ហាញអំពីសំណោរត្រឹមត្រូវតាមអំណានប៉ុណ្ណោះ ។ បើគេបង្កើតពាក្យថ្មីសងនឹងពាក្យទាំងពីរនេះ ដោយមិនប្រើពាក្យកម្ចីបែបនេះ នោះបញ្ហានៃសំណោរទាំងនេះនឹងលែងមានហើយ។

ដើម្បីកត់សូរ / f / ក្នុងភាសាបារាំង/អង់គ្លេស ខ្មែរប្រើកន្សោមព្យញ្ជនៈ *ហ្វ* ហើយប្រើវាក្នុងអក្ខរាវិរុទ្ធ និង សំណេរពាក្យកម្ចីដូចជា *កាហ្វេ, ហ្វីល, ហ្វ្រង់,* ... ជាដើម។ ដើម្បីកត់សូរ /g/ របស់ភាសាបារាំង/អង់គ្លេស ខ្មែរបានសន្មតប្រើកន្សោមព្យញ្ជនៈ *ហ្គ*។

ដូចយើងបានឃើញរួចមកហើយថា ព្យញ្ជនៈខ្មែរចាំបាច់ត្រូវមានគូមូលភេទ "អ" និង "អ៊" ។ មានន័យថា <u>បុព្វបុរសខ្មែរបង្កើតរូបព្យញ្ជនៈពីរដើម្បីកត់សូរព្យញ្ជនៈមួយ ព្រោះរូបស្រៈមួយកត់សូរសទ្ទតាស្រៈពីរ (លើកលែង ស្រៈ *ឫ, ឭ,* និង *ឮ* ចេញ) ក្នុងភាសាខ្មែរ</u>។ ព្រោះហេតុនេះ ខ្មែរបានប្រើត្រីសព្ទបន្ថែមលើកន្សោមព្យញ្ជនៈ *ហ្វ* ជា *ហ្វ៊* ដើម្បីបង្កើតបានជាគូមូលភេទ "អ" និង "អ៊" រៀងគ្នា (ឧ. *កាហ្វេ* និង *ហ្វីល* ជាដើម)។ យើងនឹងមិនបរិយាយអំពីកន្សោមព្យញ្ជនៈ *ហ្វ* ឲ្យច្រើនជាងនេះទេ ដ្បិតវាមិនត្រូវនឹងប្រធានបទរបស់យើងនៅទីនេះ។ ផ្ទុយទៅវិញ យើងងាកមកនិយាយអំពីកន្សោមព្យញ្ជនៈ *ហ្គ* ដែលមានព្យញ្ជនៈទីបីនៃវគ្គ *ក* ចូលផ្សំក្នុងទីតាំងរង។

កន្សោមព្យញ្ជនៈ *ហ្គ* មានព្យញ្ជនៈ *គ* (ជើង *គ*) ចូលផ្សំក្នុងទីតាំងរង។ ហេតុនេះ កន្សោមព្យញ្ជនៈនេះច្បាស់ណាស់ត្រូវមានមូលភេទ "អ៊" ។

បើកន្សោមព្យញ្ជនៈ *ហ្គ* មានមូលភេទ "អ៊" នោះ តើគូមូលភេទ "អ" របស់វាមានរូបយ៉ាងណា?

នៅក្នុងព្រឹត្តិបត្រ លេខ ២ របស់គណៈកម្មាធិការជាតិភាសាខ្មែរ ចេញផ្សាយឆ្នាំ ២០០៩ គណៈកម្មការនេះបញ្ជាក់ថាខ្លួនបានអនុម័តយកការកត់សូរ /g/ របស់ភាសាបរទេស ដោយកន្សោមព្យញ្ជនៈ *ហ្គ* ។ ខ្ញុំបានជួប និង ស្ដាប់ប្រសាសន៍ផ្ទាល់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការនេះ។ លោកមានប្រសាសន៍ថា កន្សោមព្យញ្ជនៈនេះបង្កើតដោយការសន្មត ដ្បិតសូរ *ហ* និង *គ* ពុំអាចផ្សំគ្នាបង្កើតជាសូរ /g/ របស់ភាសាបរទេសនោះបានឡើយ ។

គួរយើងកត់សម្គាល់ថា ការកត់សូរ /g/ ដោយកន្សោមព្យញ្ជនៈ *ហ្គ* ត្រូវបានសាធារណជនប្រើប្រាស់មុនការអនុម័តរបស់គណៈកម្មាធិការនេះទៅទៀត។ ក្នុងការប្រើប្រាស់នោះ គេសង្កេតឃើញថា សាធារណជនប្រើប្រាស់វាមិនទៀងទាត់ជាមូលភេទណាមួយទេ ពោលគឺ ក្នុងពាក្យខ្លះ វាមានមូលភេទ "អ" និង ក្នុងពាក្យខ្លះ វាមានមូលភេទ "អ៊" ។ ឧទាហរណ៍ វាមានមូលភេទ "អ" ក្នុង ការកត់សូរ /g/ នៃសំណេរពាក្យកម្ចី "ហ្គាស" និង មូលភេទ "អ៊" នៅក្នុងសំណេរពាក្យកម្ចី "ហ្គែម" ។ ល។

### ការសាកល្បងដោះស្រាយបញ្ហា

សូមរំឭកឡើងវិញថា បុព្វបុរសខ្មែរប្រើរូបព្យញ្ជនៈពីរដើម្បីកត់សូរព្យញ្ជនៈមួយ ព្រោះរូបស្រៈខ្មែរមួយកត់សូរស្រៈពីរ។ ដូច្នេះ <u>គប្បីយើងប្រើរូបកន្សោមព្យញ្ជនៈពីរដែរ</u> ដើម្បីកត់សូរ /g/ របស់ភាសាបរទេសនោះ ពោលគឺរូបមួយមានមូលភេទ "អ" និង មួយទៀតមានមូលភេទ "អ៊"។ ការប្រើរូបកន្សោមព្យញ្ជនៈពីរនោះក៏អាចធ្វើឡើងផងដែរ ដោយការបន្ថែមវណ្ណយុត្តិ "◌៉" ឬ "◌៊" ប្រសិនបើចាំបាច់ ។

ដោយសារ *ហ្គ* មានមូលភេទ "អ៊" នោះ យើងត្រូវប្រើកន្សោមព្យញ្ជនៈមួយបែបទៀតដែលមានមូលភេទ "អ" ដើម្បីឲ្យបានជាគូនឹងវា។ តាមលទ្ធភាព យើងអាចបង្កើតវាបានជា *ហ្គ៉* ឬ *ហ្ក*។

តាមការសង្កេតរបស់ខ្ញុំ យើងគប្បីយករូបទីពីរ គឺកន្សោមព្យញ្ជនៈ *ហ្ក* ដ្បិត *ក* និង *គ* ជាគូនឹង

គ្នាស្រាប់ ដែលមិនតម្រូវឲ្យយើងប្រើវណ្ណយុត្តិជាជំនួយឡើយ ម្យ៉ាងទៀតវានឹងមិនទើសទាក់លើគ្នាច្រើនជាន់ទៀតផង។

អាស្រ័យហេតុនេះ ពាក្យហៅឈ្មោះប្រទេស ឬ ទីក្រុងមួយចំនួនដែលខ្មែរហៅប្រកបដោយមូលភេទ "អ" នៃសូរ /g/ ដូចជា *Afghanistan, Bulgaria, Gabon, Ghana, Madagascar, Paraguay, Portugal* ជាដើម គួរតែសរសេរ *អាហ្វហ្គានីស្ថាន, ប៊ុលហ្គារី, ហ្គាបុង, ហ្គាណា, ម៉ាដាហ្គាស្កា, ប៉ារ៉ាហ្គាយ, ព័រទុយហ្គាល់* ហើយពាក្យហៅឈ្មោះប្រទេស ឬទីក្រុងមួយចំនួន ដែលខ្មែរហៅប្រកបដោយមូលភេទ "អ៊" នៃសូរ /g/ ដូចជា *Angola, Santiago, Togo, Mongolia, Yugoslavia, Guernsey* ជាដើម គួរតែសរសេរជា *អង់ហ្គោឡា, សាន់ត្យាហ្គោ, តូហ្គោ, ម៉ុងហ្គោលី, យូហ្គោស្លាវី, ហ្គេនស៊ី* ។ ល។

**ចុះបើយើងមិនប្រើ *ហ្ក* ហើយប្រើតែ *ហ្គ* សម្រាប់កត់សូរ /g/ របស់ភាសាបរទេស តើវានឹងមានបញ្ហាអ្វីកើតឡើងទេ?**

បញ្ហាដែលអាចកើតឡើងនោះគឺ ប្រព័ន្ធមូលភេទ "អ" និង "អ៊" របស់ព្យញ្ជនៈខ្មែរដែលបុព្វបុរសខំប្រឹងសម្អិតសម្អាងតគ្នានោះនឹងបាត់បង់ភាពទៀងទាត់នៃមូលភេទរបស់វា ហើយវាអាចនឹងទៅជាការបើកផ្លូវឲ្យមានភាពមិនទៀងទាត់ដទៃទៀតកើតឡើងបាន។ [៥]

## V. សន្និដ្ឋាន

ដូចយើងបញ្ជាក់នៅក្នុងសេចក្ដីផ្ដើមថា សិក្សាកថានេះគ្រាន់តែសាកល្បងដោះស្រាយបញ្ហាដោយផ្អែកលើអ្វីដែលមានស្រាប់ ក្នុងភាសាខ្មែរប៉ុណ្ណោះ ពោលគឺសិក្សាកថានេះមិនមែនជាការបង្កើតទ្រឹស្ដី ឬ បង្ខំឲ្យអ្នកអានអនុវត្តតាមដាច់ខាតនោះទេ ប៉ុន្តែយើងសង្ឃឹមថា វានឹងមានប្រយោជន៍សម្រាប់អ្នកអានពិចារណា ។

"ចូរទាញយកក្បួនពីភាសា និង កុំបង្កើតទ្រឹស្ដីហើយវាយភាសាបញ្ចូល"
"មនុស្សមិនមែនអាទិទេពទេ" (បណ្ឌិត ព្រុំ ម៉ល់)

[៥] ខ្ញុំតែងតែមានការកោតសរសើរចំពោះអ្នកសរសេរឈ្មោះផ្សារទំនើប "ផារ៉ាហ្កន" ដែលកត់ត្រាឈ្មោះផ្សារនេះដោយយកន្សោមព្យញ្ជនៈ *ហ្ក* សម្រាប់មូលភេទ "អ" ក្នុងពាក្យនេះ ។

# គន្ថនិទ្ទេស


ក្រសួងអប់រំ យុវជន និង កីឡា៖ *វេយ្យាករណ៍ខ្មែរថ្នាក់ទី ៥*។ ភ្នំពេញ៖ មជ្ឍមណ្ឌលនិពន្ធ កម្មវិធី និងសៀវភៅសិក្សា, ១៩៨៣ ។

គណៈកម្មាធិការជាតិភាសាខ្មែរ ៖ *ព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរ* លេខ ២ (២០០៩)៖ ទំព័របន្ថែម ។

ឃីន សុខ៖ *វេយ្យាករណ៍ភាសាខ្មែរ*។ ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា, ២០០៤ ។

ច័ន្ទ សំណព្វ៖ *សំណេរនិងអក្ខរាវិរុទ្ធខ្មែរ*។ ភ្នំពេញ៖ Founan , ២០០៨ ។

ពុទ្ធសាសនបណ្ឌិត្យ៖ *វចនានុក្រមខ្មែរ*, បោះពុម្ពគ្រាទី ៥ ។ ភ្នំពេញ, ១៩៦៧-១៩៦៨ ។

ពូវ អ៊ុម៖ *វេយ្យាករណ៍ខ្មែរពិស្តារ*។ ១៩៦៨ ។

ព្រុំ ម៉ល់៖ *វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរ*។ ភ្នំពេញ៖ការផ្សាយរបស់អ្នកនិពន្ធ, ២០០៦ ។

អៀវ កើស៖ *ភាសាខ្មែរ*, សាកល្បងពិនិត្យដោយរកហេតុផល, បោះពុម្ពឡើងវិញ។ ភ្នំពេញ៖ ពុទ្ធ-សាសនបណ្ឌិត្យ, ១៩៩៥ ។

Gorgoniyev Y. A. *The Khmer Language*. Moscow: Nauka Publishing House, Central Department of Oriental Literature, 1966.

Huffman E. Franklin. *Cambodian System of Writing and Beginning Reader*. London: New Haven, 1970.

______. *Modern Spoken Cambodian*. London: New Haven, 1970.

Jacob M. Judith. *Introduction to Cambodian*. London: Oxford University Press, 1968.

# ស្ថានភាពនៃការប្រើប្រាស់ភាសាក្រោលនៅឃុំស្រែជិះ

កាលពីថ្ងៃទី២៥ ខែសីហា ដល់ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ មន្ត្រីវិទ្យាស្ថានភាសាជាតិមួយក្រុមសហការជាមួយអ្នកស្រាវជ្រាវអង្គការ ICC បានចុះស្រាវជ្រាវអំពីជីវភាពនិងស្ថានភាពនៃការប្រើប្រាស់ភាសាជនជាតិដើមភាគតិចក្រោល ក្នុងឃុំស្រែជិះ ស្រុកសំបូរ ខេត្តក្រចេះដើម្បីប្រមូលទិន្នន័យមក សម្រាប់ការសិក្សាស្រាវជ្រាវភាសាជនជាតិដើមភាគតិចនៅកម្ពុជា។

## ១-ប្រវត្តិនិទានទាក់ទងនឹងឈ្មោះ ក្រោល

ក្រោល គឺជាឈ្មោះភាសានិងឈ្មោះជនជាតិដើមភាគតិចមួយនៅប្រទេសកម្ពុជា។ ជនជាតិក្រោល ពីរនាក់បាននិទានរឿងស្រដៀងគ្នា ទាក់ទងនឹងឈ្មោះ ក្រោល នេះ។

### ១.១- ការនិទានរបស់លោកពូ សារ៉ាយ ពឿន

លោកជំទប់ទីពីរឃុំស្រែជិះ ដែលជាជនជាតិក្រោល ឈ្មោះ សារ៉ាយ ពឿន បាននិទានរឿងទាក់ទងនឹងឈ្មោះ *ក្រោល* ថា ដំបូងឡើយ ជនជាតិនេះពុំទាន់មានឈ្មោះថាក្រោលទេ។ គេដឹងថាពួកគេជាជនជាតិខ្មែរ។ នៅពេលដែលខ្មែរមានសង្គ្រាមជាមួយនឹងសៀម ពួកទ័ពសៀមដែលឈ្នះបានដេញតាមខ្មែរ រហូតដល់ប៉ែកឦសាននៃប្រទេសកម្ពុជា។ រត់មកដល់តំបន់មួយដែលមានឈ្មោះថាភ្នំបាំងថ្ងៃ (បច្ចុប្បន្ន មិនដឹងនៅត្រង់ណា) កងទ័ពនិងប្រជារាស្ត្រខ្មែរមួយចំនួនបានឆ្លងផុតភ្នំរួចជីវិតទៅ ខ្លះឆ្លងមិនទាន់ក៏ត្រូវទ័ពសៀមកាប់សម្លាប់អស់ជាច្រើន ឯអ្នកខ្លះទៀតរត់ចូលក្នុងព្រៃនៅតំបន់នោះ។ ដោយពួកទ័ពសៀមនៅតែដេញតាមមិនឈប់ឈរ ទើបជនជាតិខ្មែរទាំងនោះប្រើល្បិចកាប់ដើមរកាដែលមានបន្លាធំៗមកធ្វើជាស្បែកជើងហើយពាក់បញ្ច្រាសដើម្បីបំភាន់ភ្នែកពួកសៀម។ ក្រុមមនុស្សទាំងនោះក៏បន្តរស់នៅលាក់ខ្លួនក្នុងព្រៃ បរិភោគតែផ្លែឈើ ស្លឹកឈើ អំពុកឈើ អស់ពេលជាយូរ ក្លាយជាមនុស្សព្រៃ មិនហ៊ានត្រឡប់ចូលក្នុងភូមិស្ថានវិញទេ ព្រោះនឹកស្មានថាពួកទ័ពសៀមនៅបន្តកាន់កាប់តំបន់នោះ។

លុះចំណេរតមក អ្នកស្រុកជនជាតិខ្មែរផ្សេងទៀតបានដឹងថា មានមនុស្សមួយក្រុមរស់នៅជាមនុស្សព្រៃ លាក់ខ្លួនពួនអាត្មាក្នុងព្រៃជ្រៅ ហើយចង់ឱ្យពួកគេត្រឡប់មករស់ក្នុងស្រុកភូមិជាមួយគ្នាវិញ តែមិនដឹងធ្វើដូចម្តេច ព្រោះពួកអ្នកទាំងនោះតែងតែរត់គេចខ្លួនបាត់ពេលពួកគេឃើញមនុស្សចម្លែក។ ពួកអ្នកស្រុកបានប្រើល្បិចដោយធ្វើរបងជាក្រោលព័ទ្ធភ្នំមួយដែលមានព្រៃក្រាស់ ទុកច្រកសម្រាប់ចេញចូល ហើយយកស្ករត្នោតជាច្រើនទៅដាក់នៅក្នុងព្រៃនោះ។ ក្រុមមនុស្សព្រៃទាំងនោះដែលតាមការនិទានថាមិនស្គាល់ស្ករត្នោត ព្រោះរស់នៅតែក្នុងព្រៃ ច្រើនតំណមកហើយ ហៅស្ករត្នោតថា ដីក្រហម។ ពួកគេបានបរិភោគស្ករត្នោតដឹងថាមានរស់ជាតិផ្អែមឆ្ងាញ់ ក៏បបួលគ្នីគ្នាមករស់នៅក្នុងព្រៃដែលមានរបងព័ទ្ធជុំវិញជាក្រោលនោះ។ពួកអ្នកស្រុកកាលបើដឹងថាក្រុមមនុស្សព្រៃទាំងនោះចូលទៅរស់នៅក្នុងក្រោលរបស់ខ្លួនហើយ ក៏នាំគ្នាបិទច្រក ហើយចាប់នាំអ្នកទាំងនោះមកឱ្យរស់នៅជុំគ្នា ដោយបង្កើត

ជាភូមិស្ថាន និង បង្ហាត់បង្រៀនឱ្យស្លៀកពាក់ ប្រកបរបរកសិកម្មធ្វើស្រែចម្ការតាមទម្លាប់ពីដូនតាវិញ។ ហេតុនេះហើយទើបជាប់ឈ្មោះថា ជនជាតិក្រោល រហូតមក។

**១.២- ការនិទានរបស់លោកអ៊ុំប្រធានភូមិស្រែជិះ**

ចំណែកលោកអ៊ុំប្រធានភូមិស្រែជិះបាននិទានរឿងទាក់ទងនឹងឈ្មោះជនជាតិក្រោលថា មានមនុស្សមួយក្រុមបាននាំគ្នាទៅកាប់ឫស្សីក្នុងព្រៃជ្រៅ ហើយចងជាក្បូនបណ្តែតតាមស្ទឹងដែលហូរកាត់តំបន់ព្រៃភ្នំ។ ដោយទឹកហូរខ្លាំងពេក ក្បូនរបស់ពួកគេក៏ដាច់ខូចអស់។ ក្រុមអ្នកទាំងនោះក៏វង្វេងក្នុងព្រៃហើយបន្តរស់នៅតែក្នុងព្រៃ។ តំណក្រោយមក កូនចៅរបស់ពួកគេក្លាយទៅជាមនុស្សព្រៃ។ នៅសម័យបារាំងគ្រប់គ្រងស្រុកខ្មែរ ពួកបារាំងចង់ឱ្យមនុស្សព្រៃទាំងនោះមករស់នៅក្នុងភូមិស្ថានជាមួយអ្នកស្រុកដទៃទៀត តែមិនដឹងធ្វើដូចម្តេច ព្រោះពួកគេតែងតែរត់គេចខ្លួនបាត់ពេលជួបអ្នកស្រុកម្តងៗ។ ពួកបារាំងនិងអ្នកស្រុកបានប្រើល្បិច ដោយធ្វើរបងជាក្រោលព័ទ្ធជុំវិញភ្នំមួយដែលមានព្រៃក្រាស់ ហើយទុកតែច្រកមួយសម្រាប់ចេញចូល។ គេបានយកស្ករត្នោតទៅដាក់ក្នុងក្រោលនោះ។ ពួកមនុស្សព្រៃដែលពុំធ្លាប់ស្គាល់ស្ករត្នោត បានទៅបរិភោគស្ករនោះដឹងថាមានរសជាតិផ្អែមឆ្ងាញ់ ក៏បបួលគ្នីគ្នាមកបរិភោគស្ករ និង ដេកនៅក្នុងព្រៃនោះ។ ពួកអ្នកស្រុកក៏នាំគ្នាបិទច្រកក្រោលហើយនាំយកមនុស្សព្រៃទាំងនោះឱ្យមករស់នៅបង្កើតជាភូមិស្ថាននិងបង្ហាត់ឱ្យចេះស្លៀកពាក់និងប្រកបរបរធ្វើស្រែចម្ការវិញ។ ចាប់ពីពេលនោះមក ទើបគេហៅអ្នកទាំងនោះថា ជនជាតិ*ក្រោល* រហូតមកដល់សព្វថ្ងៃ។

អ្នកនិទានទាំងពីរនាក់បានអះអាងថា បច្ចុប្បន្ននេះ មានភ្នំមួយឈ្មោះថា ភ្នំក្រោល ស្ថិតនៅក្នុងទឹកដីខេត្តមណ្ឌលគិរី។ គឺទីនោះហើយដែលជាទីកន្លែងដែលគេធ្វើក្រោល សម្រាប់ព័ទ្ធចាប់មនុស្សព្រៃឱ្យមករស់នៅក្នុងភូមិស្ថានវិញ។

## ២-ទីតាំងនិងចំនួនជនជាតិក្រោល ៖

ទិន្នន័យពីក្រសួងមហាផ្ទៃនិងការស្រាវជ្រាវជំបូងៗ គេបានដឹងថា ក្នុងប្រទេសកម្ពុជាជនជាតិក្រោលភាគច្រើនរស់នៅក្នុងឃុំស្រែជិះ និង ឃុំរលួសមានជ័យ នៃស្រុកសំបូរ ខេត្តក្រចេះ និង មួយចំនួនទៀត រស់នៅក្នុងឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

ឃុំស្រែជិះជាឃុំមួយដែលស្ថិតនៅឆ្ងាយដាច់ស្រយាល មានចម្ងាយប្រហែល១២០គ.ម.ពីក្រុងក្រចេះ។ឃុំស្រែជិះមានព្រំប្រទល់ខាងកើតទល់នឹងខេត្តមណ្ឌលគិរី ខាងលិចទល់នឹងឃុំរលួសមានជ័យ ស្រុកសំបូរ ខាងត្បូងទល់នឹងឃុំចង្រ្កង ស្រុកក្រចេះ និង ខេត្តមណ្ឌលគិរី ខាងត្បូងទល់នឹងខេត្ត-មណ្ឌលគិរី។ ឃុំស្រែជិះមានជនជាតិក្រោលចំនួន៥១៧គ្រួសារ ត្រូវជា២៨៤៣នាក់ ក្នុងនោះមានស្រីចំនួន១៤៣៦នាក់។ តាមស្ថិតិក្រសួងមហាផ្ទៃ ឃុំស្រែជិះមាន៦ភូមិ គឺ ៖

- ភូមិស្រែជិះ (ភាគច្រើនលើសលប់ជាជនជាតិក្រោល)
- ភូមិរៀង (ជនជាតិក្រោលទាំងអស់)
- ភូមិត្នោត (ជនជាតិក្រោលទាំងអស់)
- ភូមិភ្នំពីរ (ជនជាតិក្រោលទាំងអស់)
- ភូមិអំពក (មានជនជាតិព្នង)

- ភូមិកូនរាំ (មានជនជាតិថ្នូន)

គោលដៅនៃការចុះអង្កេតរបស់យើងនាពេលនេះ គឺភូមិស្រែជិះដែលមានជនជាតិដើមភាគតិចក្រោលរស់នៅច្រើនជាងគេ។ ភូមិស្រែជិះ នៅឆ្នាំ២០០៩ មានប្រជាពលរដ្ឋសរុបចំនួន២០៧គ្រួសារ ក្នុងនោះ មានគ្រួសារក្រោលចំនួន២០២គ្រួសារ ត្រូវជា១១៣០នាក់ (ស្រីចំនួន៥៧២នាក់)។ បើយើងធ្វើដំណើរបែកចេញពីផ្លូវជាតិលេខ៧ ត្រង់ម្តុំស្រែស្បូវទៅភូមិស្រែជិះ យើងត្រូវធ្វើដំណើរកាត់ព្រៃស្រោងជិត៥០គ.ម. ដោយឆ្លងកាត់ឃុំវល្លិសមានជ័យ។ ជនជាតិក្រោលជាប្រធានភូមិស្រែជិះបានឱ្យដឹងថា ជនជាតិក្រោលបានរស់នៅភូមិស្រែជិះតាំងពីដូនតាមក ពុំដែលផ្លាស់ប្តូរទីតាំងទៅទីណាផ្សេងម្តងឡើយ សូម្បីតែ ក្នុងសម័យ ប៉ុល ពត ក៏ដោយ។

ទិន្នន័យពីសាលាឃុំស្រែជិះ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួន គ្រួសារក្រោល | ចំនួន គ្រួសារសរុបក្នុងភូមិ |
|---|---|---|---|---|---|
| ក្រចេះ | សំបូរ | ស្រែជិះ | ស្រែជិះ | ២០២គ្រួ=១១៣០នាក់ | ២០៧គ្រួ |
| | | | រវៀង | ១៤៥គ្រួ =៧៧៨នាក់ | ១៤៥គ្រួ |
| | | | ត្នោត | ១២១គ្រួ=៦៥១នាក់ | ១២១គ្រួ |
| | | | ភ្នំពីរ | ៤៩គ្រួ=២៨៤នាក់ | ៤៩គ្រួ |
| | | វល្លិសមានជ័យ | ស្រែទាង | | ១៩៨ គ្រួ |
| មណ្ឌលគិរី | កោះញែក | រយ៉ | រយ៉ | ២៥ គ្រួ | ១៣៦ គ្រួ |
| | | | រវ៉ែត | ៧៩ គ្រួ | ៨៦ គ្រួ |
| | | | ក្ដោយ | ៥០ គ្រួ | ៥១ គ្រួ |

## ៣-ស្ថានភាពជីវភាពជនជាតិក្រោលនៅភូមិស្រែជិះ

ជនជាតិក្រោលនៅភូមិស្រែជិះមានរបៀបរបបរស់នៅប្រចាំថ្ងៃនិងទំនៀមទម្លាប់មិនខុសពីជនជាតិខ្មែរឡើយ តែភាគច្រើន ពួកគាត់រស់នៅក្នុងស្ថានភាពលំបាកនៅឡើយ។ ពួកគាត់ប្រកបរបរធ្វើ

- ភូមិកូនរ៉ា (មានជនជាតិថ្នូន)

គោលដៅនៃការចុះអង្កេតរបស់យើងនាពេលនេះ គឺភូមិស្រែជិះដែលមានជនជាតិដើមភាគតិចក្រោលរស់នៅច្រើនជាងគេ។ ភូមិស្រែជិះ នៅឆ្នាំ២០០៩ មានប្រជាពលរដ្ឋសរុបចំនួន២០៧គ្រួសារ ក្នុងនោះ មានគ្រួសារក្រោលចំនួន២០២គ្រួសារ ត្រូវជា១១៣០នាក់ (ស្រីចំនួន៥៧២នាក់)។ បើយើងធ្វើដំណើរបែកចេញពីផ្លូវជាតិលេខ៧ ត្រង់ម្តុំស្រែស្បូវទៅភូមិស្រែជិះ: យើងត្រូវធ្វើដំណើរកាត់ព្រៃស្រោងជិត៥០គ.ម. ដោយឆ្លងកាត់ឃុំរលួសមានជ័យ។ ជនជាតិក្រោលជាប្រធានភូមិស្រែជិះបានឱ្យដឹងថា ជនជាតិក្រោលបានរស់នៅភូមិស្រែជិះតាំងពីដូនតាមក ពុំដែលផ្លាស់ប្តូរទីតាំងទៅទីណាផ្សេងម្តងឡើយ សូម្បីតែ ក្នុងសម័យ ប៉ុល ពត ក៏ដោយ។

ទិន្នន័យពីសាលាឃុំស្រែជិះ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួន គ្រួសារក្រោល | ចំនួន គ្រួសារសរុបក្នុងភូមិ |
|---|---|---|---|---|---|
| ក្រចេះ | សំបូរ | ស្រែជិះ | ស្រែជិះ | ២០២គ្រួ=១១៣០នាក់ | ២០៧គ្រួ |
| | | | រវៀង | ១៤៥គ្រួ =៧៧៨នាក់ | ១៤៥គ្រួ |
| | | | ត្នោត | ១២១គ្រួ=៦៥១នាក់ | ១២១គ្រួ |
| | | | ភ្នំពីរ | ៤៩គ្រួ=២៨៤នាក់ | ៤៩គ្រួ |
| | | រលួសមានជ័យ | ស្រែទាង | | ១៩៨ គ្រួ |
| មណ្ឌលគិរី | កោះញ៉ែក | រយ៉ | រយ៉ | ២៥ គ្រួ | ១៣៦ គ្រួ |
| | | | រវ៉ែគ | ៧៩ គ្រួ | ៨៦ គ្រួ |
| | | | ក្ដោយ | ៥០ គ្រួ | ៥១ គ្រួ |

## ៣-ស្ថានភាពជីវភាពជនជាតិក្រោលនៅភូមិស្រែជិះ

ជនជាតិក្រោលនៅភូមិស្រែជិះមានរបៀបរបបរស់នៅប្រចាំថ្ងៃនិងទំនៀមទម្លាប់មិនខុសពីជនជាតិខ្មែរឡើយ តែភាគច្រើន ពួកគាត់រស់នៅក្នុងស្ថានភាពលំបាកនៅឡើយ។ ពួកគាត់ប្រកបរបរធ្វើ

តាមចម្លើយ ពួកគាត់សប្បាយចិត្តខ្លាំងណាស់ប្រសិនបើភាសាក្រោលនឹងត្រូវបានអភិវឌ្ឍឱ្យមានសំណេរសម្រាប់កត់ត្រា ហើយ ពួកគាត់ក៏ពេញចិត្តនឹងអានសៀវភៅជាភាសាក្រោលផងដែរប្រសិនបើមាន។ ការសិក្សាស្រាវជ្រាវភាសាក្រោល ជាការចាំបាច់ដែលត្រូវធ្វើបន្តទៀតឱ្យកាន់តែស៊ីជម្រៅ។

## ៦-វាក្យសព្ទ ខ្មែរ-ក្រោល

យើងយកអក្សរខ្មែរសម្រាប់កត់ត្រាភាសាក្រោល។ ការកត់ត្រាភាសាក្រោលដោយប្រើតួអក្សរខ្មែរនេះ ពុំប្រើសំណេរបែបទំនាញសូរឡើយ ហើយពាក្យដែលសរសេរមាន "រ" ត្រូវបញ្ចេញសូរ [r] , ពាក្យនីមួយៗត្រូវបានសរសេរឃ្លាតពីគ្នា។ ចំពោះសទ្ទខ្លះដែលពុំមានក្នុងភាសាខ្មែរ យើងខ្ញុំប្រើអក្សរផ្សំជា បណ្ដោះអាសន្នសិន ដូចជា សទ្ទព្យញ្ជនៈ [ɡ] សរសេរ "ហ្គ ឬ ហ្គ"។

| ពាក្យខ្មែរ | ពាក្យក្រោល | កត់សូរ |
|---|---|---|
| ក្បាល | អឹមពូក-អំពូក | ʔampo:k |
| សក់ | ឆក់ | chak |
| មុខ | ម៉ាត់ | mat |
| ត្រចៀក | តូលរ | to:lr |
| ច្រមុះ | ម៉ូហ | mo:h |
| រន្ធច្រមុះ | ត្រូម ម៉ូហ | tro:mmo:h |
| មាត់ | មុញ | muɲ |
| ភ្នែក | ម៉ាត់ | mat |
| ត្របកភ្នែក | បិកកោន ម៉ាត់ | bɔ:kkaon mat |
| ចិញ្ចើម | អ្ហើម - អិញជើម | ʔcɤm–ʔəɲcɤm |
| រោមភ្នែក | គ្រុយ ម៉ាត់ | kruj mat |
| ថ្ពាស | ង្ហឿរ | ŋɯər |
| ធ្មេញ | រេចច | ce:c |
| អណ្ដាត | លឹមពាត - លំពាត | ləmpea:t-lumpea:t |
| បបូរមាត់ | ប៉ប៉ុលរ មុញ | pa:polr muɲ |
| ចង្កា | ត្កាម | tka:m |
| ក | កូវ | kow |
| កញ្ចឹងក | ក្ទឿង កូវ | ktɯəŋkow |

| | | |
|---|---|---|
| ស្មា | តឹមប៉ូវ-តំប៉ូវ | təmpow-tampow |
| ដៃ | ដៃ | daj |
| ដើមដៃ | ហ្គឹល ដៃ | hgɨl daj |
| កែងដៃ | គៀង ដៃ | kieŋ daj |
| កំភួនដៃ | ឌុំ ដៃ | dum daj |
| កដៃ | កូវ ដៃ | kow daj |
| ម្រាមដៃ | ក្រញ៉ាម ដៃ | kra:ɲa:m daj |
| មេដៃ | ម៉ិះ ដៃ | mœh daj |
| បាតដៃ | លឹមប៉ាង ដៃ-លំប៉ាង ដៃ | ləmpa:ŋ daj - lumpa:ŋ daj |
| ក្រចកដៃ | គ្នកដៃ | kəcɔ:k daj |
| គន្លាក់ដៃ | កឡាក់ ដៃ | kəlak daj |
| ជើង | ជ្យុង | djuŋ |
| ភ្លៅ | ប្លូ | blu: |
| ជង្គង់ | អឹមពូក ក្តាំង | ʔəmpu:k ktaŋ |
| កំភួនជើង | ប៉ោយ្ហ | baojh |
| កជើង | កូវ ជ្យុង | kow djuŋ |
| បាតជើង | ប៉ាតជ្យុង | pa:t djuŋ |
| ម្រាមជើង | ក្រញ៉ាម ជ្យុង | kra:ɲa:m djuŋ |
| មេជើង | ម៉ិះ ជ្យុង | mœh djuŋ |
| ក្រចកជើង | គ្នក ជ្យុង | kcɔ:k djuŋ |
| ទ្រូង | ឌ្រួង | druəŋ |
| ដោះ | តោះ | tah |
| ពោះ | កន់ឌូល | kandu:l |
| ក្បាលពោះ | អឹមពូក កន់ឌូល | ʔəmpu:k kandu:l |
| ផ្ចិត | ខ្លក់ | khlak |

| | | |
|---|---|---|
| ចង្កេះ | អឹមប៊ុត-អំប៊ុត | ʔəmbut- ʔambut |
| ក្រពះ | ក្រពះ | krapɛah |
| ថ្លើម | ខ្លើម | khlaəm |
| ប្រម៉ាត់ | ប្រម៉ាត់ | pra:mat |
| ពោះវៀន | ពោះវៀន | puohwiɜn |
| បេះដូង | អបូក នួហ-អំបូក នួហ | ʔambo:k nu:h |
| កូន | កោន | kaon |
| ចៅ | ចៅ | caw |
| ប្រពន្ធ | ចអួរ | cəʔuo |
| ប្តី | ចួរ | cgow |

ផែនទីឃុំស្រែជិះ ÷



រូបថតពេលជួបសម្ភាសន៍ជនជាតិក្រោល



# បច្ចេកសព្ទរទេះ

(សម្ភាសន៍លោកអ៊ុំ **សក់ លក់** អាយុ៧៧ឆ្នាំ អតីតជាងធ្វើរទេះ
នៅភូមិតាកុក ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង)
(ថ្ងៃព្រហស្បតិ៍ ទី២៤ ខែមិថុនា ឆ្នាំ២០១០)

កន្ទុយត្រពង ន. ផ្នែកខាងចុងនៃមេសណ្ដូកនាងជាឬមេផ្ទះរទេះ មានសណ្ឋាន-ងឡើងបន្តិច។

កន្ទុយទូក ន. ផ្នែកខាងចុងផុតនៃទូករទេះ មានសណ្ឋាន-ងឡើងដូចកន្ទុយសត្វទា។

កន្ទួតជុំ ន. ក្បាច់រំលេចជាខ្សែធ្នូតកន្ទួលនៅជុំវិញជុំរទេះនីមួយៗ។

កាប ន. មេកាត់ទទឹងសណ្ដូកនាងជាឬទ្រុងរទេះ ចុងរបស់វាចងភ្ជាប់នឹងប្រែកត្រង់។
កាបមានពីរ ខាងមុខនិងខាងក្រោយ។

កាំ ន. ឧបករណ៍ទ្រទ្រង់រទេះដែលភ្ជាប់ពីជុំមកខ្នង រទេះកង់ម្ខាងមានកាំ១៦ ជាទូទៅ កាំមានប្រវែង ០,៥ម.។ រទេះមួយមាន៣២កាំ។

កាំនឹម ន. កន្លះឈើឬឬស្សីប្រវែងប្រហែល២,៥០សង់ទីម៉ែត្រសម្រាប់ស៊កកន្ទុយខ្សែទាមនៅផ្នែកខាងចុងនឹមទាំងសងខាង ដើម្បីទប់កគោក្របីនៅពេលទឹម។

ក្បាលក្រពើ ន. កន្លែងប្រជុំទូករទេះផ្នែកខាងមុខ។

ក្បាលនឹម ន. ផ្នែកនៅចំកណ្ដាលពីខាងលើនឹម។

ខ្វី ន. ការចោះរន្ធភ្លៅរទេះដែលគេលៃធ្វើយ៉ាងណាឱ្យរន្ធនោះស្ថិតនៅផ្នែកខាងលើប្រែក ងឬស្ថិតនៅផ្នែកខាង លើខ្នងប្រែក-ងដើម្បីឱ្យកង់រទេះរាងញែកខាងក្រោមគេធ្វើយ៉ាងនេះដើម្បីឱ្យពេលបរគោក្របីអូសធូរមិនតឹង(គឺចោះរន្ធប្រែក-ងខាងម្ខាងលៃឱ្យលើសទៅមុខ០,០៥ម.រីឯ ប្រែក ង ខាងម្ខាងទៀតឱ្យលើសមកក្រោយ ០,០៥ម.ដែរ នេះជាក្បួនលោកតា សក់ លក់)។

ខ្នង់ ន. ឈើដែលគេដាប់ភ្ជាប់ទូករទេះទាំងពីរខាងឱ្យនឹង មានប្រវែង០,៦៩ម.(បើរទេះធំគេប្រើខ្នង់៥សម្រាប់ទឹមគោធំៗ)។

ខ្នង ន. ផ្នែកខាងនៃកង់រទេះសម្រាប់ទប់ចុងកាំដែលមានបួនស្និត ក្នុងមួយស្និតគេស៊កចុងកាំបួនដែរ។

ខ្នល់ ន. កំណល់ដែលកល់ក្រោមទូករទេះ សម្រាប់ទប់និងទ្រភ្លៅរទេះ មានទំហំ០,២ម.(ពីរតឹក)បួនជ្រុង។

ខ្សែជ្រាម ន. ខ្សែសម្រាប់ចងភ្ជាប់នឹមទៅនឹងក្បាលក្រពើរទេះ។

ខ្សែទាម ន. ខ្សែដែលគេចាក់ច្បោះជាបន្ទះ ចុងម្ខាងចងភ្ជាប់នឹងនឹមសម្រាប់ទាក់កគោក្របីកុំឱ្យរបូតពីនឹម។

ចន្ទល់ ន. ឈើឬឬស្សីតូចពីរភ្ជាប់ក្បាលគ្នាដោយកូនច្រវាក់ប្រវែងប្រហែល០,២៥ម.(ពីរតឹកកន្លះ) សម្រាប់ទ្រទល់ក្បាលក្រពើរទេះ។ ចំពោះអ្នកស្រុកនៅខេត្តបាត់ដំបង គេច្រើនធ្វើចន្ទល់តែមួយប៉ុណ្ណោះ ប៉ុន្តែមានចម្កាម។

ចន្ទោល ន. ផ្នែកខាងចុងដែលបន្តពីក្បាលក្រពើមានសណ្ឋានកោង-ងស្មើតឡើងលើ ហើយឧបចូល

មកវិញបន្តិច។

ចែ ន. កន្លះដែលគេបោះភ្ជាប់នឹងក្បាលក្រពើឬប្រជុំទូករទេះដើម្បីទប់ខ្សែជ្រាមកុំឱ្យជ្រាមអើលចុះឡើង។

ឆ្នង់/ចម្រឹង ន. បង្គោលឬចម្រឹងដែលបណ្ដុះចេញពីមេសណ្ដូកនាងជាខាងក្រោមដើម្បីសម្រាប់ទប់ និងសម្រាប់ភ្ជាប់កម្រងបន្ទោះជញ្ជាំងផ្ទះរទេះ។

ជ្រាម/ព្រ័ត្រ ន. ខ្សែ ពួរ ឬ ព្រ័ត្រស្បែកក្របី សម្រាប់ចងភ្ជាប់នឹមទៅនឹងក្បាលក្រពើ។

ញញ ន. ចុងផ្នែកខាងមុខត្រពងមានរាង-ងបន្តិច ចំណែកឯនៅផ្នែកខាងក្រោយគេហៅថាកន្ទុយត្រពង។

ដែកគ្រីប/ដែកប៉ាន ន. ដែកស្រោបខ្នងកង់ទាំងមូលសម្រាប់គ្រីបខ្នងកង់ទាំងមូល មានកម្រាស់០,០១ម. ឬ០,០០៨ម.(មួយធឹងឬ៨លី)។ (ខេត្តនានាខុសពីខេត្តបាត់ដំបងគេហៅ ដែកប៉ាន)។

ដែកចាប់មាត់ដុំ ន. ដែកដែលរឹតរង្វង់ចុងដុំដើម្បីការពារកុំឱ្យដុំប្រេះឬបែក។

ដុំ ន. មេប្រជុំកាំរទេះដែលស្ថិតនៅចំកណ្ដាលរង្វង់កង់ គឺជាកន្លែងសម្រាប់បញ្ចុះពន្លួញកាំ មានប្រវែង ០,៥៣ម. មានរង្វង់ជាទូទៅប្រហែល ០,១៨ម.ទៅ០,២៥ម. ជាផ្នែកសំខាន់របស់កង់រទេះ ។

ដោះនឹម ន. ដុំឈើដែលកល់ពីក្រោមនឹមដើម្បីទប់នឹមកុំឱ្យក្រឡាប់និងដើម្បីអាចឱ្យនឹមវិលបានងាយស្រួលកុំឱ្យរទេះងាយក្រឡាប់។

ត្បោងន. រំពាត់វាយគោឬក្របីធ្វើពីគល់ផ្ដៅដែលមានជាប់ដើមផងមានប្រវែងប្រហែល១,៥០ម.ទុកគល់ប្រហែល០,៥០ម. សល់ពីនោះគេច្រៀកជាបីចម្រៀក ហើយ គេបិតវាឱ្យរៀវចុងរួចវេញជាផ្លុងមួយ រួចហើយយកទៅជ្រលក់ជ័រចុងនិងលាបជ័រទឹក ដើម្បីឱ្យវារឹងនិងភ្លឺរលោង (អ្នកស្រុកខ្លះហៅថា មោងឬខ្សែតី)។

ត្រពង/ចង្រ្កត់ ន. មេខាងលើសណ្ដូកនាងជាឬផ្ទះរទេះ ដែលគ្របពីលើចម្រឹងរទេះ។ អ្នកស្រុកខ្លះហៅត្រពងនេះថា ចង្រ្កត់។

ទងកន្ត្រៃ ន. ប្រជុំនៃទូករទេះជាប់នឹងក្បាលក្រពើ។

ទូករទេះ ន. មេសណ្ដូកស្របគ្នាពីរ ភ្ជាប់គ្នាដោយខ្នង់ចំនួនប្រាំ ដោយផ្នែកខាងម្ខាងមានសណ្ឋានរីកជាងខាងផ្នែកម្ខាងទៀត មេសណ្ដូកជាតួសំខាន់នៃរទេះ។ វាមានប្រវែង៤ម៉ែត្រ ហើយរទេះនីមួយៗ ជាទូទៅគេច្រើនបើកខ្នង់០,៦៩ម. សម្រាប់ទ្រសណ្ដូកនាងជា។

ទ្រនាប់ទូក ន. កំណល់ទូករទេះជាមួយប្រែកត្រង់ គេដាក់វាពីលើប្រែកត្រង់ដើម្បីកុំឱ្យសឹកទូករទេះ។

ទ្រាយ ន. មេធំដែលគេបណ្ដុះចេញពីកាបនៅផ្នែកពីមុខនិងពីក្រោយនៃផ្ទះរទេះ សម្រាប់ទប់ត្រពង។

នឹម ន. គ្រឿងរទេះធ្វើពីឈើធ្លាក់ឬធ្វើពីគល់ឬស្សីត្រង់ល្អ ហើយមាំ សម្រាប់ទឹមគោក្របី គេចងវានៅពីលើក្បាលក្រពើ មានប្រវែង២ម.។

ប៉ាឡាំង ន. ឈើកម្រាស់ប្រហែលស្មើមួយតឹកបួនជ្រុងដាក់ឱ្យស្មើគ្នានឹងស្លង់ដុំ។

ប្រែក ង ន. គ្រឿងរទេះធ្វេងស្គាំសម្រាប់ទប់កង់ទាំងពីរ ផ្នែកកណ្ដាលទប់ដែកភ្លៅរទេះ ចុងប្រែកខាងមុខហៅថាក្បាលប្រែក រីឯចុងប្រែកផ្នែកខាងក្រោយហៅថា កន្ទុយប្រែក។ នៅត្រង់កក្បាលប្រែកនិងកកន្ទុយប្រែកគេដាប់ដំណាប់សម្រាប់សិកចុងប្រែកត្រង់។

ប្រែកត្រង់ ន. គ្រឿងរទេះដែលគេដាក់កាត់ទទឹងពីក្រោមទូករទេះ មានពីរ មួយនៅប៉ែកខាងមុខនិងមួយទៀតនៅប៉ែកខាងក្រោយ។ ប្រែកត្រង់ ប៉ែកខាងមុខមានប្រវែង២ម. រីឯ ប្រែកត្រង់ប៉ែកខាងក្រោយមានប្រវែង២,២ម. ដោយចុងទាំងសងខាងនៃប្រែកនេះគេលាក់ជាពន្លួញសម្រាប់

សិកភ្ជាប់ជាមួយប្រែក-ង។ មុខងាររបស់វាគឺ សម្រាប់ទប់បន្ទុករទេះទាំងមូលដែលផ្ទុកក្នុងផ្ទះរទេះ។

**ផ្តិត** ន. ផ្ទាំងកាំដែលគេបោះភ្ជាប់គ្នាជា៤ៗកាំទៅនឹងខ្នង ក្នុងកង់រទេះមួយមាន៤ផ្តិត ក្នុង១ផ្តិតមានកាំ៤។

**ផ្ទះរទេះ/សណ្ដូកនាងដា/កឹងរទេះ** ន. បន្ទុករទេះដែលគេដាក់ពីលើទូករទេះ។

**ភ្លៅរទេះ** ន. ដែកស្បែងឬដែកថ្ពាំងអំពៅដែលគេស៊កក្នុងរន្ធដុំ ធ្លុះពីប្រែកម្ខាងទៅប្រែកម្ខាងមានប្រវែង ១,៩ម.។

**ភ្ញៀ** ន. បន្ទោះឬស្សីតូចៗក្រងជាជញ្ជាំងផ្ទះរទេះ ហើយក្រងភ្ជាប់នឹងរែងភ្ញៀ។

**មាត់តម្រែក** ន. មុខតំណខ្នងកង់រទេះ។

**រែងភ្ញៀ** ន. មេសម្រាប់ក្រងបន្ទោះរនាបជញ្ជាំងរទេះធ្វើពីបន្ទោះឬស្សីរាងរៀវដែលគេបិតរលោង។

**លាក់ស្នាកាំ** ន. ចុងពន្លួញកាំរទេះដែលបញ្ចុះនៅក្នុងខ្នងកង់។

**សន្ទះ** ន. គ្រឿងរទេះសម្រាប់ទប់ឬបិទបាំងអីវ៉ាន់នៃផ្ទះរទេះ។

**សន្ទុះ** ន. ចន្លោះទំនេរពីចុងដុំក្នុងទៅខ្នល់ មានប្រវែង០,១ម.(មួយតឹក) វាមានប្រយោជន៍ធ្វើឱ្យដុំរទេះរត់ចេញចូលស្រួល កុំឱ្យធាប់សឹកដុំ និង ដើម្បីឱ្យគោក្របីអូសទៅធូរមិនតឹង។

**ស្នាយ** ន. ស្នៀតដែលគេសៀតជាមួយនឹងលាក់ស្នាកាំបញ្ចុះទៅក្នុងខ្នងរទេះ។

**ស្រឡោ** ន. ខ្នង់មុខបង្អស់របស់ទូករទេះសម្រាប់ទប់ឬទ្រកូនគ្រែដែលគេភ្ជាប់នៅលើទូករទេះ ដើម្បីឱ្យអ្នកបររទេះអង្គុយ។

**សម្គាល់** វាក្យសព្ទរទេះនេះ អ្នកស្រុកបាត់ដំបងមួយចំនួនធំលែងស្គាល់ហើយ ពីព្រោះសព្វថ្ងៃ អ្នកស្រុកដែលរស់នៅក្នុងខេត្តនេះមួយចំនួនធំគេប្រើតែគោយន្តឬត្រាក់ទ័រអស់ទៅហើយ។ ហើយម្យ៉ាងទៀតការហៅវាក្យសព្ទនេះទៀតសោតក៏មានផ្នែកខ្លះគេហៅខុសពីវាក្យសព្ទរទេះ របស់ខេត្តឯទៀតដែរ។ ក្រុមការងារយើងនឹងចុះទៅស្រាវជ្រាវបច្ចេកសព្ទរទេះនេះនៅតាមបណ្ដាខេត្តដទៃ ដើម្បីយកមកប្រៀបធៀបគ្នានិងដើម្បីយកពាក្យទាំងនេះមកបញ្ចូលក្នុងវចនានុក្រមខ្មែរទុកជាកេរមរតកវប្បធម៌របស់ខ្មែរតទៅ។

# វចនសព្ទតម្បាញ(ខេត្តតាកែវ)

ស្រុកព្រៃកប្បាសមានឃុំចំនួន១៣ ភូមិចំនួន១១០ ប្រជាជនសរុបមានចំនួនប្រហែល ៩៦០០០នាក់ កីតម្បាញក្នុងស្រុកនេះ មានចំនួនប្រមាណ៣០៣៣កី ក្នុងនោះ ឃុំព្រៃផ្ដៅមាន ២៣៨កី ឃុំតាំងយ៉ាបមាន១២២៤កី ឃុំក្តាញ់មាន៩៣៩កី ឃុំចម្ប៉ាមាន១៨៨កី ឃុំចារមាន៤២១កី ឃុំស្នោមាន២៣កី ឃុំកំពែងមាន ជាង១០០កី។

ខាងក្រោមនេះ ជាបច្ចេកសព្ទរបស់អ្នកតម្បាញនៅក្នុងឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

កុង កិ. ស្រាវសូត្រពីក្នុងថ្លាងដែលមានដាក់ស្ងោរសំបុកនាង។

ដាម ន. បន្ទះឈើឬឫស្សីមានប្រវែងប្រមាណ១,២ម.(មួយម៉ែត្រពីរតឹក) មានបន្ទាប្រមាណ០,០២ម.(ពីរសង់ទីម៉ែត្រ)។ គេប្រើដាមសម្រាប់ខ្វាស់ទៃ កុំឱ្យសរសៃសូត្រលាចូលគ្នា។

ក្ដារមូរ ន. ឧបករណ៍សម្រាប់មូរទៃ មូរសរសៃអំបោះ ឬ មូរសរសៃសូត្រ ដើម្បីចាក់ធ្មេញឈើដោយធ្មេញកណ្ដូប។

ធ្មេញកណ្ដូប ន. ឧបករណ៍សម្រាប់ចាក់ធ្មេញឈើ មានប្រវែងប្រមាណ ០,២ម.(ពីរតឹក)មានចុងស្រួច មានរងៀងសម្រាប់ថ្ពក់សរសៃសូត្រដែលសឹកតាមប្រឡោះធ្មេញឈើ។

ទូត្រករ ន. ឧបករណ៍សម្រាប់ទាក់សរសៃអំបោះឱ្យឡើងឱ្យចុះនៅពេលត្បាញ មានប្រវែង១,២ម.(មួយម៉ែត្រពីរតឹក)។ ឈើឬឫស្សីពីរបន្ទះបិតឱ្យមូលមានទំហំប៉ុនម្រាមដៃដាក់មួយនៅពីលើមួយនៅពីក្រោម។ របៀបថ្ពរ បន្ទាប់ពីចាក់ធ្មេញឈើរួចហើយ គេរៀបចំថ្ពរ ដោយយកឈើ ឬ ឫស្សីដែលបិតរួចចំនួនបីគូ (មានន័យថា ទូត្រករត្រូវមានបីចំពោះការត្បាញសូត្រ ដើម្បីបាន ជាហូល ផាមួង...)ដាក់មួយនៅពីលើសរសៃសូត្រ រីឯមួយទៀតដាក់ពីខាងក្រោមសរសៃសូត្រ រួចហើយអ្នកចាក់ត្រករ គេចាប់ផ្ដើមពីចុងម្ខាងនៃឈើនោះ ដោយយកអំបោះឆៅឬសរសៃសូត្រ មកចាក់ប្រទាក់ពីលើទៅក្រោមពីក្រោមទៅលើ ព័ទ្ធទាក់ឈើឬឫស្សីនោះ ដោយឆ្លុះយកសរសៃសូត្រតាមដាមដែលបានខ្វាស់នៅពេលមូរសរសៃសូត្រចូលក្ដារមូរ។ ត្រករមានបី នៅពេលគេ ថ្ពរឬនៅពេលគេចងត្រកររួចហើយ គេយកខ្សែចងចុងឈើឬឫស្សី នៃទូត្រករទាំងសងខាងនៅផ្នែកខាងក្រោម រួចគេយកឈើឬឫស្សីមូលទំហំប៉ុនមេជើងមកធ្វើជាឈ្នាន់សម្រាប់ជាន់ ដើម្បីទាក់ទៃឱ្យម្ដងឡើងម្ដងចុះនៅពេលត្បាញ។

ត្រសាល់ ន. ឧបករណ៍សម្រាប់ចងព្យួរទូត្រករ ដើម្បីងាយស្រួលនៅពេលគេជាន់ឈើឈ្នាន់ទូត្រករនីមួយៗឡើងចុះៗបង្ហាទៃ រួចហើយអ្នកត្បាញអាចបោះត្រល់ចុះឡើងៗបាន។ ចាស់ពីបុរាណ លោកឆ្លាក់ត្រសាល់ជា រូបហង្ស រូបគ្រុឌ ឬ រូបផ្សេងៗជាលម្អ។

ចាងណាង ន. ឧបករណ៍សម្រាប់ចងព្យួរទូត្រករដែរ ប៉ុន្តែវាគឺជាកំណាត់ឈើតូចខ្លីប្រើជំនួសត្រសាល់ នៅពេលគេមិនចេះឆ្លាក់ត្រសាល់។

ធ្មេញឈើ ន. ឧបករណ៍សម្រាប់គោះបង្ហាប់សាច់សំពត់ផង សម្រាប់ខណ្ឌសរសៃអំបោះមួយសរសៃៗឱ្យនៅឃ្លាតពីគ្នាផង ដើម្បីងាយស្រួលគោះបង្ហាប់អំបោះដែលគេបោះចេញពីត្រល់។ធ្មេញឈើ

មានពីរប្រភេទ គឺមួយធ្វើពីដែក ហៅថា ធ្មេញដែក និងមួយទៀតគេធ្វើពីខ្លឹមឈើរឹង ឬធ្វើពីខ្នង ឫស្សីចាស់ហើយរឹង។ ធ្មេញឈើមានប្រវែងប្រមាណ១,២ម. (មួយម៉ែត្រពីរតឹក) ផ្នែកលើហៅថាក្រប ផ្នែកខាងក្រោមហៅថាចង្កា គឺក្របធ្មេញឈើ។ ធ្មេញឈើគេធ្វើតាមចំនួនសូត្រឬគេធ្វើអំបោះតាមចំនួនធ្មេញឈើ បើធ្មេញឈើមានចំនួន៦០ គេប្រើសូត្រ៦០ ផ្លូនដៃដែលមួយផ្លូនមានសូត្រ៤០សរសៃ។

ផ្ស៊ំ ន. ឧបករណ៍សម្រាប់មូរសាច់សំពត់ដែលអ្នកត្បាញ ត្បាញរួចហើយ។ ផ្ស៊ំធ្វើឡើងពីឈើកម្រាស់០,០៥ម. (ប្រាំសង់ទីម៉ែត្រ) បួនជ្រុង មានប្រវែងប្រមាណ១,៣ម. (មួយម៉ែត្របីតឹក) ។ ជ្រុងម្ខាង របស់ផ្ស៊ំ គេឆូតលកសាច់ឈើឱ្យមានជម្រៅពក់លួម តែអាចដាក់បង្កប់ឈើឬឫស្សីដែលបិតរួច ឱ្យមានទំហំប្រមាណប៉ុនគល់ចង្កឹះ សម្រាប់ប្រើខ្ទាស់ក្បាលសាច់សំពត់ដែលត្បាញនៅដើមដំបូងដើម្បីងាយស្រួលមូរសាច់សំពត់ នៅពេលត្បាញបានច្រើន។

ចន្ទល់ ន. ឧបករណ៍សម្រាប់ទល់សាច់សំពត់ដែលត្បាញរួចហើយឱ្យតឹងស្មើសាច់ល្អងាយស្រួលក្នុងការត្បាញ។ ចន្ទល់មានប្រវែងប្រមាណ១ម.ទៅ១,២ម.(មួយម៉ែត្រទៅមួយម៉ែត្រពីរតឹក) ទៅតាមទំហំនៃសាច់សំពត់ដែលត្បាញរួច។ នៅចុងសងខាងចន្ទល់គេស្រោបដែកឬឆ្អឹងសត្វដែលចុងម្ខាងៗមានធ្វើជាបន្លាពីរខ្លីៗនៅទីមត្ថាសម្រាប់ខ្ទាស់ទល់រឹមសាច់សំពត់។

អង្វឹង ន. ឧបករណ៍តម្បាញម្យ៉ាងមានស្លាបបីម្ខាង គេបញ្ចុះស្នួលចំកណ្ដាលទ្រដោយជើងអង្វឹងសម្រាប់ស៊កដុំសរសៃសូត្រដើម្បីខារសូត្រដាក់បំពង់។ អង្វឹងភ្ជាប់នឹងរហាត់ដែលរហាត់នេះមានមុខងារសម្រាប់រវៃ។ អង្វឹងមានពីរប្រភេទ អង្វឹងតូចសម្រាប់រវៃឬកាល់សូត្រពីអង្វឹងមកបំពង់។ អង្វឹងធំសម្រាប់ខាល់គាតដាក់ខ្នាល់(ជាពាក្យអ្នកឃុំក្លាញ់និយាយចំពោះកិរិយាសព្ទ ខារ ថា*ខាល់*, និងហៅ ខ្នារ ថា *ខ្នាល់* ដូច្នេះ)។

គាត ន. សូត្រដែលគេចងឱ្យចេញជាក្រឡាគោមឬក្បាច់ផ្សេងៗ ដោយគេយកប្រដាប់ធ្វើពីឈើ មានរាងជាក្រឡាបួនជ្រុងទ្រវែងមកធ្វើជាឧបករណ៍សម្រាប់ចងពាក់សរសៃសូត្រ។ កាលណាគេចងគាតរួច គេយកគាតដែលចងនោះទៅជ្រលក់ពណ៌ឱ្យបានច្រើនដងដើម្បីបានគ្រប់ពណ៌...។ ពេលជ្រលក់ពណ៌រួច គេយកគាតមកផ្ដាច់ចំណង ហើយយកទៅស៊កនឹងអង្វឹងធំដើម្បីខាល់ (ខារ)គាតនោះចូលខ្នាល់(ខ្នារ *ន.* ធ្វើពីដើមបបោសឬដើមឫស្សី)។ នៅពេលគេខាល់ដាក់ខ្នាល់រួចហើយ គេយកខ្នាល់នោះទៅដាក់ក្នុងត្រល់ទុកសម្រាប់ត្បាញ។

កុង ន. ឧបករណ៍សម្រាប់រវៃសូត្រចេញពីបំពង់។

ព័ន្ធមូរ ន. ឧបករណ៍ជាប់ក្ដារមូរ ដើម្បីគាបសូត្រងាយស្រួលមូរសូត្រ។

ត្រដោក ន. ឧបករណ៍សម្រាប់ចងរឹតក្ដារមូរជាមួយនឹងឈើរឹតដើម្បីបន្ធូរឬបន្តឹងផ្ទៃតម្បាញ។

ពក ន. ឧបករណ៍ប្រវែង១,៣ម.(មួយម៉ែត្របីតឹក) ធ្វើពីឫស្សីដកម៉ែឬឈើមូល (តំឡូវអ្នកស្រុកនៅក្នុងស្រុកព្រែកប្បាស ជាពិសេសអ្នកឃុំក្លាញ់ភាគច្រើនគេយកទុយោទឹកមកធ្វើ)ទំហំប៉ុនមេដៃសម្រាប់នាំដាមពេលមូរផ្ទៃចូលក្ដារមូរ និង សម្រាប់ឆ្លាស់ផ្ទៃ ដើម្បីចងថ្កូរឬចងទូត្រករ។

ក្ដារត្រករ ន. ឧបករណ៍សម្រាប់ថ្កូរ ធ្វើពីឈើ មានបន្ទារ០,១ម.(មួយតឹក) ប្រវែង០,២ម.(ពីរតឹក)។

ប្រែង ន. ឧបករណ៍សម្រាប់សិតសូត្រ ធ្វើពីកន្ទុយគោឬក្របី មានស្នូកធ្វើពីឈើឬធ្វើពីស្នែងក្របី មានប្រវែង០៣ម.(បីតឹក)។

កូនដាម ន. ឧបករណ៍សម្រាប់ជាជំនួយក្នុងការរើសសរសៃសូត្រចូលទូត្រករ ធ្វើពីបន្ទះឫស្សីស្ដើង ទំហំប៉ុនស្លឹកស្រូវ ប្រវែង១,៣ម.(មួយម៉ែត្របីតឹក)។
ជើងសេះ ន. ឧបករណ៍ភ្ជាប់គម្រូបធ្មេញឈើទៅនឹងចង្កា។
ចង្កា ន. គម្របផ្នែកខាងក្រោមគម្របធ្មេញឈើ។

នៅមានបច្ចេកសព្ទតម្បាញមួយចំនួនទៀត ដូចជាៈ ក្បៀយ, អ័ក្ស, ឡុត, ត្រល់ ...។
ចំណាំ សូត្រមួយដុំ = គុលី = ២គីឡូក្រាម ត្បាញរួចបាន១០ទៅ១១ក្បិន។

# អក្សរសិល្ប៍ប្រជាប្រិយជនជាតិជង

## សេចក្ដីផ្ដើម

ជនជាតិជង ជាជនជាតិមួយក្នុងចំណោមជនជាតិដើមផ្សេងៗទៀតដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដែរ។ នៅខេត្តពោធិ៍សាត់ ជនជាតិនេះរស់នៅក្នុងឃុំអូរសោម ស្រុកវាលវែង ដែលជាស្រុកមួយនៅដាច់ស្រយាលពីទីរួមខេត្ត។ តាមការរៀបរាប់របស់លោកអ៊ឹ ព្រុំ ជុំ អាយុ៧០ឆ្នាំ ជាជនជាតិជង បានអះអាងថា ជនជាតិជងដែលរស់នៅទីនេះ គឺមានតាំងពីសម័យអាណានិគមនិយមបារាំងមកម្ល៉េះ ពួកគេច្រើនហៅខ្លួនឯងថា *ជងសាត់អន្ទ្រាត សាត់អន្ទ្រែង* មានន័យថា ជាអ្នករត់ចោលស្រុកដោយសារបារាំងធ្វើបាប ជំរិតទារពន្ធធ្ងន់ធ្ងរពេក។

លោក សុក បឿន មេឃុំអូរសោមមានប្រសាសន៍ថា ជនជាតិជងនៅឃុំអូរសោមមានចំនួន២១៥គ្រួសារ ស្មើនឹង៧៤១នាក់។ ជនជាតិជងទាំងនោះ មានប្រពៃណីទំនៀមទម្លាប់រស់នៅមិនខុសពីជនជាតិខ្មែរយើងប៉ុន្មានទេ ការនិយាយមានលក្ខណៈរដឺនៗបន្តិច។ ពួកគេកាន់ព្រះពុទ្ធសាសនា បួសជាព្រះសង្ឃ ប្រារព្ធពិធីផ្សេងៗដូចខ្មែរដែរ។ រហូតមកដល់បច្ចុប្បន្ន ជនជាតិជងពុំមានលក្ខណៈអ្វីកត់សម្គាល់ថា មានលក្ខណៈខុសប្លែកពីជនជាតិខ្មែរឡើយ ទាំងការរស់នៅនិងការស្លៀកពាក់។

ការសិក្សាស្រាវជ្រាវរបស់យើង ធ្វើឡើងត្រឹមតែការប្រមូលចងក្រងនូវរឿងព្រេងនិទានប្រជាប្រិយនិងកម្រងចំណេះដឹងប្រពៃណីទាំងឡាយទុកជាឯកសារតែប៉ុណ្ណោះ។ រឿងព្រេងនិទានប្រជាប្រិយមួយចំនួន ដែលយើងប្រមូលចងក្រងបាន មានខ្លឹមសារល្អសម្រាប់អប់រំ ក៏ដូចជាការពន្យល់នូវបាតុភូតផ្សេងៗក្នុងជីវភាពរស់នៅ។

រឿងទាំងប៉ុន្មានដែលចុះផ្សាយនេះ ជាចំណែកតូចមួយនៃទិន្នន័យស្រាវជ្រាវ ដែលរក្សានូវខ្លឹមសារទាំងស្រុង ដោយពុំមានធ្វើការវិភាគទេ។

## រឿងបងប្អូនបីនាក់

កាលដើមឡើយ ក្នុងគ្រួសារមួយមានកូនបីនាក់ កូនទី១ឈ្មោះចៅជ័យ កូនទី២ឈ្មោះចៅសួស និង កូនពៅឈ្មោះចៅសែន។ អ្នកទាំងបីត្រូវឪពុកម្ដាយប្រើឱ្យទៅចាំពង្រោះនៅឯក្រៅភូមិ។ ចៅជ័យនិងចៅសួសកើតសេចក្ដីខឹងនឹងម្ដាយដោយសារគាត់ស្រឡាញ់ចៅសែនជាងពួកខ្លួន ដោយសារការប្រចណែននេះ ថ្ងៃមួយ ពួកគេក៏គេចពីចាំពង្រោះលួចរត់ចូលព្រៃមិនឱ្យចៅសែនដឹង។ ចូលដល់ព្រៃដាច់ឆ្ងាយពីភូមិ អ្នកទាំងពីរក៏បាញ់បានសត្វដំរីមួយ ហើយនាំគ្នាដុតសាច់ដំរីនោះបរិភោគ រួចដេកលង់លក់នៅក្នុងព្រៃនោះទៅ។ ចំណែកចៅសែនវិញ លុះដឹងថាបងៗលួចរត់មិនឱ្យខ្លួនទៅជាមួយ ក៏លួចធ្វើដំណើរតាមពីក្រោយរហូត ដោយមិនឱ្យបងៗដឹងឡើយ។ យប់ស្ងាត់បន្តិចក៏មានយក្ខិនីមួយមកស៊ីសាច់ដំរី ចៅជ័យនិងចៅសួសបើកភ្នែកឡើងឃើញយក្ខិនីក៏សន្លប់បាត់ស្មារតីទាំងពីរនាក់ ចៅសែនឃើញដូច្នេះ ក៏ចេញមកប្រយុទ្ធជាមួយយក្ខិនីរហូតឈ្នះ។ យក្ខិនីឃើញចៅសែនមានយុទ្ធសិល្ប៍ខ្លាំងពូកែ ក៏អង្វរឱ្យដោះលែងខ្លួន ចៅសែននិយាយថា «យើងដោះលែងបាន ប៉ុន្តែឯងមិនត្រូវ

ឱ្យយើងឃើញមុខទៀតទេ ទោះនៅកន្លែងណាក៏ដោយ» យក្ខិនីឮដូចនេះក៏អរគុណចៅសែនយ៉ាងខ្លាំង ហើយហោះចេញបាត់ទៅ។ ចៅជ័យនិងចៅសួសភ្ញាក់ពីសន្លប់វិញ ឃើញសាច់ដំរីនៅសល់ទាំងអស់ នឹកឆ្ងល់ថា ហេតុអីក៏យក្ខិនីមិនស៊ី? ឬក៏មានអ្នកណាមកជួយ?។

ច្រើនថ្ងៃខែកន្លងផុត សាច់ដំរីក៏អស់ រកសត្វផ្សេងទៀតក៏មិនបាន អ្នកទាំងពីរដេកស្ដូកស្ដឹង ដោយគ្មានអាហារបរិភោគ។ ចៅសែនឃើញបងៗមានលក្ខណៈបែបហ្នឹងក៏យកបាយពីរដុំមកដាក់នៅក្បែរកន្លែងដេករបស់បងៗរៀងរាល់ថ្ងៃ ចៅជ័យនិងចៅសួសភ្ញាក់ឡើងឃើញបាយ ក៏នឹកឆ្ងល់ថា អ្នកណាចិត្តល្អម្ល៉េះយកបាយមកឱ្យពួកយើងបរិភោគ ប្អូនយើងទេដឹង? ឮពាក្យនេះ ចៅជ័យសម្លុតចៅសួសថា «កុំនិយាយពីឈ្មោះអាសែន! យើងស្អប់វាណាស់ តាំងពីដើមរហូតមកម៉ែស្រឡាញ់វាជាងពួកយើងទាំងពីរ» ចៅសួសក៏ស្ងាត់មាត់។

ចៅជ័យនិងចៅសួសបានធ្វើដំណើរផ្សងព្រេងទៅមុខទៀត ក៏ឃើញសាលាមួយនៅកណ្ដាលព្រៃ ហើយក៏នាំគ្នាចូលសម្រាកនៅទីនោះ ស្រាប់តែឃើញយក្ខិនីកាលពីមុន ក៏គិតថា «យប់នេះយើងនឹងលួចរត់ចេញ បើមិនដូច្នេះទេយក្ខិនីពិតជាស៊ីពួកយើងពុំខាន»។ មិនទាន់យប់ផងយក្ខិនីមកបម្រុងនឹងស៊ីអ្នកទាំងពីរ តែគាប់ជួនពេលនោះ ចៅសែនឡើងមកលើសាលានោះដែរ យក្ខក្រឡេកឃើញចៅសែនភ្លាម ក៏ហោះចេញវឹងបាត់ទៅ។ ជ័យនិងសួស នឹកឆ្ងល់ក្នុងចិត្តថា «ហេតុអីចៅសែនមកដល់ទីនេះដែរ?» តែពួកគេមិនមាត់ ហើយអ្នកទាំងបីក៏ចូលក្នុងសាលា ស្រាប់តែឃើញនាងពៅកំពុងជាប់ចំណងដែលគេចងទុកសម្រាប់ឱ្យយក្ខិនីស៊ីចុងក្រោយគេ ពួកគេក៏នាំគ្នាជួយស្រាយចំណងឱ្យនាង។ នាងបាន យករឿងរ៉ាវដែលយក្ខិនីអុកឡុកក្នុងនគររបស់នាងប្រាប់ដល់អ្នកទាំងបីនិងប្រាប់អ្នកទាំងបីកុំឱ្យស្នាក់នៅសាលានេះ ព្រោះវាជាកន្លែងយក្ខិនី។ ចៅសែនបានប្រាប់ទៅនាងវិញថា «ខ្ញុំមិនខ្លាចយក្ខិនីនោះទេ» ព្រោះយក្ខិនីនេះត្រូវខ្ញុំបង្ក្រាបឱ្យបាក់ស្បាតរួចម្ដងមកហើយ។

ចំណែកស្ដេចដែលកំពុងសោយរាជ្យក្នុងនគរនេះវិញ ព្រះអង្គបានប្រើអាមាត្យឱ្យមកយកសពនាងពៅជាបុត្រីក្រែងមាននៅសេសសល់ឆ្អឹងបន្តិចបន្តួចយកទៅធ្វើបុណ្យឧទ្ទិសកុសលឱ្យព្រះនាង តែពេលអាមាត្យមកដល់ ស្រាប់តែឃើញនាងពៅនៅរស់មិនទាន់ស្លាប់ អាមាត្យក៏សួរព្រះនាង ព្រះនាងក៏ប្រាប់អាមាត្យថា «ខ្ញុំមានជីវិតនៅរស់ ដោយសារបានបងចៅសែនមកជួយទាន់ពេល កុំអីត្រូវយក្ខិនីស៊ីខ្ញុំបាត់ទៅហើយ»។ ក្រោយពីស្ដាប់នាងពៅរ៉ាយរ៉ាប់ចប់ អាមាត្យក៏នាំព្រះនាងទៅរាជវាំងវិញ ស្ដេចត្រេកអរខ្លាំងណាស់ពេលឃើញបុត្រីនៅមានព្រះជន្ម នាងក៏យករឿងទាំងនេះទូលដល់ព្រះបិតា។ ក្រោយពីបានជ្រាបថា ចៅសែនជាអ្នកខ្លាំងពូកែ សូម្បីតែយក្ខិនីដែលគេខ្លាចគ្រប់គ្នានោះ ក៏ត្រូវចៅសែនបង្ក្រាបឱ្យខ្លបខ្លាចដែរ។ ស្ដេចបានប្រើអាមាត្យឱ្យនាំពលរេប៉ាវគងប៉ាវឃ្មោះនិងថែមទាំងមានកៅយុកកៅយា(ភ្លេង)លេងតាមផ្លូវទាំងយប់ទាំងថ្ងៃ មកដង្ហែចៅសែនទៅរាជវាំង។ ចៅជ័យនិងចៅសួសព្រមទាំងអ្នកស្រុកគ្រប់គ្នាគិតថា គេយកចៅសែនទៅសម្លាប់ចោល។ ពេលដល់រាជវាំង ស្ដេចបញ្ជាឱ្យអាមាត្យយកដំរីប្រេណាំងនិងសម្លៀកបំពាក់ស្អាតសមរម្យឱ្យទៅចៅសែនជិះនិងស្លៀកពាក់ ដើម្បីចូលគាល់ស្ដេចនៅឯដំណាក់។ ចៅសែនចូលទៅដល់ ស្ដេចមានបន្ទូលថា កូនអើយនៅព្រះនគររបស់យើងមានយក្ខកំណាចមួយតាមយាយីប្រជារាស្ត្ររបស់យើងរៀងរាល់ថ្ងៃ ថ្ងៃណាក៏វាស៊ីមនុស្សដែរ ធ្វើឱ្យយើងខ្វាយខ្វល់នៅមិនបានសុខសោះ។ តើកូនមានមធ្យោបាយអ្វីទប់ទល់ជាមួយយក្ខិនីនោះទេ?

ចៅសែនក៏ក្រាបទូលវិញថា «សូមព្រះអង្គកុំបារម្ភអី យក្ខិនីនោះវារត់បាត់ហើយ វាលែងហ៊ានស៊ីមនុស្សនៅក្នុងព្រះនគរនេះទៀតហើយ ព្រោះត្រូវទូលព្រះបង្គំបំបាក់ស្មារតីវាឱ្យខ្លបខ្លាចម្តងរួចមកហើយកាលពីពេលមុននេះ។ ដូច្នេះពេលវាឃើញទូលព្រះបង្គំនៅទីនេះ វាមិនហ៊ានមកឡើយ»។ ស្តេចឮចៅសែននិយាយដូច្នេះ ព្រះអង្គត្រេកអរយ៉ាងខ្លាំង ដោយគិតថាចាប់ពីថ្ងៃនេះទៅ ប្រជារាស្ត្ររបស់ទ្រង់នឹងបានសុខសាន្តជាពុំខាន។ ក្រោយពីបានសំណេះសំណាលជាមួយចៅសែនអំពីយក្ខិនីរួចហើយ ស្តេចក៏ចាត់ចែងរៀបអភិសេកបុត្រីពៅនិងចៅសែនជាគូស្វាមីភរិយានឹងគ្នា។ បន្ទាប់មក ស្តេចសួរទៅចៅសែនថា តើបុត្រមកទីនេះ មានគ្នាប៉ុន្មាននាក់? ចៅសែនទូលថា បុត្រមកទីនេះមានគ្នាបីនាក់ បុត្រនិងបងប្រុសពីរនាក់ទៀត ម្នាក់ឈ្មោះចៅជ័យនិងម្នាក់ទៀតឈ្មោះចៅសួស ពួកគាត់ទាំងពីរនាក់នោះស្នាក់នៅឯសាលាឯណោះ។

ស្តេចបានចាត់ឱ្យអាមាត្យយកដំរីទៅទទួលអ្នកទាំងពីរ។ ឯចៅជ័យនិងចៅសួស ពេលឃើញអាមាត្យនាំពលរេហ៍និងដំរីធ្វើដំណើរយ៉ាងគគ្រឹកគគ្រេងសំដៅមករកខ្លួនដូចនេះ ក៏ភិតភ័យយ៉ាងខ្លាំងនឹកស្មានថាគេនឹងមកចាប់ខ្លួនយកទៅសម្លាប់ចោល ក៏នាំគ្នារត់គេចពីក្បួនដង្ហែនោះ គ្មានងាកក្រោយ។ ចំណែកចៅសែនដែលកំពុងជិះលើខ្នងដំរីនោះ បានស្រែកហៅបងទាំងពីរឱ្យឈប់រត់ ដោយបញ្ជាក់ថាខ្ញុំជាប្អូនរបស់បងទេ បងកុំខ្លាចអី ប្អូននឹងនាំបងទាំងពីរទៅក្នុងព្រះរាជវាំង។ ចៅជ័យនិងចៅសួសនៅតែមិនស្តាប់ការហៅរបស់ប្អូន គិតតែពីរត់ ព្រោះអ្នកនៅលើខ្នងដំរីនោះពួកគេឃើញមនុស្សស្លៀកពាក់ជាស្តេច គឺពិតជាមិនមែនប្អូនរបស់ខ្លួនទេ ពួកគេប្រើល្បិចដើម្បីចាប់ខ្លួន។ អ្នកទាំងពីរនៅតែមិនព្រមឈប់ ចៅសែនក៏បញ្ជាក់ប្រាប់នូវរឿងរ៉ាវដែលកន្លងផុតទៅថា បងនៅចាំទេ កាលពីមុនខ្ញុំតាមជួយបងរហូតមក ដូចជាវាយយក្ខិនីដែលមកស៊ីសាច់ដំរីរបស់បងនិងដុំបាយដែលខ្ញុំបាន ដាក់ឱ្យបងបរិភោគរៀងរាល់ថ្ងៃជាដើម។ ឮសម្តីនេះ ទើបចៅជ័យនិងចៅសួសឈប់រត់ គិតថាជាប្អូនរបស់ខ្លួនពិតប្រាកដមែន ហើយក៏អរគុណប្អូនដែលបានជួយពួកខ្លួនកន្លងមកនិងយល់ព្រមទៅរាជវាំងជាមួយចៅសែន។

បន្ទាប់ពីនាំចៅជ័យនិងចៅសួសចូលទៅរស់នៅក្នុងរាជវាំងនោះមក ចៅសែនបានធ្វើដំណើរផ្សងព្រេងទៅកាន់នគរផ្សេងទៀត។ ដើរកាត់ព្រៃចូលវាលកាត់វាលចូលព្រៃអស់ពេលជាច្រើនថ្ងៃ ហើយក៏បានជួបនឹងសាលាមួយនៅក្នុងព្រៃស្ងាត់ជ្រងំ។ ចៅសែនដើរចូលក្នុងសាលានោះស្រាប់តែឃើញមានស្គរមួយយ៉ាងធំ ចៅសែនក៏យកដំបងទូងស្គរនោះលេង ស្រាប់តែឮសំឡេងមនុស្សបន្លឺចេញពីស្គរនោះថា «បងកុំវាយអី បើចង់ស៊ីក៏ស៊ីទៅ! កុំចាំបាច់វាយឱ្យខ្ទរខ្ទើមប្រមាត់ខ្ញុំធ្វើអ្វី?» ឮដូច្នេះចៅសែនក៏ហែកស្គរនោះមើល ក៏បានឃើញមនុស្សស្រីម្នាក់ រួចក៏សួរនាងថា «តើនាងនៅក្នុងស្គរនេះធ្វើអ្វី?» នាងនោះបានឆ្លើយតបទៅចៅសែនវិញថា «ព្រះបិតារបស់ខ្ញុំបានយករូបខ្ញុំមកឱ្យយក្ខិនីស៊ី ខ្ញុំនេះជាមនុស្សចុងក្រោយគេហើយ»។ ពេលនោះយក្ខិនីក៏ដើចូលមកក្នុងសាលា គ្រាន់តែក្រឡេកឃើញចៅសែនភ្លាមយក្ខិនីគេចខ្លួនបាត់មួយរំពេច។ ចំណែកឯស្តេចនៅនគរនេះក៏បានប្រើអាមាត្យឱ្យមកយកឆ្អឹងនាងពៅក្រែងនៅមានសេសសល់បន្តិចបន្តួចធ្វើបុណ្យឧទ្ទិសកុសលឱ្យនាង។ តែនៅពេលអាមាត្យមកដល់ឃើញព្រះនាងនៅរស់ អាមាត្យធ្វល់ក៏សួរព្រះនាង ព្រះនាងក៏ប្រាប់រឿងរ៉ាវទាំងអស់ដល់អាមាត្យ។ លុះមកដល់ព្រះរាជវាំង នាងពៅបាននិយាយពីរឿងរ៉ាវទាំងប៉ុន្មានដែលចៅសែនបានជួយនាងឱ្យរួចផុតពីសេចក្តីស្លាប់ ប្រាប់ដល់ព្រះបិតា។

ក្រោយពីបានជួយបុត្រីស្តេចនគរនេះឱ្យរួចផុតពីគ្រោះថ្នាក់នោះមក ចៅសែនបានវិលត្រឡប់ទៅកាន់នគរដើមវិញ ហើយបានណែនាំចៅជ័យឱ្យទៅគ្រប់គ្រងនគរថ្មី។ ចៅជ័យប្រកែកជាមួយចៅសែន ដោយសម្អាងថាខ្លួនគ្មានសមត្ថភាព ជាពិសេសមិនអាចកម្ចាត់យក្សិនីបាន។ ចៅសែនបានសន្យានឹងចៅជ័យថា ខ្ញុំនឹងប្រើមន្តអាគមធ្វើឱ្យបងមានរូបរាងកាយដូចរូបខ្ញុំ ដើម្បីឱ្យយក្សិនីខ្លបខ្លាចបង។ ចៅជ័យក៏ព្រមធ្វើដំណើរតាមប្អូនទៅកាន់សាលានៅក្នុងព្រៃនោះ ហើយចៅសែនក៏បានប្រើមន្តអាគមធ្វើឱ្យចៅជ័យមានរូបរាងដូចខ្លួនពិតប្រាកដ។ ស្តេចនគរនេះបានរៀបចំពលសេនារួមទាំងដំរីផងនាំចៅសែនចូលទៅក្នុងរាជវាំង ចៅជ័យក្លែងខ្លួនត្រូវរៀបអភិសេកជាមួយបុត្រីស្តេច រួចបានសោយរាជ្យសម្បត្តិក្នុងនគរនោះទៅ។ មុននឹងចេញដំណើរផ្សងព្រេងបន្តទៀត ចៅសែនបានផ្តាំចៅជ័យថាសូមបងនឹកនាដល់ឪពុកម្តាយរបស់យើងផង។

ចៅសែនបានធ្វើដំណើរផ្សងព្រេងទៅដល់នគរស្តេចកុជង្គនាគ ហើយបានប្រលោមស្នេហ៍បុត្រីស្តេចកុជង្គនាគ ជាហេតុធ្វើឱ្យស្តេចកុជង្គនាគខឹងយ៉ាងខ្លាំង ហើយបានចាប់ចៅសែនដាក់ទ្រុងដែក។ ពេលឃើញស្តេចកុជង្គនាគនិងពលសេនានាំគ្នារុញសំពៅដែលជាប់កឿងនៅលើឆ្នេរសមុទ្រឱ្យចុះទៅក្នុងទឹកវិញពុំរួច ចៅសែនក៏និយាយចំអកទៅកាន់ពួកអាមាត្យស្តេចកុជង្គនាគថា «អាមាត្យអើយ អាមាត្យ រុញប៉ុណ្ណឹងមិនរួច គេធ្លឹះតែចុងជើងក៏រួចដែរ!»។ ពួកអាមាត្យឮដូច្នេះខឹងខ្លាំងណាស់ ក៏ទៅទូលស្តេច។ ស្តេចក៏បញ្ជាឱ្យគេដោះលែងចៅសែនពីទ្រុងដែក ហើយចៅសែនបានយកចុងជើងទៅធ្លឹះសំពៅតែបន្តិច ក៏រអិលចូលទៅក្នុងទឹកភ្លាម។ ដោយឃើញភាពអស្ចារ្យរបស់ចៅសែនយ៉ាងនេះ ស្តេចកុជង្គនាគបានហៅចៅសែនមកសួរថា «ឯងអាចទប់ទល់ជាមួយស្តេចក្រុងចិនបានទេ? ដ្បិតស្តេចក្រុងចិនខ្លាំងណាស់»។ ចៅសែនឆ្លើយថា «ទូលព្រះបង្គំមិនហ៊ានអួតទេ ព្រោះខ្ញុំមិនមែនជាអ្នកខ្លាំងពូកែអ្វីដែរ តែខ្ញុំអាចសាកល្បងប្រយុទ្ធជាមួយស្តេចក្រុងចិននោះបាន»។ ស្តេចកុជុង្គនាគយល់ព្រមឱ្យចៅសែននាំកងទ័ព៣ស្បែក[១]ទៅប្រយុទ្ធជាមួយស្តេចក្រុងចិន ប៉ុន្តែចៅសែនសុំមិនយកកងទ័ពច្រើនទេ គឺយកតែបីនាក់បានហើយ ម្នាក់សម្រាប់អេះរមាស់ ម្នាក់សម្រាប់ដាំបាយដងទឹក និងម្នាក់ទៀតសម្រាប់អុចបារី។ ចៅសែនជិះសំពៅទៅច្បាំងជាមួយស្តេចក្រុងចិនដែលមានកងទ័ពយ៉ាងច្រើនស្អេះស្កះណែនតាន់តាប់។ ស្តេចក្រុងចិនគិតថាគ្នាតែពីបីនាក់ហ្នឹងបាញ់មួយគ្រាប់ស្លាប់អស់ហើយ តែកងទ័ពស្តេចក្រុងចិនបាញ់អស់រយៈពេលប្រាំពីរយប់ប្រាំពីរថ្ងៃនៅតែពុំអាចសម្លាប់ខាងចៅសែនបាន។ ទ័ពចិនសម្រុកបាញ់ហូតអស់គ្រាប់ គិតថាចៅសែនស្លាប់ តែពេលផ្សែងរសាត់បាត់អស់ ឃើញចៅសែននៅរស់ដដែល។ ស្តេចក្រុងចិនលាន់មាត់ថា «យីអានេះ ពូកែមែន!»។ ចៅសែនសួរថា តើពួកអ្នកបាញ់អស់គ្រាប់ឬនៅ? ពួកចិនឆ្លើយថា បាញ់អស់គ្រាប់ហើយ។ ចៅសែនប្រាប់ថា បើអ៊ីចឹងយើងនឹងបាញ់អ្នកវិញម្តង គឺយើងបាញ់តែមួយគ្រាប់ ពួកអ្នកនឹងស្លាប់ទាំងអស់។ ឮដូចនេះ ពួកកងទ័ពក្រុងចិនមានការភិតភ័យយ៉ាងខ្លាំង ក៏អង្វរមិនឱ្យចៅសែនបាញ់កងទ័ពរបស់ខ្លួន ដោយសន្យាជូនមាសប្រាក់កែវកងជាច្រើន

---

[១] ១ស្បែក មានន័យថា គេដាក់ស្បែក(ស្បែកគោ...)ឱ្យទាហានដើរជាន់ រហូតស្បែកនោះដាច់រយៈពេលណា គេរាប់ថា ១ស្បែក។

ដល់ចៅសែន លើសពីនេះទៀតនឹងលើកបុត្រីពៅឱ្យចៅសែនផងដែរ តែចៅសែនប្រកែក ហើយសុំឱ្យបុត្រីស្តេចក្រុងចិននេះ រៀបអភិសេកជាមួយចៅសួសវិញ។ នាងពៅបុត្រីស្តេចក្រុងចិនមានសក់ក្រអូបខ្លាំងណាស់ ជ្រុះមួយសរសៃក្រអូបសព្វកន្លែង។

ចៅសែនបានរៀបអភិសេកនឹងនាងសុវណ្ណលេខាជាបុត្រីស្តេចកុជង្គនាគរួច ចៅសែននិងចៅសួសក៏ទៅក្រាបថ្វាយបង្គំលាព្រះបិតាក្មេកចេញរកឪពុកម្តាយបង្កើតរបស់ខ្លួន។ បិតាក្មេកក៏អនុញ្ញាតឱ្យព្រមទាំងប្រគល់ពលសេនា៤ស្បែកឱ្យមកតាមខ្លួនថែមទៀត។ ចៅសែននិងចៅសួសក៏នាំគ្នាធ្វើដំណើរត្រឡប់មកនគរខ្លួនវិញ ដោយឆ្លងកាត់នគរចៅជ័យគ្រប់គ្រង។ ចៅជ័យឃើញក្បួនដំណើររបស់ចៅសែននិងចៅសួសមានការភ្ញាក់ផ្អើលនិងភិតភ័យយ៉ាងខ្លាំង ដោយគិតថា ពួកសត្រូវមកយាយីនគររបស់ខ្លួន។ ចៅសែននិងចៅសួសបានចុះពីលើខ្នងដំរីស្ទុះទៅឱបបងរបស់ខ្លួនទើបចៅជ័យស្គាល់ថាជាប្អូនប្រុសទាំងពីរ។ បងប្អូនទាំងបីនាក់បានសំណេះសំណាលគ្នាដោយក្តីនឹករលឹក។ ចៅជ័យលាបិតាក្មេករួមដំណើរជាមួយប្អូនៗទៅលេងឪពុកម្តាយ បិតាក្មេកបានប្រគល់ពលសេនា២ស្បែកឱ្យមកតាមខ្លួន។ ក្បួនដំណើរយ៉ាងគគ្រឹកគគ្រេងរបស់អ្នកទាំងបីនាក់នេះ ធ្វើឱ្យអ្នកស្រុក ញាតិមិត្ត បងប្អូនក្នុងនគរកំណើតរបស់ខ្លួនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

បងប្អូនទាំងបីចូលទៅថ្វាយបង្គំឪពុកម្តាយ ដោយនិយាយប្រាប់ថា ពួកខ្ញុំទាំងបីនាក់ជាកូនរបស់ពុកម៉ែ។ ឪពុកម្តាយមានការភ្ញាក់ផ្អើលហើយនិយាយថា កូនរបស់ពួកខ្ញុំស្លាប់អស់ហើយ។ កូនទាំងបីឆ្លើយព្រមគ្នាថា ខ្ញុំឈ្មោះចៅជ័យ ខ្ញុំឈ្មោះចៅសួស ខ្ញុំឈ្មោះចៅសែន។ ក្រោយពីស្គាល់គ្នាថាជាឪពុកម្តាយនិងកូនច្បាស់ហើយ ពួកគេក៏ស្ទុះឱបគ្នា ព្រមទាំងថ្លែងសារទុក្ខប្រាប់គ្នាទៅវិញទៅមកប្រកបដោយក្តីក្តុកក្តួលឥតឧបមា។ ចៅជ័យនិងចៅសួសបានប្រាប់ឪពុកម្តាយថា «ពួកកូនមានភ័ព្វសំណាងក៏ដោយសារតែបុណ្យបារមីរបស់ប្អូនសែនដែរ»។ ឪពុកម្តាយដឹងដូច្នេះ ក៏និយាយថា នគរយើងនឹងមានសេចក្តីសុខចម្រើនចាប់ពីពេលនេះតទៅ ព្រោះកូនជាអ្នកមានបុណ្យបារមីកសាងពូជសាសន៍ជនជាតិជងយើង។ នគរចៅសែន ជានគរខ្មែរនេះឯង ហើយចាប់ពីពេលនោះមកនគរខ្មែរមានការរីកចម្រើនមានឈ្មោះល្បីល្បាញធ្វើឱ្យនគរនានាមានការខ្លាចញញើត មិនហ៊ានមើលងាយនគរខ្មែរឡើយ។



លោកតា **អ៊ុច ចេ៉ច** អាយុ៨៧ឆ្នាំ ជនជាតិជង នៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ និទានរឿង**បងប្អូនបីនាក់**។

# ឯកតារង្វាស់ប្រវែង និង ឯកតារង្វាស់ទម្ងន់
# ដែលមាននៅក្នុងបទានុក្រមបាលី ម៉ឺង សែស និង
# មាននៅក្នុងវចនានុក្រមខ្មែរ

| ល.រ. | ទំព័រ | ពាក្យ | ពន្យល់ន័យ |
|---|---|---|---|
| ១ | ១១៧ | កោសោ<br>(មិនមែនជាប.សំ.) ទេ | មួយក្រោសត្រូវជា៥០០ជួរធ្នូ; ពងល្វា (ដូចអណ្ឌំ); គំនរទ្រព្យ ឬ ឃ្លាំង; ប្រាក់ (ដូចហិរញ្ញំ)។ |
| ២ | ១២០ | កណ<br>(អាចជារង្វាស់) | កុណ្ឌក (កុន្ទក់) (ដូចជញ្ញត្ត); តូច, តិច, ល្អិត(ដូចសុខុម) |
| ៣ | ១២៧ | កុម្ភ | ចំនួន១០អម្ពណ; ពោងដំរី (ដូចមាតង្គមុទ្ធបិណ្ឌ); ក្អម, ឆ្នាំង (ដូចឃដ)។ |
| ៤ | ៩ | អណុ<br>(អាចជា រង្វាស់ប្រវែង) | ១អណុ ចំនួន៣៦បរមាណុ; តូច, តិច, ឆ្មារ, ល្អិត(ដូចចុល្លំ);<br>៣៦បរមាណុ = ១អណុ<br>៣៦អណុ = ១តជ្ជារី<br>៣៦តជ្ជារី = ១រថរេណុ<br>៣៦រថរេណុ = ១លិក្ខា<br>៧លិក្ខា = ១ឩកា (ចៃ)<br>៧ឩកា = ១ធញ្ញមាស<br>៧ធញ្ញមាស = ១អង្គុល (ធ្នាប់) |

| | | | |
|---|---|---|---|
| | | | (អង្គុលំ មួយធ្នាប់ ប្រមាណ៧ធញ្ញមាស)<br>១២ធ្នាប់ = ១វិទត្ថិ (ចំអាម)<br>២ចំអាម = មួយហត្ថ |
| ៥ | ២១ | អព្ភន្តរំ<br>(រង្វាស់ប្រវែង) | អព្ភន្តរមួយប្រវែង២៨ហត្ថ; ខាងក្នុង, រវាង, ចន្លោះ, រយៈ (ដូចអន្តរំ)។ |
| ៦ | ១៣០ | ខណមុហុត្តោ<br>(រង្វាស់ពេល)<br><br><br><br><br><br><br>ខណលយោ | មួយខណមុហុត្ត ចំនួន១០មុហុត្ត, កាលដែលផ្ទាត់ម្រាមដៃបានដប់ដង ហៅថាមួយខណៈ,<br>១០ខណៈ ជា ១លយៈ[១],<br>១០លយៈ ជា ១ខណលយៈ,<br>១០ខណលយៈ ជា ១មុហុត្ត<br>១០មុហុត្ត ជា ១ខណមុហុត្ត។<br><br><br>១ខណលយោ ជា ១០លយៈ<br>១០លយៈ ជា ១ខណលយៈ,<br>១០ខណលយៈ ជា ១មុហុត្ត,<br>១០មុហុត្ត ជា ១ខណមុហុត្ត ។ |
| ៧ | ១៣១ | ខណោ | ១ខណៈ ចំនួន១០អច្ឆរកាល គឺ |

[១] ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ភាគ១-២, ឆ្នាំ១៩៦៧-៦៨. ទំព័រ១០៩៥ ។

| | | | |
|---|---|---|---|
| | | (រង្វាស់ពេល) | កាលដែលផ្ទាត់ម្រាមដៃ។ |
| ៨ | ១៤២ | គាវុតំ<br>(រង្វាស់ប្រវែង) | ១គាវុត ចំនួន៨០ឧសភ ;<br>៧ហត្ថ ជា ១យដ្ឋិ<br>២០យដ្ឋិ ជា ១ឧសភ<br>៨០ឧសភ ជា ១គាវុត<br>៤គាវុត ជា ១យោជន៍ ។ |
| ៩ | ១៤៤ | គុញ្ជា<br>(រង្វាស់ទម្ងន់) | ១គុញ្ជា ចំនួន៤គ្រាប់ស្រូវ<br>២គុញ្ជា ចំនួន ១មាសក<br>គឺទម្ងន់១គ្រាប់សណ្ដែករាជមាស;<br>ទំពាំងបាយជូរ (ដូច ជីញ្ចុតា)។ |
| ១០ | ១ | អក្ខោ<br>(រង្វាស់ទម្ងន់) | មួយអក្ខ ប្រមាណ១២មាសក |
| ១១ | ៧៦ | ឧសភ[២]<br>(រង្វាស់ប្រវែងឬចម្ងាយ) | ចំនួន២០យដ្ឋិ (វសតិយដ្ឋិ)= ១៤០ហត្ថ;<br>(រង្វាស់ប្រវែង)?; ឈើដែលស្លាប់ក្នុងកាលជាទីបំផុតនៃផ្លែទុំ (ដូច ឧសធិ);<br>គោឈ្មោល (ដូចគោ); ប្រសើរ (ដូចសេដ្ឋ)។ |
| ១២ | ១៩២ | តុម្ពោ<br>(រង្វាល់) | តុម្ព ជាឈ្មោះរង្វាល់ម្យ៉ាង (ដូចអាឡ្ហកោ) |
| ១៣ | ១៩៦ | តុលា | ចំនួន១០០បល (បលសត); ដូចគ្នា, ស្មើគ្នា (ដូចសទិសត្ត); ជ្និមផ្ទះ |

[២] ជួន ណាត៖ វចនានុក្រមខ្មែរ ជ.ឯ.ម.ទំព័រ១៨១៨-១៨១៩ ថាឈ្មោះរង្វាស់ឬមាត្រាវាស់មួយយ៉ាង។

| | | | |
|---|---|---|---|
| ១៤ | ២០៣ | ទ្វិសហស្សបលំ | ចំនួន២ ០០០ បលៈ ហៅថា១ភារៈ, សព្វនេះជា អត្ថនៃភារសព្ទ |
| ១៥ | ២១៦ | ទិយឌ្ឍោ<br>ទិវឌ្ឍោ<br>(ចំនួនរៀប) | ទីពីរដោយកន្លះ គឺ មួយកន្លះ (ដូច ទិវឌ្ឍោ)<br>ទីពីរដោយកន្លះ គឺ មួយកន្លះ |
| ១៦ | ២១៦ | ធញ្ញមាសោ<br>(រង្វាស់ប្រវែង) | មួយធញ្ញមាស = ៧ ឧកា |
| ១៧ | ២១៨ | ធរណោ | ៤ គ្រាប់ស្រូវ ជា ១កុញ្ជា<br>២កុញ្ជា ជា ១មាសក<br>៥មាសក ២ដង ជា ១០មាសក ជា ១អក្ខ<br>៨អក្ខ ជា ១ធរណោ<br>៥ធរណោ ជា ១សុវណ្ណ<br>៥សុវណ្ណ ជា ១និក្ខ<br>៥និក្ខ ជា ១បាទ |
| ១៨ | ៣១០ | ភារោ<br>(រង្វាស់ទម្ងន់) | ១០០បលៈ ជា ១តុលា<br>២០តុលា ជា ១ភារ (១ហាប) |
| ១៩ | ២៦៤ | បលំ | បលមួយមានចំនួន១០ធរណៈ |
| ២០ | ៣២៩ | មាណិកា(រង្វាស់) | ឈ្មោះរង្វាស់ម្យ៉ាងប្រមាណ ៤ទោណៈ |
| ២១ | ៣៣១ | មាសកោ<br>(រង្វាស់ទម្ងន់) | មាសក,<br>តម្លៃមាសមានទម្ងន់ស្មើគ្នានឹងស្រូវ៨គ្រាប់ |
| ២២ | ៣៤៣ | យដ្ឋិ(រង្វាស់ប្រវែង) | ប្រវែង៧ហត្ថ ហៅថា ១យដ្ឋិ |

| | | | |
|---|---|---|---|
| ២៣ | ៣៤៩ | រថរេណុ/រថរេណូ[៣] | ១រថរេណុ = ៣៦តជ្ជារី<br>១តជ្ជារី = ៣៥អណុ<br>១ អណុ = ៣៦ បរមាណុ |
| ២៤ | ៣៦០ | លិក្ខាឬលិក្យា[៤]<br>(រង្វាស់ប្រវែង) | ១លិក្ខា = ៣៦រថរេណុ<br>៧លិក្ខា = ១ឩកា<br>៧ឩកា = ១ធញ្ញមាស<br>៧ធញ្ញមាស = ១អង្គុលៈ(អង្គុលី)<br>១២អង្គុលៈ = ១វិទត្ថិ(១ចំអាម)<br>២វិទត្ថិ = ១រតនៈ(១ហត្ថ)<br>៧រតនៈ = ១យដ្ឋិ<br>២០យដ្ឋិ = ឧសភៈ(= ១៤០ហត្ថ)<br>៨០ឧសភៈ = ១គាវុត(= ១១.២០០ហត្ថ )<br>៤គាវុត = ១យោជន៍ ( = ៤៤. ៨០០ហត្ថ; ន័យខ្លះថា ៤០០សិន )<br>១រថរេណុ = ៣៦តជ្ជារី<br>១តជ្ជារី = ៣៦អណុ<br>១អណុ = ៣៦បរមាណុ |
| ២៥ | ៤៣៨ | សុវណ្ណោ | ១សិវណ្ណោ ត្រូវជា ៥ធរណៈ |

[៣] ជួន ណាតៈ វចនានុក្រមខ្មែរ ជ.ឯ.ម. ទំព័រ៩៨៥ សរសេរ *រថរេណូ* ឈ្មោះគ្រឿងរាប់យ៉ាងល្អិតមួយប្រភេទប្រមាណ៣៦ តជ្ជារី។

[៤] -ដ- ទំព័រ១១០៣។